រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សកម្មភាពឃុំ សង្កាត់ ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹង សុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

354.968
ACT

ខែកញ្ញា ឆ្នាំ២០១០

sh: training

NCDD Library
000410

# មាតិកា


សេចក្តីផ្តើម ..... iv

ផ្នែកទី១. ស្ថានភាពសេវាសង្គមនៅឃុំ សង្កាត់ ..... ១

១.១. សុខភាពមាតា ..... ១

១.១.១. សេវាសុខភាពនៅឃុំ សង្កាត់ ..... ១

១.១.២. ការថែទាំសុខភាពមាតា និងទារក ..... ២

១.១.៣. ការផ្តល់អាហារូបត្ថម្ភ ..... ៤

១.២. អនាម័យ ..... ៥

១.២.១. ស្ថានភាពអនាម័យនៅសហគមន៍ ..... ៥

១.២.២. ជំងឺមួយចំនួនដែលបណ្តាលមកពីខ្វះអនាម័យ ..... ៦

១.៣. មត្តេយ្យសិក្សាសហគមន៍ ..... ១០

១.៣.១. ការអប់រំនៅកម្ពុជា ..... ១០

១.៣.២. ការអប់រំកុមារតូច ..... ១៣

១.៣.៣. កត្តាសំខាន់ៗពាក់ព័ន្ធនឹងគុណភាពនៃការអប់រំ ..... ១៤

១.៤. សមភាពយេនឌ័រ ..... ១៥

១.៤.១. ទស្សនៈទូទៅនៃយេនឌ័រ ..... ១៥

១.៤.២. ការបញ្ជ្រាបយេនឌ័រ ..... ១៩

១.៤.៣. សមភាពយេនឌ័រក្នុងវិស័យអប់រំ ..... ២២

១.៤.៤. សមភាពយេនឌ័រក្នុងការអភិវឌ្ឍឃុំ សង្កាត់ ..... ២៤

១.៥. កិច្ចការពារកុមារ ..... ២៦

១.៥.១. សិទ្ធិជាមូលដ្ឋានរបស់កុមារ ..... ២៦

១.៥.២. ទម្រង់នៃការរំលោភបំពានលើកុមារ ..... ២៩

១.៥.៣. កុមារដែលទទួលរងនូវការរំលោភបំពាន ..... ៣០

១.៥.៤. ការថែទាំជំនួសចំពោះកុមារ ..... ៣៥

ផ្នែកទី២. សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម ..... ៣៩

២.១. ការរៀបចំផែនការអភិវឌ្ឍន៍ផ្នែកសង្គម ..... ៣៩

២.១.១. ការកំណត់តម្រូវការអភិវឌ្ឍន៍ផ្នែកសង្គម ........ ៣៩
២.១.២. ការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់ការអភិវឌ្ឍន៍ផ្នែកសង្គម ........ ៤០
២.២. ការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គម ........ ៤៨
២.២.១. ការអនុវត្តសកម្មភាពអប់រំផ្សព្វផ្សាយ ........ ៤៨
២.២.២. ការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារដល់ស្ត្រីមានផ្ទៃពោះ ........ ៥១
២.២.៣. ការចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ ........ ៥៦
២.២.៤. ការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍ ........ ៦៤
២.២.៥. ការរៀបចំវេទិកាលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ ........ ៧៦
២.២.៦. ការគាំទ្រមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ........ ៧៩
២.៣. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ........ ៨១
ផ្នែកទី៣. យន្តការគាំទ្រការអភិវឌ្ឍផ្នែកសង្គម ........ ៨៦
៣.១. តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ សង្កាត់ ........ ៨៦
៣.១.១. ក្រុមប្រឹក្សាឃុំ សង្កាត់ ........ ៨៦
៣.១.២. មេឃុំ ចៅសង្កាត់ ........ ៨៦
៣.១.៣. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ........ ៨៧
៣.១.៤. អ្នកដឹកនាំភូមិ ........ ៨៨
៣.១.៥. អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ........ ៨៨
៣.១.៦. ភ្នាក់ងារសេវាសុខភាពសហគមន៍ ........ ៨៩
៣.១.៧. អ្នកសម្របសម្រួលអនាម័យសហគមន៍ ........ ៨៩
៣.១.៨. គ្រូមត្តេយ្យសិក្សាសហគមន៍ ........ ៩០
៣.២. តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត ........ ៩០
៣.២.១. ទីចាត់ការផែនការ និងវិនិយោគ ........ ៩០
៣.២.២. មន្ទីរសុខាភិបាល ........ ៩១
៣.២.៣. មន្ទីរអភិវឌ្ឍន៍ជនបទ ........ ៩១
៣.២.៤. មន្ទីរអប់រំ យុវជន និងកីឡា ........ ៩២
៣.២.៥. មន្ទីរកិច្ចការនារី ........ ៩២
៣.២.៦. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ........ ៩៣

## ឧបសម្ព័ន្ធ


ទម្រង់ទី១ : ផែនការសកម្មភាពប្រចាំឆ្នាំ ........ ៩៤
ទម្រង់ទី២ : ផែនការថវិកាប្រចាំឆ្នាំ ........ ៩៦
ទម្រង់ទី៣ : ផែនការសកម្មភាពប្រចាំត្រីមាស ........ ៩៨
ទម្រង់ទី៤ : ផែនការថវិកាប្រចាំត្រីមាស ........ ១០០
ទម្រង់ទី៥ : កម្មវិធីផ្សព្វផ្សាយ ........ ១០១
ទម្រង់ទី៦ : ទិន្នន័យស្ត្រីមានផ្ទៃពោះតាមភូមិនីមួយៗ ........ ១០២
ទម្រង់ទី៧ : សំណើសុំ ........ ១០៣
ទម្រង់ទី៨ : បញ្ជីឈ្មោះស្ត្រីមានផ្ទៃពោះទទួលបានការគាំទ្រ ........ ១០៤
ទម្រង់ទី៩ : ទិន្នន័យនៃការប្រើប្រាស់បង្គន់អនាម័យតាមគ្រួសារ ........ ១០៥
ទម្រង់ទី១០ : ប្រជាពលរដ្ឋចូលរួមសាងសង់បង្គន់អនាម័យ ........ ១០៦
ទម្រង់ទី១១ : បញ្ជីឈ្មោះគ្រួសារដែលត្រូវផ្តល់សម្ភារៈបង្គន់អនាម័យ ........ ១០៧
ទម្រង់ទី១២ : កិច្ចសន្យាផ្តល់សម្ភារៈបង្គន់អនាម័យ ........ ១០៨
ទម្រង់ទី១៣ : កាលវិភាគបណ្តុះបណ្តាលស្តីពី បច្ចេកទេសសាងសង់បង្គន់អនាម័យដល់ប្រជាពលរដ្ឋ ១០៩
ទម្រង់ទី១៤ : តារាងតាមដានភាពរីកចម្រើននៃការសាងសង់បង្គន់អនាម័យ ........ ១១០
ទម្រង់ទី១៥ : កុមារអាយុ៣-៥ឆ្នាំតាមភូមិនីមួយៗ ........ ១១១
ទម្រង់ទី១៦ : បញ្ជីឈ្មោះសិស្សចូលរៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ ........ ១១២
ទម្រង់ទី១៧ : កិច្ចសន្យាផ្តល់សេវាបង្រៀនមត្តេយ្យសិក្សាសហគមន៍ ........ ១១៣
ទម្រង់ទី១៨ : របាយការណ៍តាមដានវត្តមានសិស្ស ........ ១១៥
ទម្រង់ទី១៩ : របាយការណ៍ស្តីពីការបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ ........ ១១៦
ទម្រង់ទី២០ : របាយការណ៍រីកចម្រើនស្តីពីការអនុវត្តសកម្មភាព ........ ១១៧
ទម្រង់ទី២១ : របាយការណ៍រីកចម្រើនស្តីពីការអនុវត្តថវិកា ........ ១១៩

# អារម្ភកថា

ដើម្បីរួមចំណែកធ្វើឱ្យសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានវិភាជន៍មូលនិធិទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ១១៩៩ឃុំ សង្កាត់នៅ ១៨រាជធានី ខេត្ត ដើម្បីអនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់។

ដើម្បីជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងការអនុវត្តមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិបានរៀបចំសេចក្តីណែនាំ ស្តីពី អនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់ លេខ ០៥១ ស.ណ.ន/គ.ជ.អ.ប ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០។

មេរៀននេះរៀបចំឡើងក្នុងគោលបំណង ផ្តល់ជាជំនួយស្មារតីក្នុងការអនុវត្តសេចក្តីណែនាំ ស្តីពី អនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់។ មេរៀននេះ នឹងផ្តល់ការយល់ដឹងជាមូលដ្ឋានទាក់ទងនឹងស្ថានភាពសេវាសង្គមនៅឃុំ សង្កាត់ សកម្មភាពឃុំ សង្កាត់ ក្នុងការអភិវឌ្ឍន៍ផ្នែកសង្គម និងយន្តការគាំទ្រក្នុងការអភិវឌ្ឍន៍ផ្នែកសង្គម។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សង្ឃឹមយ៉ាងមុតមាំថា ខ្លឹមសារមេរៀននេះនឹងផ្តល់សារប្រយោជន៍ដល់ការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធទាំងអស់ និងស្វាគមន៍ជានិច្ចនូវមតិរិះគន់ស្ថាបនា ដើម្បីកែលម្អខ្លឹមសារមេរៀននេះកាន់តែប្រសើរឡើង។

# ផ្នែកទី១.

# ស្ថានភាពសេវាសង្គម

# នៅឃុំ សង្កាត់

# ផ្នែកទី១. ស្ថានភាពសេវាសង្គមនៅឃុំ សង្កាត់

ស្ថានភាពសេវាសង្គមនៅឃុំ សង្កាត់ ដែលលើកយកមកបង្ហាញនេះ ផ្តោតចម្បងលើការអភិវឌ្ឍផ្នែកសង្គមទាក់ទងនឹងសុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់ ដែលជាផ្នែកសំខាន់មួយនៅក្នុងការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

## ១.១. សុខភាពមាតា និងទារក

### ១.១.១. សេវាសុខភាពនៅឃុំ សង្កាត់

ប្រជាពលរដ្ឋអាចទទួលសេវាថែទាំសុខភាពនៅថ្នាក់ឃុំ សង្កាត់មានដូចជា មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព ប៉ុស្តិ៍សុខភាព និងការផ្តល់សេវាចុះមូលដ្ឋាន។

ក). មន្ទីរពេទ្យបង្អែក

មន្ទីរពេទ្យបង្អែកបង្កើតឡើងផ្អែកតាមចំនួនប្រជាពលរដ្ឋ។ មន្ទីរពេទ្យបង្អែកមួយបម្រើប្រជាពលរដ្ឋពី ៦០.០០០នាក់ ទៅ ២០០.០០០នាក់ (ជាមធ្យម ១០០.០០០នាក់) ដែលមាន៨ទៅ១៥មណ្ឌលសុខភាពចំណុះ។ មន្ទីរពេទ្យបង្អែកផ្តល់សេវាសុខភាពដូចជា:

- ការការពារ : ការធ្វើតេស្ត និងប្រឹក្សាដោយស្ម័គ្រចិត្តអំពីកម្មវិធី បង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- ការថែទាំ និងព្យាបាល : ការពិគ្រោះ ពិនិត្យ និងព្យាបាលជំងឺទូទៅធ្ងន់ធ្ងរ ការវះកាត់ធំ ការសម្រាលកូន និងជំងឺឯកទេស (ធ្មេញ បំពង់ក ភ្នែក ....)។

ខ). មណ្ឌលសុខភាព

មណ្ឌលសុខភាពបង្កើតឡើងផ្អែកតាមចំនួនប្រជាពលរដ្ឋ។ មណ្ឌលសុខភាពមួយបម្រើប្រជាពលរដ្ឋពី ៨.០០០នាក់ ទៅ ១២.០០០នាក់។ មណ្ឌលសុខភាពផ្តល់សេវាសុខភាពជាអប្បបរមាដូចជា:

- ការការពារ : ផ្តល់ថ្នាំបង្ការ ផ្តល់គ្រាប់ថ្នាំជីវជាតិអា ការផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិក ការពិនិត្យផ្ទៃពោះមុនពេលសម្រាល ក្រោយពេលសម្រាល ការពន្យារកំណើត ពិនិត្យមើលបញ្ហាកង្វះអាហារូបត្ថម្ភ ការអប់រំសុខភាពមាតា និងទារក
- ការថែទាំ និងព្យាបាល : ការពិគ្រោះ ពិនិត្យ និងព្យាបាលជំងឺទូទៅ ជំងឺកាមរោគ ការវះកាត់តូច ការធ្វើតេស្តឈាម និងព្យាបាល ជំងឺគ្រុនចាញ់ ការសម្រាលធម្មតា ព្យាបាលជំងឺរបេងដោយប្រើប្រាស់ ដូតស៍ សង្កេតជំងឺហង់សិន និងបញ្ជូនទៅផ្នែកសេវាសុខភាពពាក់ព័ន្ធ។

ប្រសិនបើ មណ្ឌលសុខភាពមិនអាចព្យាបាលបានត្រូវបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យបង្អែក។

គ). ប៉ុស្តិ៍សុខភាព

ករណីប្រជាពលរដ្ឋរស់នៅរាយប៉ាយមិនមានលក្ខណៈ ប្រមូលផ្តុំនៅមួយកន្លែង គេអាចបង្កើតប៉ុស្តិ៍សុខភាពនៅតាមកន្លែង ឬតំបន់ទាំងនោះ ជាពិសេសតំបន់ដាច់ស្រយាល ។ ប៉ុស្តិ៍សុខភាពផ្តល់សេវាសុខភាពដូចជា :

- ការការពារ : ផ្តល់ថ្នាំបង្ការក្នុងវ័យបន្តពូជអាយុ១៥-៤៤ឆ្នាំ និងកុមារអាយុតិចជាង១ឆ្នាំ ផ្តល់គ្រាប់ថ្នាំជីវជាតិអា ការផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិក ការពិនិត្យផ្ទៃពោះមុនពេលសម្រាល ក្រោយពេលសម្រាល ការពន្យារកំណើត ពិនិត្យមើលកង្វះអាហារូបត្ថម្ភ និងការអប់រំសុខភាពមាតា និងទារក
- ការថែទាំ និងព្យាបាល : ការពិគ្រោះ ពិនិត្យ និងព្យាបាលជំងឺទូទៅ ជំងឺកាមរោគ ការធ្វើតេស្តឈាម និងព្យាបាលជំងឺគ្រុនចាញ់ ព្យាបាលជំងឺរបេងដោយប្រើប្រាស់ដូតស៍ (លេបថ្នាំតាមវេជ្ជបញ្ជា និងនៅចំពោះមុខគ្រូពេទ្យ) សង្កេតជំងឺហង់សិន និងបញ្ជូនទៅផ្នែកសេវាសុខភាពពាក់ព័ន្ធ ។

ឃ). ការផ្តល់សេវាចុះមូលដ្ឋាន

ការផ្តល់សេវាចុះមូលដ្ឋានត្រូវបានចុះមួយខែម្តងសម្រាប់ភូមិជិត១ និងពីរខែម្តងសម្រាប់ភូមិដាច់ស្រយាល ។ ការផ្តល់សេវាចុះមូលដ្ឋានមានសេវាសុខភាពដូចជា :

- ការការពារ : ផ្តល់ថ្នាំបង្ការដល់ស្ត្រីក្នុងវ័យបន្តពូជអាយុ ១៥-៤៤ឆ្នាំ និងកុមារអាយុតិចជាង១ឆ្នាំ (មិនគិតថ្លៃ) ការពិនិត្យផ្ទៃពោះមុនពេលសម្រាល ក្រោយពេលសម្រាល (ចំពោះភូមិដាច់ស្រយាល និងគ្មានមណ្ឌលសុខភាពនៅជិត) ការផ្តល់ជីវជាតិអា សម្រាប់កុមារអាយុ៦-៥៩ខែ និងទម្លាក់ព្រូនសម្រាប់កុមារអាយុ១២-៥៩ខែ ២ដងក្នុងមួយឆ្នាំ ការអប់រំសុខភាព និងការពន្យារកំណើត
- ការថែទាំ និងព្យាបាល : ការព្យាបាលជំងឺគ្រុនចាញ់នៅតំបន់មានជំងឺគ្រុនចាញ់ខ្លាំង ។

### ១.១.២. ការថែទាំសុខភាពមាតា និងទារក

ការថែទាំសុខភាពមាតា និងទារកជាកិច្ចការមួយយ៉ាងសំខាន់ ដែលស្ត្រីមានផ្ទៃពោះ និងស្ត្រីជាមាតាគ្រប់រូបត្រូវយកចិត្តទុកដាក់ ពិសេសពិនិត្យផ្ទៃពោះមុនពេលសម្រាល ការបំបៅកូនដោយទឹកដោះម្តាយមួយមុខគត់ និងអាហារបន្ថែមដល់ទារក ការផ្តល់ថ្នាំបង្ការជំងឺដល់កុមារ និងការផ្តល់អាហារូបត្ថម្ភ ។

ក). ការពិនិត្យផ្ទៃពោះមុនពេលសម្រាល



គោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលបានបញ្ជាក់ថា ទោះជានៅទីណាក៏ដោយ ការសម្រាលត្រូវធ្វើឡើងជាមួយពេទ្យឆ្មបជំនាញដែលបានទទួលការបណ្តុះបណ្តាលរួច ។ ប្រសិនបើ មិនអាចរកពេទ្យឆ្មបជំនាញដែលបានទទួលការបណ្តុះបណ្តាលបានត្រូវជំនួសដោយសេវាឆ្មបបុរាណដែលបានឆ្លងកាត់ការបណ្តុះបណ្តាល ។

**ការត្រៀមជុំវិញកំណើត :**

- ពិនិត្យផ្ទៃពោះយ៉ាងតិច២ដង ក្នុងអំឡុងពេលមានផ្ទៃពោះ
- ហូបចំណីអាហារចម្រុះឱ្យបានគ្រប់គ្រាន់ និងថ្នាំជាតិដែកបន្ថែមតាមវេជ្ជបញ្ជា
- ទទួលការណែនាំពីគ្រូពេទ្យអំពីអ្វីដែលមិនគួរធ្វើក្នុងពេលមានផ្ទៃពោះ ដូចជា សេពគ្រឿងស្រវឹង ជក់បារី និងការប្រើថ្នាំដោយពុំមានវេជ្ជបញ្ជា
- សន្សំប្រាក់សម្រាប់ទំនុកបម្រុងពេលសម្រាលកូន
- បម្រុងមធ្យោបាយធ្វើដំណើរសម្រាប់បញ្ជូនទៅមណ្ឌលសុខភាព ពេលមានបញ្ហា ឬពេលសម្រាលកូន
- សម្រាលកូនត្រូវសម្រាលដោយឆ្មបជំនាញនៅមណ្ឌលសុខភាព
- ទទួលការណែនាំពីគ្រូពេទ្យអំពីសារប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្តាយ និងការចាក់ថ្នាំបង្ការ ។

ការត្រៀមជីវិញកំណើតទទួលបានលទ្ធផលល្អ មិនត្រឹមតែមានការយកចិត្តទុកដាក់ពីស្ត្រីមានផ្ទៃពោះប៉ុណ្ណោះទេ ប៉ុន្តែទាមទារឱ្យមានការយកចិត្តទុកដាក់ និងការគាំពារពីក្រុមគ្រួសារ ពិសេសស្វាមីរបស់ស្ត្រីដែលមានផ្ទៃពោះផងដែរ ។

## ង). ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ និងការផ្តល់អាហារបន្ថែម



ទឹកដោះម្តាយតែមួយមុខ គឺជាអាហារ និងទឹកដែលទារកត្រូវការក្នុងអំឡុងពេល៦ខែដំបូង ។ បន្ទាប់ពី៦ខែ ទារកត្រូវការអាហារបន្ថែមពីលើទឹកដោះម្តាយ ។ ការបំបៅកូនដោយទឹកដោះតែមួយមុខគត់មានន័យថា ផ្តល់តែទឹកដោះសុទ្ធមិនមានបន្ថែមទឹក ទោះបីជាបរិយាកាសក្តៅយ៉ាងណាក៏ដោយ ក៏មិនត្រូវបន្ថែមវត្ថុរាវផ្សេងដែរ ។ បើអ្នកគិតថា ទារករបស់អ្នកស្រេកទឹក អ្នកត្រូវបំបៅដោះភ្លាម ។ ទឹកដោះម្តាយមានជាតិទឹកគ្រប់គ្រាន់ជាតិទឹក៨០% ។ ទឹកដោះតែមួយមុខគត់អាចបំពេញអ្វីដែលទារកត្រូវការ ដើម្បីធំធាត់មានកម្លាំងមាំមួន និងសុខភាពល្អក្នុងអំឡុងពេល៦ខែដំបូង ។

ការបំបៅកូនដោយទឹកដោះម្តាយសុទ្ធតែមួយមុខគត់មានសារប្រយោជន៍ ដូចជា :

- ជាអាហារដែលល្អបំផុតតែមួយគត់ ដើម្បីជួយឱ្យទារកធំធាត់ប្រកបដោយសុខភាព និងថាមពល
- ជាអាហារល្អឥតខ្ចោះសម្រាប់ទារក ងាយរំលាយ និងចិញ្ចឹមរាងកាយទារកបានយ៉ាងមានប្រសិទ្ធភាព
- ផ្ទុកទៅដោយអង្គបដិបក្ខ ដែលអាចការពារទារកពីជំងឺ និងការបង្ករោគផ្សេងៗ
- គាំពារទារកមិនឱ្យកើតជំងឺរាគរូស និងជំងឺផ្លូវដង្ហើម
- ជាអាហារបរិសុទ្ធស្រស់ៗ និងមានសីតុណ្ហភាពសមល្មម
- អាចពន្យារកំណើតបានមួយរយៈពេល
- មិនត្រូវការចំណាយប្រាក់សម្រាប់ទិញ ។

### គ). ការផ្តល់ថ្នាំបង្ការជំងឺដល់កុមារ



ការផ្តល់ថ្នាំបង្ការ គឺជាមធ្យោបាយមួយមានសុវត្ថិភាព និងប្រសិទ្ធភាពបំផុតក្នុងការការពារប្រឆាំងនឹងជំងឺធ្ងន់ធ្ងរមួយចំនួន។ បន្ទាប់ពីបានទទួលថ្នាំបង្ការហើយសពាង្គកាយរបស់ទារក ឬកុមារនឹងអាចប្រយុទ្ធប្រឆាំង ឬការពារនឹងជំងឺ ដែលមកយាយីសពាង្គកាយរបស់ពួកគេ។ ការផ្តល់ថ្នាំបង្ការ គឺជាបញ្ហាបន្ទាន់។ គ្រប់កុមារទាំងអស់ត្រូវទទួលថ្នាំបង្ការឱ្យបានគ្រប់ចំនួនក្នុងឆ្នាំទី១នៃជីវិតរបស់ពួកគេ។ ការផ្តល់ថ្នាំបង្ការអាចការពារទល់នឹងជំងឺគ្រោះថ្នាក់ជាច្រើន។ កុមារដែលមិនបានទទួលការផ្តល់ថ្នាំបង្ការអាចរងគ្រោះថ្នាក់ដោយជំងឺជាញឹកញាប់ ខ្លះទៅជាពិការអស់មួយជីវិត ខ្លះទៅជាខ្វះអាហារូបត្ថម្ភ និងអាចបណ្តាលឱ្យស្លាប់។

**ប្រតិទិននៃការចាក់ថ្នាំបង្ការជំងឺរបស់កុមារនៅកម្ពុជា**

| ចំនួនលើក | អាយុកុមារ | ថ្នាំបង្ការដែលត្រូវផ្តល់ឱ្យ |
|---|---|---|
| លើកទី១ | ទើបកើត | ការពារជំងឺរបេង ជំងឺរលាកថ្លើមប្រភេទបេ |
| លើកទី២ | អាយុ១ខែកន្លះ | ការពារជំងឺគ្រុនស្វិតដៃជើង ជំងឺក្អកមាន់ ខាន់ស្លាក់ តេតាណូស ជំងឺរលាកថ្លើមប្រភេទបេ និងជំងឺហ៊ិប |
| លើកទី៣ | អាយុ២ខែកន្លះ | ការពារជំងឺគ្រុនស្វិតដៃជើង ជំងឺក្អកមាន់ ខាន់ស្លាក់ តេតាណូស ជំងឺរលាកថ្លើមប្រភេទបេ និងជំងឺហ៊ិប |
| លើកទី៤ | អាយុ៣ខែកន្លះ | ការពារជំងឺគ្រុនស្វិតដៃជើង ជំងឺក្អកមាន់ ខាន់ស្លាក់ តេតាណូស ជំងឺរលាកថ្លើមប្រភេទបេ និងជំងឺហ៊ិប |
| លើកទី៥ | អាយុ៩ខែ | ការពារជំងឺកញ្ជ្រិល |

## ១.១.៣. ការផ្តល់អាហារូបត្ថម្ភ

### ក). អាហារូបត្ថម្ភ



អាហារូបត្ថម្ភ គឺជាសារធាតុមាននៅក្នុងចំណីអាហារ ដែលជួយដល់ការលូតលាស់រាងកាយ និងប្រាជ្ញាស្មារតីរបស់មនុស្ស។ មនុស្សអាចទទួលបានអាហារូបត្ថម្ភ តាមរយៈការបរិភោគចំណីអាហារ ដូចជា សាច់ ស៊ុត ទឹកដោះ ផលិតផលទឹកដោះ ត្រី សណ្តែកសៀង គ្រាប់ធញ្ញជាតិ បន្លែបៃតង និងផ្លែឈើ។ល។ ក្រៅពីនេះ ប្រជាពលរដ្ឋក៏អាចទទួលអាហារូបត្ថម្ភបន្ថែមពីមណ្ឌលសុខភាពផងដែរ ដូចជា គ្រាប់ថ្នាំជីវជាតិអា គ្រាប់ថ្នាំជីវជាតិដែក។ល។

ខ). **ជីវជាតិអា**



ជីវជាតិអា គឺជាជីវជាតិដ៏សំខាន់មួយសម្រាប់ការធំលូតលាស់អភិវឌ្ឍន៍រូបរាងកាយ និងសុខភាពរបស់កុមារ ដើម្បីការពារជំងឺខ្វាក់មាន់។ ការផ្តល់ជីវជាតិអា គឺជាផ្នែកមួយនៃសកម្មភាពផ្តល់សេវាចុះមូលដ្ឋានរបស់បុគ្គលិកមណ្ឌលសុខភាព ដែលត្រូវផ្តល់២ដងក្នុងមួយឆ្នាំ នៅខែឧសភា និងខែវិច្ឆិកា សម្រាប់កុមារអាយុ៦ខែ ដល់៥៩ខែ និងផ្តល់ឱ្យជារៀងរាល់ខែសម្រាប់ស្ត្រីក្រោយពេលសម្រាលក្នុងអំឡុងពេល៦ សប្តាហ៍។

គ). **អំបិលអ៊ីយ៉ូដ**




អំបិលអ៊ីយ៉ូដមានសារៈសំខាន់ណាស់សម្រាប់ជួយដល់បញ្ហា និងការអភិវឌ្ឍរាងកាយរបស់កុមារ។ ជាតិអ៊ីយ៉ូដបន្តិចបន្តួចមានសារសំខាន់ជួយដល់ការលូតលាស់របស់កុមារ។ ប្រសិនបើ កុមារមិនបានទទួលជាតិអ៊ីយ៉ូដគ្រប់គ្រាន់ ឬម្តាយខ្វះជាតិអ៊ីយ៉ូដពេលមានផ្ទៃពោះ កូនកើតមកនឹងមានពិការភាពខាងស្មារតី ការស្តាប់ និងការនិយាយ ឬធ្វើឱ្យការលូតលាស់ផ្នែកផ្លូវកាយ និងផ្លូវចិត្តមានការយឺតយ៉ាវ។

ជំងឺពកក គឺជាសញ្ញានៃកង្វះជាតិអ៊ីយ៉ូដក្នុងចំណីអាហារ។ ស្ត្រីមានផ្ទៃពោះដែលមានជំងឺពកក គឺអាចប្រឈមនឹងគ្រោះថ្នាក់ដូចជា ការរលូតកូន ទារកស្លាប់ក្នុងពោះ ឬទារក ដែលកើតមកមានការខូចខាតផ្នែកខួរក្បាល។ ការប្រើប្រាស់អំបិលលាយអ៊ីយ៉ូដជំនួសអំបិលធម្មតាអាចឱ្យម្តាយ និងកូនមានជាតិអ៊ីយ៉ូដគ្រប់គ្រាន់តាមសេចក្តីត្រូវការ។

## ១.២. អនាម័យ

អនាម័យ មានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងបញ្ហាសុខភាពរបស់ប្រជាពលរដ្ឋ។ អនាម័យរួមចំណែកមួយយ៉ាងសំខាន់ក្នុងការជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋផងដែរ។

### ១.២.១. ស្ថានភាពអនាម័យនៅសហគមន៍

ក). **អនាម័យនៅសហគមន៍**



អនាម័យ ជាវិធីមួយយ៉ាងសំខាន់ជួយដល់ការរស់នៅរបស់ប្រជាពលរដ្ឋ និងសហគមន៍ឱ្យមានសុខភាពល្អ និងជៀសផុតពីជំងឺទាំងឡាយ។ អនាម័យនៅសហគមន៍មានដូចជា :

- **អនាម័យផ្ទាល់ខ្លួន** : ការសម្អាតដៃ ការសម្អាតខ្លួនប្រាណ ការទុកដាក់ទឹកស្អាត ការប្រើប្រាស់ទឹកស្អាត ការទុកដាក់ចំណីអាហារ ។ល។
- **អនាម័យបរិស្ថាន** : ការទុកដាក់សំរាម សម្អាតព្រៃជុំវិញលំនៅដ្ឋាន បន្ទោរបង់ ការខាកស្តោះ ការបង្ហូរទឹកសម្អុយ និងការថែទាំប្រភពទឹក ។ល។

ខ). បញ្ហាអនាម័យនៅសហគមន៍

ខ.១). បញ្ហាអនាម័យផ្ទាល់ខ្លួន

- ទុកដាក់ទឹកមិនបានត្រឹមត្រូវ ប្រើប្រាស់ទឹកមិនស្អាត និងផឹកទឹកឆៅ
- ក្រោយពីបន្ទោរបង់ លាងលាមកកូន ឬការប៉ះពាល់មាន់ ទា ជាដើម ហើយមិនបានសម្អាតដៃនឹងសាប៊ូ
- មិនបានសម្អាតដៃនឹងសាប៊ូមុនពេលបរិភោគចំណីអាហារ
- ទុកដាក់ចំណីអាហារមិនបានគ្របឱ្យជិត ឬមានរុយរោម
- ទុកដាក់ និងការលាងសម្អាតចាន ឆ្នាំងមិនបានស្អាត
- សម្រានមិនបានចងមុងការពារមូសខាំ

ខ.២). បញ្ហាអនាម័យបរិស្ថាន

- បន្ទោរបង់ពាសវាលពាសកាល
- ខាកស្តោះពាសវាលពាសកាល
- ចោលសំរាមពាសវាលពាសកាល និងក្នុងប្រភពទឹក
- ទុកព្រៃ និងស្មៅដុះស៊ុបទ្រុបជុំវិញលំនៅដ្ឋាន ដែលជាជម្រកមូស
- ទុកដាក់សម្ភារៈ សំបកកំប៉ុង សំបកកង់ឱ្យដក់ទឹកបង្កជាជម្រកមូស

កង្វះអនាម័យជាមូលហេតុចម្បងនៃការចម្លងរោគ និងបង្កឱ្យមាន ជំងឺ ដូចជា ដង្កូវក្នុងពោះវៀន (ព្រូន) ជំងឺរាក ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម និងជំងឺផ្តាសាយបក្សី ។ល។

គ). សារប្រយោជន៍នៃអនាម័យនៅសហគមន៍

- ធ្វើឱ្យឃុំ សង្កាត់ ភូមិ និងលំនៅដ្ឋានមានបរិស្ថានល្អ
- កាត់បន្ថយជំងឺដង្កាត់ និងជំងឺរាតត្បាត
- បង្កើនសុខភាពផ្ទាល់ខ្លួន និងសុខភាពសាធារណៈ
- កាត់បន្ថយការចំណាយលើសេវាសុខភាព
- បង្កើតទម្លាប់ល្អក្នុងការរស់នៅស្អាត
- ចូលរួមចំណែកក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ

### ១.២.២. ជំងឺមួយចំនួនដែលបណ្តាលមកពីខ្វះអនាម័យ

ក). ព្រូន

ប្រជាពលរដ្ឋភាគច្រើនកើតមានជំងឺដង្កូវក្នុងពោះវៀន (ព្រូន) អ្នកទាំងនោះភាគច្រើនជាកុមារ និងអ្នកក្រីក្រ។ ភាគច្រើននៃកុមារដែលរងគ្រោះ គឺកុមារក្រីក្រ ដែលពួកគេច្រើនតែមានសុខភាពមិនល្អ និងខ្វះអាហារូបត្ថម្ភ។ នៅពេលមានការទម្លាក់ព្រូនកុមារនៅតាមសាលារៀន និងនៅតាមសហគមន៍ កុមារដែលរងគ្រោះទាំងនេះនឹងមានសុខភាពល្អប្រសើរជាងមុន។

កុមារជាច្រើនចាប់ផ្តើមកើតព្រូន បន្ទាប់ពីបញ្ឈប់ការបំបៅដោះដោយទឹកដោះម្តាយ ហើយក៏បន្តកើតមាន និងកើតមានសាជាថ្មីជាវេ្យងរហូតនៅក្នុងជីវិតរស់នៅរបស់ពួកគេ។

ផលប៉ះពាល់ដោយដង្កូវក្នុងពោះវៀន ចំពោះកុមារកើតមានក្នុងរយៈពេលយូរ និងបន្តឥតដាច់ ហើយអាចជះឥទ្ធិពលអាក្រក់ទៅដល់គ្រប់ផ្នែកនៃការរីកចម្រើនរបស់កុមារដូចជា សុខភាព អាហារូបត្ថម្ភ ការអភិវឌ្ឍ ការយល់ដឹង ការសិក្សា ការចងចាំ និងគំនិតច្នៃប្រឌិត។

- **ការទម្លាក់ព្រូនទៀងទាត់អាចជួយឱ្យ :** កុមារមានសុខភាពល្អ រីកលូតលាស់បានល្អ និងកុមារសិក្សាបានលទ្ធផលល្អ
- **ផលរំខាននៃការទម្លាក់ព្រូន :** នៅក្នុងករណីជាច្រើន ការទម្លាក់ព្រូនគ្មានបញ្ហាអ្វីទាំងអស់។ ចំពោះកុមារខ្លះ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីព្រូន នោះអាចបណ្តាលឱ្យមានផលរំខានខ្លះៗ ដូចជា ឈឺពោះតិចៗ ឬរងនូវប្រតិកម្មថ្នាំបន្តិចបន្តួច។

## ខ). ជំងឺរាគ

ជំងឺរាគបណ្តាលមកពីមេរោគ ដែលឆ្លងតាមរយៈការបរិភោគចំណីអាហារ ដែលមានមេរោគ ជាពិសេសពពួកមេរោគនៅក្នុងលាមក។ ជំងឺរាគកើតឡើងជាញឹកញាប់នៅកន្លែងដែលមានការបន្ទោរបង់មិនបានត្រឹមត្រូវ ខ្វះអនាម័យ និងខ្វះទឹកស្អាត។ ជំងឺរាគបណ្តាលឱ្យស្លាប់ដោយសារខ្សោះជាតិទឹកពីក្នុងខ្លួន។

ប្រជាពលរដ្ឋអាចការពារជំងឺរាគតាមមធ្យោបាយដូចខាងក្រោម :

- ត្រូវផឹកទឹកដាំពុះ ជាពិសេសចំពោះកុមារអាយុក្រោម៥ឆ្នាំ
- ត្រូវប្រើបង្គន់អនាម័យ ឬជីកកប់លាមកក្រោយបន្ទោរបង់
- ត្រូវលាងសម្អាតដៃនៅមុនពេលចម្អិនអាហារ មុនពេលបរិភោគ ក្រោយពេលចេញពីបង្គន់ និងក្រោយពេលលាងគូថឱ្យទារក
- បំបៅកូនដោយទឹកដោះម្តាយ និងមិនត្រូវបំបៅដោយដបឡើយ
- ត្រូវរៀបចំផ្ទះបាយឱ្យស្អាតកុំឱ្យមានរុយ និងគ្របអាហារឱ្យជិត
- លាងបន្លែ សាច់មុនពេលចម្អិន និងចម្អិនអាហារ ជាពិសេសសាច់ឱ្យបានឆ្អិនល្អ
- លាងចានជាមួយសាប៊ូ និងទឹកស្អាត
- មិនត្រូវបរិភោគអាហារ ដែលមានក្លិនមិនល្អ ផ្អូម ជុះផ្សិត ឬខូចនោះទេ

## គ). ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម



ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម គឺជាជំងឺដ៏គ្រោះថ្នាក់ធ្ងន់ធ្ងរដែលឆ្លងតាមរយៈ មូសខាំ។ មូសដែកគោលញីចម្លងជំងឺគ្រុនចាញ់ ចំណែកឯមូសខ្លា ចម្លងជំងឺគ្រុនឈាម។

គ.១). ភាពគ្រោះថ្នាក់នៃជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាម

ជំងឺគ្រុនចាញ់ និងជំងឺគ្រុនឈាមមានគ្រោះថ្នាក់ចំពោះមនុស្សទូទៅ ជាពិសេសចំពោះស្ត្រីមានផ្ទៃពោះ និងកុមារ :

- ស្ត្រីមានផ្ទៃពោះ : បង្កការលំបាកនានា ដូចជាកូនស្លាប់ក្នុងផ្ទៃ និងម្តាយអាចស្លាប់នៅពេលសម្រាល
- កុមារ : ការលូតលាស់យឺត និងការរីកចម្រើននៃខួរក្បាលខ្សោយ ថាមពលពុំអាចទប់ទល់នឹងជំងឺបាន ។

ឪពុកម្តាយត្រូវប្រុងប្រយ័ត្នខ្ពស់នៅពេលអ្នកជំងឺមានអាការៈគ្រុនក្តៅខ្លាំង ហើយមានការសង្ស័យថា កើតជំងឺគ្រុនចាញ់ ឬគ្រុនឈាមត្រូវប្រញាប់យកអ្នកជំងឺទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យជាបន្ទាន់ ។

ថ្វីត្បិតតែជំងឺគ្រុនចាញ់ និងគ្រុនឈាម ជាជំងឺដ៏គ្រោះថ្នាក់ក៏ដោយ ក៏ជំងឺទាំងនេះអាចការពារបាន បើយើងអនុវត្តន៍តាមការណែនាំឱ្យបានត្រឹមត្រូវ ។

គ.២). វិធីការពារជំងឺគ្រុនចាញ់ :

- ទោះថ្ងៃ ឬយប់ត្រូវសម្រាន្តក្នុងមុងឱ្យបានត្រឹមត្រូវ
- មុងត្រូវជ្រលក់ថ្នាំ ដើម្បីកុំឱ្យមូសទុំបាន

គ.៣). វិធីការពារជំងឺគ្រុនឈាម

- ទោះថ្ងៃ ឬយប់ត្រូវសម្រាន្តក្នុងមុងឱ្យបានត្រឹមត្រូវ
- មុងត្រូវជ្រលក់ថ្នាំ ដើម្បីកុំឱ្យមូសទុំបាន
- គ្របពាង និងអាងទឹកឱ្យបានជិតល្អ ឬដាក់ថ្នាំអាបែត
- លុប ឬបង្ហូរទឹកចេញពីកន្លែងដែលមានដក់ទឹក
- ធ្វើអនាម័យសម្អាតជុំវិញផ្ទះ

ឃ). ជំងឺផ្តាសាយបក្សី

ជំងឺផ្តាសាយបក្សី គឺជាមេរោគមួយប្រភេទ ដែលបង្កជំងឺលើសត្វបក្សី ទាំងសត្វបក្សីព្រៃ និងសត្វបក្សីស្រុក ។

- សត្វបក្សីព្រៃ រួមមាន សត្វហើរលើអាកាសហោះហើររយៈចម្ងាយជិត និងរយៈចម្ងាយឆ្ងាយ ដែលអាចឆ្លងពីប្រទេសមួយទៅប្រទេសមួយទៀត ហើយអាចឆ្លងរាលដាលជំងឺនៅទូទាំងពិភពលោក
- សត្វស្រុក រួមមាន មាន់ ទា ក្ងាន ដែលចិញ្ចឹមតាមកសិដ្ឋាន ឬតាមគ្រួសារ ដែលមាននៅក្នុងភូមិ ឃុំ ។ល ។

បច្ចុប្បន្ននេះ មេរោគគ្រុនផ្តាសាយបក្សី ( អ៊ីនភ្លូអិនហ្សា អេ អេជ ហ្វាយអិនវ៉ាន់ Influenza A, H5N1) មានលទ្ធភាពឆ្លងទៅមនុស្ស ដែលបង្កឱ្យមានជំងឺធ្ងន់ធ្ងរ និងបង្កឱ្យស្លាប់ ។ អត្រាស្លាប់នៃអ្នកឆ្លងមេរោគនេះមានកម្រិតខ្ពស់ ។

ឃ.១). ការឆ្លងរាលដាលនៃមេរោគផ្តាសាយបក្សី

មេរោគផ្តាសាយបក្សីអាចឆ្លងរាលដាលទៅមនុស្ស ឬបក្សីផ្សេងទៀត តាមរយៈ ការប៉ះពាល់ជាមួយបក្សីដែលឈឺ ឬងាប់ ។ ការឆ្លងមេរោគផ្តាសាយបក្សីអាចឆ្លងតាមរយៈ :

- ធានាថាសម្រេចឱ្យបានការរីកចម្រើនចំនួន៥០% នៅក្នុងកម្រិតអក្ខរកម្មជនពេញវ័យនៅមុនបំណាច់ឆ្នាំ២០១៥ ពិសេសសម្រាប់ស្ត្រីភេទ និងឱកាសស្មើភាពគ្នាក្នុងការអប់រំមូលដ្ឋាន និងការអប់រំបន្តសម្រាប់ជនពេញវ័យទាំងអស់
- លុបបំបាត់ភាពខុសគ្នា (វិសមភាព) នៃយេនឌ័រនៅសាលាបឋមសិក្សា និងមធ្យមសិក្សានៅឆ្នាំ២០០៥ និងធ្វើឱ្យបានសម្រេចនូវសមភាពយេនឌ័រក្នុងវិស័យអប់រំនៅឆ្នាំ២០១៥ ដោយផ្តោតការយកចិត្តទុកដាក់លើការធានាឱ្យកុមារីបានទទួលនូវលទ្ធភាពចូលរៀនពេញលេញ និងស្មើភាព ហើយនឹងសម្រេចបាននូវការអប់រំមូលដ្ឋានប្រកបដោយគុណភាព
- កែលម្អលើគ្រប់ទិដ្ឋភាពនៃគុណភាពអប់រំ និងធានាបាននូវគុណភាពល្អប្រសើរបំផុតគ្រប់ផ្នែក ដើម្បីឱ្យមនុស្សគ្រប់រូបផ្តើមបានលទ្ធផលរៀនសូត្រក្នុងកម្រិតមួយ ដែលអាចទទួលយកបានមានកម្រិតវាស់បាន និងមានការទទួលស្គាល់ ជាពិសេសផ្នែកអក្សរសាស្ត្រ លេខនព្វន្ត និងជំនាញចាំបាច់សម្រាប់ចិញ្ចឹមជីវិត (បំណិនជីវិត) ។

## ឃ). គោលការណ៍៤យ៉ាងនៃការអប់រំ

គោលការណ៍៤យ៉ាងនៃការអប់រំ គឺដើម្បីផ្តល់ឱ្យប្រជាពលរដ្ឋ :

- ទទួលបានចំណេះដឹង
- មានបំណិនជីវិត
- ក្លាយជាមនុស្សល្អប្រកបដោយសីលធម៌រស់នៅល្អ
- រស់នៅជាមួយគ្នាក្នុងសង្គមប្រកបដោយសុខសន្តិភាព និងសុខដុមរមនា ។

## ង). ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា

យោងតាមមាត្រា១៥ នៃច្បាប់ស្តីពី ការអប់រំចែងថា រដ្ឋត្រូវរៀបចំឱ្យមានប្រព័ន្ធអប់រំពេញលេញ និងឯកភាព ដែលរួមមាន ការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ ។

បច្ចុប្បន្នប្រព័ន្ធអប់រំប្រទេសកម្ពុជា គឺជាបរិយាប័ន្ន (ការអប់រំបញ្ចូលគ្នា) មានន័យថាទាំងកុមារា និងកុមារីមានសិទ្ធិទទួលបានការអប់រំស្មើៗគ្នា ទោះបី ក្រីក្រ ពិការ កំព្រា កុមារជនជាតិដើមភាគតិច កុមារនៅតំបន់ដាច់ស្រយាល និងកុមារអនាថា ។ល ។

យោងតាមមាត្រា៦៨ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជាចែងថា រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋម និងមធ្យមសិក្សានៅសាលារៀនសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។

ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា

| ភូមិសិក្សា | កម្រិតថ្នាក់ | អាយុសមស្រប |
|---|---|---|
| មត្តេយ្យសិក្សា | ៣ កម្រិតថ្នាក់ | ៣-៥ ឆ្នាំ |
| បឋមសិក្សា (ភូមិសិក្សាទី១) | ៦ កម្រិតថ្នាក់ | ៦-១១ ឆ្នាំ |
| មធ្យមសិក្សាបឋមភូមិ និង | ៣ កម្រិតថ្នាក់ | ១២-១៤ ឆ្នាំ |
| មធ្យមសិក្សាទុតិយភូមិ (ភូមិសិក្សាទី២) | ៣ កម្រិតថ្នាក់ | ១៥-១៧ ឆ្នាំ |
| ឧត្តមសិក្សា (ភូមិសិក្សាទី៣) | សិក្សាពី ៤-៧ ឆ្នាំ | ១៨ ឆ្នាំឡើងទៅ |

កន្លែងដែលផ្តល់ការអប់រំមានដូចជា :

- នៅសាលារៀន ឬគ្រឹះស្ថានសិក្សា : ថ្នាក់ថែទាំកុមារ មត្តេយ្យសាលា សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ សាកលវិទ្យាល័យ និងវិទ្យាស្ថាន ។ល។
- នៅផ្ទះ (គ្រួសារ) : ទទួលការអប់រំពីឪពុកម្តាយ អ្នកអាណាព្យាបាល ដូចជា ជីដូនជីតា ពីសាច់ញាតិ និងបងប្អូន និងអ្នកគ្រប់គ្រងថែរក្សា ។ល។
- សហគមន៍ (វត្តអារាម) : ថ្នាក់អក្ខរកម្ម ថ្នាក់ហ្វឹកហ្វឺនពីបំណិនជីវិត និងការងារអនុវត្តជាក់ស្តែងនៅសហគមន៍ ។ល។

ឃ). ការអប់រំចូលរួមកាត់បន្ថយភាពក្រីក្រ

ការអប់រំជាយុទ្ធសាស្ត្រមួយរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ដូច្នេះដើម្បីកាត់បន្ថយភាពក្រីក្រតម្រូវឱ្យកម្ពុជាលុបបំបាត់ជាបន្ទាន់ផងដែរនូវអនក្ខរភាព។ ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តខ្ពស់ក្នុងការធ្វើឱ្យសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា ឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងអភិវឌ្ឍន៍ប្រកបដោយសមធម៌ ដោយមានការតម្រង់ទិសច្បាស់លាស់សម្រាប់ពេលអនាគត និងមានចរិតគាំទ្រប្រជាជនក្រីក្រ និងអភិវឌ្ឍន៍ជនបទ។

ភាពក្រីក្រ គឺជាភាពនៃការខ្វះអាហារ ខ្វះសម្លៀកបំពាក់ ខ្វះទីជម្រក ខ្វះសេវាអប់រំ ខ្វះសេវាសុខភាព និងខ្វះប្រព័ន្ធគមនាគមន៍ ។ល។

ការអប់រំជាយុទ្ធសាស្ត្រជួយកាត់បន្ថយភាពក្រីក្រ ព្រោះការអប់រំនឹងធ្វើឱ្យប្រជាពលរដ្ឋមានចំណេះដឹង និងជំនាញក្នុងការ :

- បង្កើនផលិតភាពកសិកម្ម សិប្បកម្ម និងសេវាកម្ម
- ការការពារ និងថែរក្សាសុខភាព
- ប្រកបការងាររកប្រាក់ចំណូល
- ទំនាក់ទំនងក្នុងសហគមន៍ប្រកបដោយភាពសុខសាន្ត

### ១.៣.២. ការអប់រំកុមារតូច

ក). ដំណាក់ការលូតលាស់របស់កុមារ

ដំណាក់កាលនៃការលូតលាស់របស់កុមារ គឺ :

- ទារកអាយុពី 0ខែ-១២ខែ (១ឆ្នាំ)
- កុមារវ័យដំបូងពី ១ឆ្នាំ-៦ឆ្នាំ
- វ័យកុមារភាពពី ៦ឆ្នាំ-១២ឆ្នាំ
- កុមារវ័យជំទង់អាយុពី ១២ឆ្នាំ-ក្រោម១៨ឆ្នាំ

ខ). ការអប់រំកុមារតូចក្នុងដំណាក់កាលដំបូង

ការគាំពារ និងការអភិវឌ្ឍកុមារវ័យដំបូង ពិតជាមានសារប្រយោជន៍ខ្លាំងណាស់ ព្រោះវាផ្តល់ផលជាវិជ្ជមានលើកុមារ ជាពិសេសលើការអភិវឌ្ឍផ្នែកខួរក្បាល ដែលជាទូទៅការអភិវឌ្ឍផ្នែកខួរក្បាលនេះ វាលូតលាស់យ៉ាងឆាប់រហ័សនៅក្នុងខែ និងឆ្នាំដំបូងរបស់កុមារ។

កង្វះការយកចិត្តទុកដាក់ក្នុងការគាំពារកុមារតូច គឺនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានឥតឈប់ឈរទៅលើកុមារ ដែលអាចនាំឱ្យមានការខូចខាតលើសពីអ្វីដែលយើងបានគិតទុក។

ជាការសំខាន់ណាស់ដែលឪពុកម្តាយ អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សាត្រូវយកចិត្តទុកដាក់លើកទឹកចិត្ត និងត្រូវនិយាយលេងជាមួយកូនតាមដែលអាចធ្វើទៅបាន។

គ). គំនិតសំខាន់ៗជួយជំរុញដល់ការអភិវឌ្ឍកុមារតូច

- ការពារកុមារឱ្យរួចផុតពីគ្រោះថ្នាក់ដល់រាងកាយ និងស្មារតី
- ផ្តល់អាហារូបត្ថម្ភ និងការថែទាំសុខភាពឱ្យបានគ្រប់គ្រាន់
- ផ្តល់ថ្នាំបង្ការឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា
- ផ្តល់ភាពស្និទ្ធស្នាលជាមួយកុមារ
- ផ្តល់ឱកាសឱ្យកុមាររកនឹកគិតស្រាវជ្រាវរកពាក្យដែលគេចង់ប្រើ
- យកចិត្តទុកដាក់ចំពោះការប្រើប្រាស់ភាសា (ពាក្យនិយាយស្តី) ជាមួយកុមារ
- យកចិត្តទុកដាក់ និងគាំទ្រក្នុងការទទួលនូវសមត្ថភាពថ្មី ការអភិវឌ្ឍជំនាញ ភាសា និងការគិត
- សង្កេតលើឥរិយាបថរបស់កុមារ
- ផ្តល់ឱកាសឱ្យកុមារបានលេងកំសាន្ត។

ឃ). សារប្រយោជន៍នៃការអប់រំកុមារតូច

មធ្យោបាយសំខាន់ដែលជួយកុមារឱ្យមានការអភិវឌ្ឍល្អ គឺការបញ្ជូនកូនទៅថ្នាក់មត្តេយ្យនៅពេលគេមានអាយុចាប់ពី៣ទៅ៥ឆ្នាំ។ ការបញ្ជូនកុមារឱ្យទៅរៀននៅថ្នាក់មត្តេយ្យមានសារប្រយោជន៍ជាច្រើនដូចជា :

- ជំរុញឱ្យមានការអភិវឌ្ឍខាងរាងកាយ ប្រាជ្ញាស្មារតី អារម្មណ៍ និង សង្គមរបស់កុមារ
- លើកទឹកចិត្តកុមារឱ្យមានការត្រៀមទុកជាមុន សម្រាប់ការចូលរៀនសាលាបឋមសិក្សា
- កុមារបានចូលរៀននៅថ្នាក់មត្តេយ្យ និងមានសកម្មភាពសិក្សានៅសាលាបឋមសិក្សាបានល្អជាងកុមារដែលមិនបានឆ្លងកាត់ការរៀនសូត្រនៅថ្នាក់មត្តេយ្យ
- បង្កភាពងាយស្រួលក្នុងការចុះឈ្មោះចូលរៀនថ្នាក់ទី១ នៅពេលកុមារគ្រប់អាយុ៦ឆ្នាំ ឬយ៉ាងទាបបំផុត ៧០ខែ
- ជួយកាត់បន្ថយអត្រារៀនត្រួតថ្នាក់ និងបោះបង់ការសិក្សានៅថ្នាក់បឋមសិក្សា
- ផ្តល់ឱកាសឱ្យកុមារគ្រប់រូបទទួលបាននូវសិទ្ធិអប់រំ និងការអភិវឌ្ឍ

## ១.៣.៣. កត្តាសំខាន់ៗពាក់ព័ន្ធនឹងគុណភាពនៃការអប់រំ

ដើម្បីឱ្យការអប់រំមានគុណភាពល្អប្រសើរ លុះត្រាតែ :

- សិស្ស : កុមារមានសុខភាពល្អ ឧស្សាហ៍ព្យាយាម មករៀនទៀងទាត់ មានសីលធម៌រស់នៅល្អ សហការរៀនសូត្រ ចេះជួយពន្យល់មិត្តភក្តិ ទើបលទ្ធផលសិក្សាបានល្អប្រសើរ
- គ្រូបង្រៀន : គ្រូត្រូវមានគុណភាព បែងចែកគ្រូបង្រៀនតាមកម្រិត និងជំនាញ មានការបំប៉នសមត្ថភាពគ្រូបង្រៀនជាប្រចាំ អធិការកិច្ចគ្រូ គាំទ្រ និងលើកទឹកចិត្តគ្រូ បង្រៀនតាមកម្មវិធីត្រឹមត្រូវ និងមានសម្ភារៈបង្រៀនគ្រប់គ្រាន់ ព្រមទាំងគ្រូមានមនសិការ និងសីលធម៌វិជ្ជាជីវៈខ្ពស់
- ការគ្រប់គ្រងសាលារៀន : មានរចនាសម្ព័ន្ធគ្រប់គ្រងត្រឹមត្រូវ (គណៈគ្រប់គ្រងសាលារៀន គណៈកម្មការកម្រងសាលា គណៈកម្មការទ្រទ្រង់សាលា...) ដោយមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋមានទំនាក់ទំនងល្អ ជំរុញការអនុវត្តផែនការរបស់គណៈកម្មការ មានការប្រជុំទៀងទាត់ និងមានប្រព័ន្ធតាមដានត្រួតពិនិត្យច្បាស់លាស់
- បរិស្ថានសាលារៀន : មានអគារសិក្សា និងថ្នាក់រៀនស្អាត មានសោភ័ណភាពល្អ មានទីធ្លាសម្រាប់សិស្សលេងសមរម្យ មានរបង ដងទង់ជាតិ រុក្ខជាតិ សួនផ្កា សួនច្បារ បង្គន់អនាម័យ ប្រព័ន្ធទឹកស្អាត ទីធ្លាកីឡាគ្រប់គ្រាន់ និងមានសុវត្ថិភាពល្អ
- អាជ្ញាធរមូលដ្ឋាន : មានការគាំទ្រ និងចូលរួមសកម្មភាព អភិវឌ្ឍន៍សាលារៀន ចូលរួមក្នុងការកសាងផែនការ និងគ្រប់គ្រងថវិកា តាមដានការប្រើប្រាស់ថវិកា និងចូលរួមវាយតម្លៃគុណភាពអប់រំជាប្រចាំ
- សហគមន៍ មាតាបិតា អាណាព្យាបាល និងអ្នកគ្រប់គ្រងសិស្ស : ត្រូវជំរុញកុមារឱ្យមកសាលារៀន គាំទ្រ និងចូលរួមសកម្មភាពអភិវឌ្ឍន៍សាលារៀន ចូលរួមក្នុងការកសាងផែនការ និងចូលរួមវាយតម្លៃគុណភាពអប់រំជាប្រចាំ។

## ១.៤. សមភាពយេនឌ័រ

### ១.៤.១. ទស្សនៈទូទៅនៃយេនឌ័រ

#### ក). ភេទ និងយេនឌ័រ

**ក.១). និយមន័យភេទ**

ភេទ គឺសំដៅលើភាពខុសគ្នាតាមធម្មជាតិខាងលក្ខណៈជីវសាស្ត្រ ដែលកំណត់មនុស្សណាមួយជាបុរស និងស្ត្រី។ ភាពខុសគ្នាផ្នែកជីវសាស្ត្រនេះមិនបានកំណត់អំពីមូលហេតុ ដែលនាំឱ្យស្ត្រី និងបុរសមានតួនាទីខុសគ្នាក្នុងសង្គមទេ។

**ក.២). និយមន័យយេនឌ័រ**

យេនឌ័រ គឺជាផ្នត់គំនិត និងការប្រព្រឹត្តរបស់សង្គម គ្រួសារ សហគមន៍ ឬស្ថាប័នទៅលើក្មេងស្រី ឬក្មេងប្រុស ស្ត្រី ឬបុរស ដែលមានទំនាក់ទំនងទៅនឹងការបែងចែកតួនាទី មុខងារ ការទទួលបានសិទ្ធិអំណាច ភារកិច្ច។ ចំណុចទាំងនេះ អាចមានលក្ខណៈ និងតម្លៃខុសៗគ្នាទៅតាមតំបន់ វប្បធម៌ ប្រពៃណីនីមួយៗ។

ដោយផ្នត់គំនិត និងការប្រព្រឹត្តទាំងនេះបានកើតឡើងដោយសារសង្គម សហគមន៍ ឬស្ថាប័ន ហេតុនេះយេនឌ័រក៏អាចកែលំអ និងផ្លាស់ប្តូរបាន ក៏ដោយសារសង្គម សហគមន៍ ឬស្ថាប័នផងដែរ។ ការផ្លាស់ប្តូរ ឬកែលំអត្រូវធ្វើឡើងចំពោះតែផ្នត់គំនិត និងការប្រព្រឹត្តណាដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងតម្លៃរបស់មនុស្សទាំងស្ត្រី និងបុរស។

ឧទាហរណ៍

ផ្នត់គំនិតដែលមិនផ្តល់ឱកាសឱ្យក្មេងស្រីរៀនសូត្រអាចនាំឱ្យស្ត្រីភាគច្រើនមានការអប់រំទាប មិនសូវមានសេចក្តីក្លាហាន និងងាយរងនូវការបោកបញ្ឆោតជាដើម។ ចំណុចអវិជ្ជមានទាំងនេះ សង្គមត្រូវធ្វើការកែលំអ និងផ្លាស់ប្តូរនូវទស្សនៈ និងការប្រព្រឹត្តទាំងនេះ តាមរយៈការជំរុញ និងផ្តល់ឱកាសឱ្យកូនប្រុស និងកូនស្រីទទួលបាននូវការអប់រំ ទំនុកបម្រុង និងបីបាច់ដូចៗគ្នា។

**ការសង្ខេបអំពីភេទ និងយេនឌ័រ**

| ភេទ | យេនឌ័រ |
|---|---|
| កត្តា ឬល័ក្ខខ័ណ្ឌជីវសាស្ត្រពីកំណើត | កត្តា ឬល័ក្ខខ័ណ្ឌសង្គមមិនមែនពីកំណើត |
| មិនអាចកែប្រែបាន | អាចកែប្រែបាន |
| ឧទាហរណ៍<br>១. ស្ត្រីអាចបង្កើតកូនបាន<br>២. បុរសមានមេជីវិតឈ្មោល | ឧទាហរណ៍<br>១. ស្ត្រី និងបុរសអាចធ្វើជាវិស្វករ<br>២. ស្ត្រី និងបុរសអាចដាំស្ល |

២). តួនាទីយេនឌ័រ

ដោយសារយេនឌ័រ គឺកើតឡើងដោយការកំណត់ និងការរំពឹងទុក ទាំងការបែងចែកការងារ ការទទួលខុសត្រូវ តួនាទី សិទ្ធិអំណាចនានាទៅលើក្មេង ប្រុស ឬក្មេងស្រី បុរស ឬស្ត្រីខុសៗគ្នា គេសង្កេតឃើញថា តួនាទី ឬប្រភេទការងារផ្សេងៗរបស់បុរស និងស្ត្រីនៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះ ក៏មានលក្ខណៈខុសៗគ្នាដែរ។ ជាក់ស្តែងជារៀងរាល់ថ្ងៃ ស្ត្រីភាគច្រើនជាអ្នកធ្វើការងារដែលពុំមានកម្រៃ ដូចជាការងារផ្ទះសម្បែង ការថែទាំគ្រួសារ រីឯបុរសត្រូវបានមនុស្សភាគច្រើនក្នុងសង្គម គិតថាជាអ្នកធ្វើការងារ ដើម្បីរកប្រាក់កម្រៃចិញ្ចឹម និងផ្គត់ផ្គង់គ្រួសារ។

បច្ចុប្បន្ន សង្គម សហគមន៍ និងគ្រួសារភាគច្រើននៅតែចាត់ទុកថា ការងារផ្ទះសម្បែង ឬការងារមេផ្ទះ និងការថែទាំគ្រួសារជាការងារគ្មានតម្លៃ និងជាការងារកំប៉ិកកំប៉ុក តែតាមពិតការងារទាំងនេះត្រូវការការព្យាយាមអត់ធ្មត់ និងចំណាយពេលវេលាច្រើន។ ម្យ៉ាងវិញទៀត រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ថាការងារផ្ទះមានតម្លៃស្មើគ្នា នឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ។

ពេលខ្លះ ស្ត្រីអាចរកប្រាក់ចំណូល និងធ្វើការងារផ្ទះសម្បែង ក្នុងពេលតែមួយបាន ដូចជា លក់កវ៉ាន់ នំ ចំណីឬចិញ្ចឹមសត្វ ឬដាំដំណាំរួមផ្សំ។ល។ ទន្ទឹមនឹងនេះ ស្ត្រីបានចូលរួមក្នុងការងារសហគមន៍ ដូចជាការងាររៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋាន ចូលរួមក្នុងគណៈកម្មការនានា ក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងភូមិជាដើម ប៉ុន្តែពួកគេមិនសូវមានតួនាទីជាអ្នកដឹកនាំ និងគ្រប់គ្រងលើការងារទាំងនោះទេ។

តាមពិតស្ត្រី និងបុរសអាចធ្វើការងារគ្រប់ប្រភេទបានដូចគ្នា (ការងារមានកម្រៃ ការងារគ្មានកម្រៃ និងការងារសហគមន៍) លើកលែងតែតួនាទីផ្នែកភេទ ស្ត្រី និងបុរសមិនអាចបំពេញតួនាទីដូចគ្នា ដូចជា ស្ត្រីជាអ្នកពពោះ និងបុរសជាអ្នកផ្តល់មេជីវិត។ ការងារទាំងអស់នេះមានតម្លៃ និងមានសារៈសំខាន់ដូចៗគ្នាមានទំនាក់ទំនង និងជួយបំពេញឱ្យគ្នាទៅវិញទៅមក ដោយមិនអាចកាត់ផ្តាច់ការងារណាមួយបានឡើយ។ ការជួយរំលែកការងារទៅវិញទៅមកនឹងនាំមកនូវ :

- ការឱ្យតម្លៃដល់គ្រប់សមាជិកក្នុងក្រុមគ្រួសារ និងសង្គម
- បង្កើនសុភមង្គលក្នុងគ្រួសារ និងធ្វើឱ្យសង្គមមានសុខដុមរមនា
- ចំណេញពេលវេលាក្នុងការប្រកបមុខរបរ ឬបំពេញការងារ
- ការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងជួយលើកកម្ពស់ជីវភាពក្នុងគ្រួសារ។

ចំពោះការងារសហគមន៍ត្រូវជំរុញ និងតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មទាំងស្ត្រី និងបុរស ដើម្បីធ្វើសេចក្តីសម្រេច និងភាពជាម្ចាស់ក្នុងការអភិវឌ្ឍន៍មូលដ្ឋាន និងដោះស្រាយតម្រូវការអាទិភាពរបស់ពួកគេ។

៣). តម្រូវការយេនឌ័រ

ដោយសារតែទំនាក់ទំនងតួនាទី និងសិទ្ធិអំណាចដែលសង្គម សហគមន៍ និងគ្រួសារបានផ្តល់ដល់ស្ត្រី បុរសមានលក្ខណៈខុសគ្នា សេចក្តីត្រូវការរបស់ពួកគេក៏មានលក្ខណៈខុសគ្នាទៅតាមនោះផងដែរ។ ដូច្នេះ ការយល់ដឹង

និងវិភាគបែងចែកឱ្យបានច្បាស់អំពីតម្រូវការយេនឌ័រ មានសារសំខាន់ជួយឱ្យកម្មវិធី គម្រោង និងផែនការអភិវឌ្ឍន៍នានាបានឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ស្ត្រី និងបុរសនៅក្នុងសហគមន៍ និងមូលដ្ឋាន ។

គ.១). តម្រូវការយេនឌ័រចំពោះមុខ

ដោយសារតួនាទីយេនឌ័រកំណត់ឡើងដោយសង្គម និងតម្រូវការធម្មជាតិរបស់ស្ត្រីមានតម្រូវការមួយចំនួនពាក់ពន្ធ័នឹងជីវភាព និងការងារប្រចាំថ្ងៃ ដូចជា ទឹកស្អាត បង្គន់អនាម័យ អនាម័យ ថ្នាក់អក្ខរកម្ម មណ្ឌលសុខភាព ជំនាញបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំ ឥណទានសម្រាប់ប្រកបមុខរបរ ។ល ។

បុរសក៏មានតម្រូវការទាំងនេះដូចស្ត្រីដែរ ដោយបុរសមិនសូវបានចូលរួមធ្វើការងារផ្ទះសម្បែង ការថែរក្សាគ្រួសារ ទើបពួកគាត់មិនសូវបានគិតដល់តម្រូវការ ខាងលើនេះ ។ លើសពីនេះ បុរសមានតម្រូវការទាក់ទងនឹងការជួយសំរាលដល់ការងាររបស់ពួកគាត់ដូចជា ម៉ាស៊ីនបូមទឹក ម៉ាស៊ីនភ្ជួររាស់ ម៉ាស៊ីនបោកស្រូវ ឬបច្ចេកវិជ្ជាទំនើប១ ។ល ។

តម្រូវការទាំងអស់ខាងលើនេះ គឺជាតម្រូវការចំពោះមុខរបស់ស្ត្រី និងបុរស ។ ការវិភាគ និងការធ្វើផែនការដោយយកចិត្តទុកដាក់លើតម្រូវការចំពោះមុខទាំងនេះ មានភាពចាំបាច់ណាស់ ដើម្បីធានាថារាល់កម្មវិធី និងគម្រោងនានាបានបំពេញនូវតម្រូវការពិតប្រាកដរបស់ស្ត្រី បុរស និងកុមារ ក្នុងការអាចកែប្រែស្ថានភាពជីវភាពបានប្រសើរជាងមុន ។

គ.២). តម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ

ផ្អែកលើស្ថានភាពបច្ចុប្បន្ន ដោយស្ត្រីមានចំនួនតិចក្នុងជួរជាអ្នកដឹកនាំនៅគ្រប់លំដាប់ថ្នាក់ ដូចនេះស្ត្រីនៅមានតម្រូវការជាពិសេស ដើម្បីឱ្យមានឱកាសទទួលបាននូវតួនាទី ឋានៈ មានសិទ្ធិអំណាចជាអ្នកដឹកនាំ និងអ្នកធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិត ដូចជា នៅក្នុងសភាជាតិ រាជរដ្ឋាភិបាល អ្នកដឹកនាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកដឹកនាំភូមិ ។ល ។ ដែលទាំងអស់នេះ គឺជាតម្រូវការជាយុទ្ធសាស្ត្រយេនឌ័រ ។

បុរស ក៏មានតម្រូវការនេះដែរ ប៉ុន្តែសព្វថ្ងៃ បុរសមានតួនាទីជាអ្នកដឹកនាំភាគច្រើននៅគ្រប់លំដាប់ថ្នាក់ និងមានឱកាសច្រើនក្នុងការចូលរួមជាអ្នកធ្វើសេចក្តីសម្រេចនៅគ្រប់លំដាប់ថ្នាក់តាំងពីគ្រួសាររហូតដល់សហគមន៍ និងសង្គមជាតិ ។

ការដោះស្រាយតម្រូវការយេនឌ័រជាយុទ្ធសាស្ត្រ គឺធ្វើឡើងតាមរយៈ ការបង្កើត ឬកែប្រែគោលនយោបាយសម្រាប់កែលំអឋានៈ និងតួនាទីស្ត្រី និងលុបបំបាត់នូវរាល់ការរើសអើងលើស្ត្រី និងកុមារ ។ ជាទូទៅដំណោះស្រាយនេះច្រើនទាក់ទងទៅនឹងគោលការណ៍សមភាព និងសមធម៌ ដែលអាចធ្វើឱ្យស្ត្រី និងកុមារីមានឱកាសស្មើនឹងបុរស និងកុមារា ក្នុងការ :

- ទទួលបានការបណ្តុះបណ្តាល និងការអប់រំ
- ធ្វើសេចក្តីសម្រេច

- ទទួលបានប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នា
- ទទួលបានសិទ្ធិកាន់កាប់ដីធ្លី និងទ្រព្យសម្បត្តិដទៃទៀត
- ទទួលបានសិទ្ធិគ្រប់គ្រងលើធនធានផ្សេងៗ និង
- ចូលរួមក្នុងដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ។ល ។

## ឃ). សមភាពយេនឌ័រ និងសមធម៌យេនឌ័រ

### ឃ.១). សមភាពយេនឌ័រ

សមភាពយេនឌ័រ គឺសំដៅលើភាពគ្មានការរើសអើង ដែលប្រកាន់លើភេទណាមួយ (ប្រុស ឬស្រី) នៅក្នុងការបែងចែកធនធាន ឱកាស សិទ្ធិ ផលប្រយោជន៍ ឬនៅក្នុងការទទួលសេវានានា។ សមភាពយេនឌ័រអាចកើតមានតាមរយៈ ការផ្តល់ឱកាសស្មើគ្នា ឬការទទួលបាននូវផលប្រយោជន៍របស់បុរស និងស្ត្រីនៅក្នុងសហគមន៍ ស្ថាប័ន ឬគ្រួសារនានា។ ក្នុងន័យនេះ គឺសំដៅលើភាពស្មើគ្នាលើការចូលរួម ការទទួលបានការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចរវាងបុរស និងស្ត្រីទៅលើធនធាន ទ្រព្យសម្បត្តិ សេវាកម្ម និងសកម្មភាពផ្សេងៗនៅក្នុងកិច្ចការរបស់សហគមន៍សាធារណៈ ឬគ្រួសារ ។

សមភាពយេនឌ័រនៅថ្នាក់ឃុំ សង្កាត់មានដូចជា :

- ប្រជាពលរដ្ឋទាំងបុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការចូលរួមផ្តល់យោបល់លើការងារអភិវឌ្ឍន៍ និងការងារគ្រប់គ្រងឃុំ សង្កាត់
- កុមារា កុមារីគ្រប់រូបមានសិទ្ធិស្មើគ្នាក្នុងការទទួលបានសេវាអប់រំ និងអភិវឌ្ឍន៍
- ប្រជាពលរដ្ឋទាំងបុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍន៍ ។

### ឃ.២). សមធម៌យេនឌ័រ

សមធម៌យេនឌ័រ គឺជាដំណើរការនៃការប្រព្រឹត្តដោយយុត្តិធម៌ទៅលើស្ត្រី និងបុរសសំដៅឱ្យមានសមភាពយេនឌ័រ។ ដើម្បីធានាបាននូវភាពយុត្តិធម៌ត្រូវមានវិធានការសមស្រប ជួយកាត់បន្ថយឧបសគ្គរាំង ឬបំបាត់នូវគម្លាតរវាងស្ត្រី និងបុរស ដែលធ្វើឱ្យស្ត្រី ឬបុរសមិនអាចទទួលបានឋានៈ និងផលប្រយោជន៍ស្មើគ្នានៅក្នុងសង្គម។ ដូច្នេះសមធម៌យេនឌ័រសំដៅលើមធ្យោបាយ ដើម្បីទទួលបានសមភាពយេនឌ័រ ។

ឃុំ សង្កាត់អាចធ្វើឱ្យមានសមធម៌យេនឌ័រតាមមធ្យោបាយ :

- ការបង្កើត គ.ក.ន.ក ត្រូវមានសមាជិកយ៉ាងតិច៤០%ជាស្ត្រី
- ការប្រជុំនៅថ្នាក់ភូមិ ដើម្បីប្រមូលតម្រូវការសម្រាប់កសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ត្រូវមានស្ត្រីចូលរួមយ៉ាងតិច៣០%
- ការប្រជុំនៅថ្នាក់ភូមិ ដើម្បីប្រមូលតម្រូវការសម្រាប់កសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់អាចបែងចែកជាក្រុមបុរស ក្រុមស្ត្រី ឬក្រុមជនងាយរងគ្រោះ ដើម្បីផ្តល់ឱកាសឱ្យ

ក្រុមគោលដៅទាំងអស់បានលើកឡើងតម្រូវការជាអាទិភាពរបស់សហគមន៍ក្នុងការបញ្ចូលទៅផែនការឃុំ សង្កាត់

- កំណត់ឱ្យមានស្ត្រីយ៉ាងតិច ១រូបចូលរួមជាអ្នកដឹកនាំភូមិ
- ការកំណត់ឱ្យមានស្ត្រី១រូបចូលរួមជាជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់
- ការកំណត់ស្ត្រីជាអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

### ១.៤.២. ការបញ្ជ្រាបយេនឌ័រ

**ក). និយមន័យនៃការបញ្ជ្រាបយេនឌ័រ**

ការបញ្ជ្រាបយេនឌ័រ គឺជាយុទ្ធសាស្ត្រ ឬសកម្មភាពក្នុងការបញ្ចូលទូវបញ្ហា កង្វល់ និងតម្រូវការរបស់ស្ត្រី បុរស និងជនងាយរងគ្រោះទៅក្នុងគោលនយោបាយ ផែនការ កម្មវិធី និងគម្រោងនានា ដោយមានទាំងធនធាន និងមធ្យោបាយសម្រាប់គាំទ្រដល់ដំណើរការអនុវត្តនៃការបញ្ជ្រាប។

**ខ). ធាតុសំខាន់ៗក្នុងការបញ្ជ្រាបយេនឌ័រ**

ធាតុសំខាន់ៗក្នុងការបញ្ជ្រាបយេនឌ័រមាន :

- បង្កើនការយល់ដឹងពីយេនឌ័រ
- ប្រព័ន្ធស្ថិតិ និងព័ត៌មានទាក់ទងនឹងយេនឌ័រ
- វិភាគបញ្ហាយេនឌ័រ
- ស្វែងរកការគាំទ្រមតិ
- បញ្ចូលបញ្ហាយេនឌ័រក្នុងគោលនយោបាយ ផែនការ កម្មវិធី និងស្ថាប័ន
- យន្តការ និងបណ្តាញការងារយេនឌ័រ

**ខ.១). បង្កើនការយល់ដឹងពីយេនឌ័រ**

ការបញ្ជ្រាបយេនឌ័រអាចធ្វើទៅបានពេញលេញ និងរលូន លុះត្រាតែសង្គម ស្ថាប័ន សហគមន៍ ឃុំ សង្កាត់ និងគ្រួសារបានយល់ដឹងជ្រួតជ្រាប និងទទួលស្គាល់ថា បញ្ហាយេនឌ័រ មូលហេតុ ផលប៉ះពាល់ ទំហំ និងឧបសគ្គនានារបស់ក្មេងប្រុស ក្មេងស្រី ស្ត្រី បុរស ដែលកើតមកពីយេនឌ័រ។

ក្រុមប្រឹក្សាឃុំ សង្កាត់ អាចធ្វើការបង្កើនការយល់ដឹងពីយេនឌ័រ តាមរយៈ:

- ផ្សព្វផ្សាយ ឬរៀបចំកិច្ចប្រជុំ ឬវគ្គបណ្តុះបណ្តាលដល់សមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ គ.ក.ន.ក ថ្នាក់ដឹកនាំភូមិ ឬសហគមន៍ឱ្យយល់ដឹងអំពីយេនឌ័រ បញ្ហាយេនឌ័រ ដែលកើតមាននៅក្នុងសហគមន៍ និងក្នុងសង្គម
- ផ្សព្វផ្សាយ និងអប់រំដល់ក្រុមបុរស និងក្រុមអ្នកធ្វើសេចក្តីសម្រេចនៅក្នុងគ្រួសារ ឬសហគមន៍ ឱ្យយល់ដឹងអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ
- ចុះអប់រំ និងផ្សព្វផ្សាយដល់សហគមន៍ ដើម្បីកាត់បន្ថយ ផ្លាស់ប្តូរ ឬកែលម្អឥរិយាបថ និងការប្រព្រឹត្តនានា ដែលនាំឱ្យមានបញ្ហាយេនឌ័រ ដូចជា អំពើហិង្សាលើស្រី និងកុមារ ការអប់រំរបស់ក្មេងស្រី ការចែករំលែក និងឱ្យតម្លៃលើការងារផ្ទះសម្បែង

## ១.២). ព័ត៌មាន និងប្រព័ន្ធទិន្នន័យទាក់ទងនឹងបញ្ហាយេនឌ័រ

ការរៀបចំឱ្យមានព័ត៌មាន និងប្រព័ន្ធទិន្នន័យទាក់ទងនឹងបញ្ហាយេនឌ័រ ធ្វើឱ្យមានភាពងាយស្រួលក្នុងការរៀបចំយុទ្ធសាស្ត្រ កម្មវិធី និងផែនការសម្រាប់ឆ្លើយតប និងជួយដោះស្រាយបញ្ហាយេនឌ័រ។ ជាងនេះទៅទៀត ការរៀបចំឱ្យមានព័ត៌មានជាក់លាក់ និងប្រព័ន្ធទិន្នន័យទាក់ទងនឹងបញ្ហាយេនឌ័រ គឺជាកត្តាសំខាន់ក្នុងការបង្ហាញឱ្យអ្នកពាក់ព័ន្ធ និងអ្នកដែលមានសមត្ថកិច្ចអាចធ្វើការគាំទ្រ និងដោះស្រាយបាន។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចរៀបចំព័ត៌មាន និងប្រព័ន្ធទិន្នន័យទាក់ទងនឹងយេនឌ័រ តាមរយៈ :

- ប្រមូល កត់ត្រា វិភាគ និងបញ្ចូលបញ្ហាយេនឌ័រ ស្ត្រី កុមារ និងជនងាយរងគ្រោះទៅក្នុងដំណើរការធ្វើបច្ចុប្បន្នភាពឯកសារស្ថានភាពឃុំ សង្កាត់
- កត់ត្រាជាប្រចាំនូវរាល់បញ្ហាយេនឌ័រ ស្ត្រី កុមារ និងជនងាយរងគ្រោះនានា ដែលបានលើកឡើងក្នុងកិច្ចប្រជុំនានា ឬតាមការរាយការណ៍របស់ជនរងគ្រោះ ឬតំណាងរបស់ខ្លួន។

## ១.៣). វិភាគបញ្ហាយេនឌ័រ

ការវិភាគបញ្ហាយេនឌ័រនៅក្នុងសង្គម ឬសហគមន៍ គឺជាចំណុចចាប់ផ្តើម ដើម្បីឱ្យដឹងច្បាស់អំពីបញ្ហា មូលហេតុ ផលប៉ះពាល់ ឧបសគ្គ ប្រភេទ ទំហំ និងកម្រិត ដែលកើតឡើងមកលើបុរស ស្ត្រី ក្មេងប្រុស ក្មេងស្រី និងជនងាយរងគ្រោះនៅក្នុងគ្រួសារ សហគមន៍ សង្គម ក៏ដូចជានៅក្នុងស្ថាប័នគ្រប់គ្រងនានា។ ការវិភាគយេនឌ័រ គឺត្រូវធ្វើឡើងតាមការស្វែងយល់ និងពិនិត្យលើតួនាទីយេនឌ័រ តម្រូវការយេនឌ័រ ការទទួលបានការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចលើធនធាន និងផលកម្រៃនានារបស់ស្ត្រី និងបុរស ក្មេងប្រុស និងក្មេងស្រី ព្រមទាំងវិភាគលើឱកាស ឧបសគ្គ និងកត្តារារាំងនានា ដែលកើតឡើងពីវប្បធម៌ ទម្លាប់ ការដឹកនាំគ្រប់គ្រង គោលនយោបាយ និងច្បាប់នានានៅក្នុងគ្រួសារសហគមន៍ សង្គម និងស្ថាប័ន។

ក្រុមប្រឹក្សាឃុំ សង្កាត់ អាចធ្វើការវិភាគយេនឌ័រ តាមរយៈ

- ពិនិត្យលើមូលហេតុ និងឧបសគ្គ ដែលបណ្តាលឱ្យក្មេងស្រីពុំសូវមានឱកាសពេញលេញក្នុងការសិក្សានៅកម្រិតខ្ពស់
- ពិនិត្យលើមូលហេតុ និងឧបសគ្គ ដែលបណ្តាលឱ្យមានអំពើហិង្សាក្នុងគ្រួសារលើស្ត្រី និងកុមារ ការរំលោភសេពសន្ថវៈ
- ពិនិត្យលើមូលហេតុ និងឧបសគ្គ ដែលបណ្តាលមកពីការមានស្ត្រីតិចតួច ចូលរួមជាតំណាងតាមភូមិ ឬនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់
- ពិនិត្យលើមូលហេតុ និងឧបសគ្គ ដែលបណ្តាលឱ្យមានអត្រាមរណៈខ្ពស់របស់ម្តាយ និងទារកនៅពេលស្ត្រីសម្រាលកូន។

## ១.៤). ស្វែងរកការគាំទ្រមតិ

ការស្វែងរកការគាំទ្រមតិ គឺជាមធ្យោបាយមួយជួយឱ្យមានការលើកទឹកចិត្ត បង្កើនការប្តេជ្ញាចិត្ត ការយកចិត្តទុកដាក់ ការចែករំលែកព័ត៌មានអាចជួយឱ្យថ្នាក់ដឹកនាំ និងអ្នកពាក់ព័ន្ធបង្កើនការគាំទ្រ និងចូលរួមដោះស្រាយបញ្ហាយេនឌ័រ។

ការស្វែងរកការគាំទ្រមតិអាចធ្វើឡើងតាមរយៈ :

- វេទិកាសម្រាប់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកដឹកនាំភូមិអាចជួយបង្កើនការយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាយេនឌ័រ ស្ត្រី និងកុមារនៅក្នុងសហគមន៍
- ការប្រជុំប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីពិនិត្យ និងដោះស្រាយបញ្ហាទាក់ទងនឹងបញ្ហាយេនឌ័រ
- ប្រជុំ និងបង្ហាញនូវបញ្ហាយេនឌ័រ ស្ត្រី និងកុមារ ដល់ថ្នាក់ដឹកនាំ និងអ្នកពាក់ព័ន្ធនានា ដើម្បីស្វែងរកការគាំទ្រ ការឆ្លើយតប និងការដោះស្រាយ។

## ១.៥). បញ្ចូលបញ្ហាយេនឌ័រក្នុងគោលនយោបាយ ផែនការ កម្មវិធី និងស្ថាប័ន

បញ្ចូលបញ្ហាយេនឌ័រក្នុងគោលនយោបាយ ផែនការ កម្មវិធី និងស្ថាប័ន គឺជាមូលដ្ឋានគ្រឹះនៃការធ្វើឱ្យមានការឆ្លើយតប និងដោះស្រាយបញ្ហាយេនឌ័រ។ ការប្រមូល និងវិភាគបញ្ហាយេនឌ័របានស៊ីជម្រៅអាចជួយបង្កើនប្រសិទ្ធភាព និងទម្រង់ទិសដល់ការដោះស្រាយបញ្ហាយេនឌ័រនៅក្នុងការរៀបចំគោលនយោបាយ ផែនការ កម្មវិធីរបស់ស្ថាប័ន។ ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ចូលបញ្ហាយេនឌ័រទៅក្នុងគោលនយោបាយ ផែនការឃុំ សង្កាត់ តាមរយៈ:

- ការបញ្ចូលបញ្ហាអាទិភាពយេនឌ័រ ស្ត្រី និងកុមារ ដែលបានលើកឡើងដោយសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ព្រមទាំងកំណត់ឱ្យមានធនធាន និងមូលនិធិសមស្របសម្រាប់ដោះស្រាយ
- ចូលរួមនៅក្នុងកិច្ចប្រជុំ និងដំណើរការរៀបចំផែនការ និងថវិកានានារបស់អ្នកពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលនូវបញ្ហាយេនឌ័រ ស្ត្រី និងកុមារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ១.៦). យន្តការ និងបណ្តាញការងារយេនឌ័រ

ការបង្កើតយន្តការបណ្តាញការងារយេនឌ័រ គឺជាចំណែកសំខាន់មួយក្នុងការជួយលើកទឹកចិត្ត តាមដានត្រួតពិនិត្យ ជំរុញ និងសម្របសម្រួលជាមួយគ្រប់បណ្តាលអ្នកពាក់ព័ន្ធនានា ក្នុងការគាំទ្រដល់ការដោះស្រាយបញ្ហាយេនឌ័រ ស្ត្រី កុមារ និងជនងាយរងគ្រោះ។ យន្តការគាំទ្រការងារយេនឌ័រនៅថ្នាក់ក្រោមជាតិមានដូចជា :

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររាជធានី ខេត្ត
- មន្ទីរ និងការិយាល័យកិច្ចការនារីរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ក្រុមការងារ ឬមន្ត្រីបង្គោលយេនឌ័រតាមមន្ទីរ ស្ថាប័នពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ
- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់។

ផ្អែកតាមយន្តការ និងបណ្តាញការងារទាំងនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចជំរុញ គាំទ្រ និងលើកទឹកចិត្តគ្រប់មធ្យោបាយសមស្របដល់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ និង គ.ក.ន.ក ដើម្បីឱ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់បំពេញមុខងារក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ១.៤.៣. សមភាពយេនឌ័រក្នុងវិស័យអប់រំ

សមភាពយេនឌ័រក្នុងវិស័យអប់រំ គឺជាការធ្វើឱ្យកុមារី និងកុមារាមានសិទ្ធិ និងឱកាសស្មើភាពគ្នាក្នុងការទទួលបានការអប់រំ។

**ក). សូចនាករបង្ហាញពីសមភាពយេនឌ័រក្នុងវិស័យអប់រំ**

- ចំនួនកុមារា និងកុមារីចុះឈ្មោះចូលរៀន
- ចំនួនកុមារា និងកុមារីចូលរៀនទៀងទាត់
- ចំនួនកុមារា និងកុមារីរៀនត្រួតថ្នាក់
- ចំនួនកុមារា និងកុមារីរៀនក្នុងភូមិសិក្សានីមួយៗ (មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ)
- អត្រាអក្ខរជន (ភាពចេះអក្សរ) របស់កុមារា កុមារី ស្ត្រី និងបុរស

**ខ). កត្តាសំខាន់ៗធ្វើឱ្យមានសមភាពយេនឌ័រក្នុងការអប់រំ**

កត្តាដែលធ្វើឱ្យមានសមភាពយេនឌ័រដល់ការអប់រំគឺ :

- សមភាពយេនឌ័រក្នុងការទទួលបានសេវាអប់រំ
- សមភាពយេនឌ័រក្នុងដំណើរការសិក្សា
- ការសិក្សាទទួលបានលទ្ធផលប្រកបដោយសមភាពយេនឌ័រ
- ការអភិវឌ្ឍប្រកបដោយសមភាពយេនឌ័រ

**ខ.១). សមភាពយេនឌ័រក្នុងការទទួលបានសេវាអប់រំ**

សមភាពយេនឌ័រក្នុងការទទួលបានសេវាអប់រំ គឺជាការផ្តល់ឱកាសស្មើភាពគ្នារវាងកុមារា និងកុមារី ដើម្បីទទួលបានការអប់រំទាំងអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ ឬការអប់រំមូលដ្ឋានផ្សេងៗទៀត។ ដើម្បីធ្វើឱ្យមានសមភាពយេនឌ័រក្នុងការទទួលបានសេវាអប់រំត្រូវ :

- សាលារៀនត្រូវស្ថិតនៅជិតលំនៅដ្ឋានរបស់កុមារ
- ពន្យល់ណែនាំមាតាបិតាសិស្សឱ្យយល់ពីសិទ្ធិ និងសារប្រយោជន៍នៃការបញ្ជូនកូនទៅរៀន
- ផ្ដល់ពេលវេលាឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យកុមារីបានចូលរៀនទៀងទាត់

## ១.២). សមភាពយេនឌ័រក្នុងដំណើរការសិក្សា

សមភាពយេនឌ័រក្នុងដំណើរការសិក្សា គឺជាដំណើរការសិក្សា ដែលសម្របសម្រួលទៅតាមរបៀបរៀនសូត្ររបស់កុមារី និងកុមារា ពិសេស ជៀសវាងនូវផ្នត់គំនិតលម្អៀងផ្នែកយេនឌ័រ។ ដើម្បីធ្វើឱ្យមានសមភាពយេនឌ័រក្នុងដំណើរការសិក្សាត្រូវ :

- បណ្ដុះបណ្ដាលអ្នករៀបចំកម្មវិធីសិក្សា គ្រូ និងអ្នកគ្រប់គ្រងឱ្យយល់ពីទស្សនៈយេនឌ័រ ដើម្បីឱ្យពួកគេអាចបញ្ចូលទស្សនៈយេនឌ័រទៅក្នុងការងាររបស់ពួកគេ
- ការបង្រៀនត្រូវយកចិត្តទុកដាក់ក្នុងការជួយដល់សិស្សក្រីក្រ សិស្សជនជាតិដើមភាគតិច និងជៀសវាងការរើសអើងចំពោះសិស្សស្រី
- បង្កើនសុវត្ថិភាពនៅក្នុងសាលារៀន ការធ្វើដំណើរមករៀន ជៀសវាងការប្រើទណ្ឌកម្ម អំពើហិង្សា ហើយសាលាត្រូវមានបង្គន់អនាម័យ ពិសេសសម្រាប់កុមារី
- តាមដានត្រួតពិនិត្យការសិក្សានៅក្នុងថ្នាក់ឱ្យបានទៀងទាត់ ដើម្បីធានាថាសមភាពយេឌ័រនៅក្នុងថ្នាក់ត្រូវបានអនុវត្ត។

## ១.៣). ការសិក្សាទទួលបានលទ្ធផលប្រកបដោយសមភាពយេនឌ័រ

ការសិក្សាទទួលបានលទ្ធផលប្រកបដោយសមភាពយេនឌ័រ គឺជាឱកាសស្មើភាពគ្នារវាងកុមារា និងកុមារីក្នុងការទទួលបាននូវលទ្ធផលសិក្សា ផ្អែកលើការខំប្រឹងប្រែងរបស់ពួកគេម្នាក់ៗ។ ដើម្បីធ្វើឱ្យការសិក្សាទទួលបានលទ្ធផលប្រកបដោយសមភាពយេនឌ័រត្រូវ :

- បង្កើតយន្តការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សម្នាក់ៗ ជៀសវាងភាពលម្អៀងយេនឌ័រ
- គ្រូត្រូវមានការជឿជាក់លើសមត្ថភាពទាំងសិស្សស្រី និងសិស្សប្រុស ដើម្បីផ្ដល់ការវាយតម្លៃប្រកបដោយយុត្តិធម៌ និងមិនលម្អៀង

## ១.៤). ការអភិវឌ្ឍប្រកបដោយសមភាពយេនឌ័រ

ការអភិវឌ្ឍប្រកបដោយសមភាពយេនឌ័រ គឺជាឱកាសរបស់បុរស ស្ត្រី កុមារា និងកុមារីក្នុងការទទួលបានធនធាន សេវា ការចូលរួម និងផលប្រយោជន៍ពីការអភិវឌ្ឍទាំងផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងនយោបាយ។ ដើម្បីធ្វើឱ្យការអភិវឌ្ឍប្រកបដោយសមភាពយេនឌ័រត្រូវ :

- ចលនាប្រជាពលរដ្ឋ ក្នុងការចូលរួមលើកកម្ពស់ស្ថានភាពយេនឌ័រ និងឱ្យតម្លៃស្ត្រីក្នុងសង្គម
- ការពារសិទ្ធិដល់ស្ត្រី និងកុមារី តាមរយៈ ច្បាប់ ការចូលរួមក្នុងសកម្មភាពនយោបាយ និងផ្ដល់តួនាទីជាអ្នកដឹកនាំដល់ស្ត្រី

- ការអភិវឌ្ឍត្រូវគិតទៅដល់សមភាពយេនឌ័រ ដើម្បីធានាថាលទ្ធផល និងផលប្រយោជន៍នៃការអភិវឌ្ឍ ដូចជា ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច អប់រំ និងសេវាសុខភាព។ល។ ដែលជួយទៅដល់ការលើកកម្ពស់ស្ថានភាពស្ត្រីប្រកបដោយសមភាព។

## ១.៤.៤. សមភាពយេនឌ័រក្នុងការអភិវឌ្ឍឃុំ សង្កាត់

ក). សូចនាករបង្ហាញពីសមភាពយេនឌ័រក្នុងការងារអភិវឌ្ឍន៍

- ព័ត៌មានទាក់ទងនឹងបញ្ហាស្ត្រី និងកុមារត្រូវបានប្រមូល និងវិភាគសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការឃុំ សង្កាត់
- ចំនួនបុរស និងស្ត្រីចូលរួមក្នុងដំណើរការកសាងផែនការ និងគ្រប់គ្រងគម្រោង
- ឱកាសនៃការផ្តល់យោបល់ និងការទទួលយកយោបល់របស់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រី
- ចំនួនបុរស និងស្ត្រី ដែលទទួលផលប្រយោជន៍ពីគម្រោង
- ផលប៉ះពាល់របស់គម្រោងទៅលើស្ថានភាពយេនឌ័រ

ខ). កត្តាសំខាន់ៗធ្វើឱ្យមានសមភាពយេនឌ័រក្នុងការអភិវឌ្ឍឃុំ សង្កាត់

កត្តាសំខាន់ៗ ដែលធ្វើឱ្យមានសមភាពយេនឌ័រក្នុងការអភិវឌ្ឍគឺ :

- សមភាពក្នុងការយល់ដឹងអំពីការងារអភិវឌ្ឍន៍ឃុំ សង្កាត់
- សមភាពក្នុងការចូលរួមក្នុងដំណើរការកសាងផែនការ
- សមភាពក្នុងការចូលរួមក្នុងការគ្រប់គ្រងគម្រោង
- សមភាពក្នុងការទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍ

ខ.១). សមភាពក្នុងការយល់ដឹងអំពីការងារអភិវឌ្ឍន៍ឃុំ សង្កាត់

ការយល់ដឹង និងការទទួលបានព័ត៌មានអំពីការងារអភិវឌ្ឍន៍ ជាកត្តាមួយសំខាន់ជួយឱ្យស្ត្រីមានឱកាសចូលរួមក្នុងការងារអភិវឌ្ឍន៍។ ដើម្បីឱ្យមានសមភាពក្នុងការយល់ដឹងអំពីការងារអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវ :

- លើកទឹកចិត្តឱ្យស្ត្រី ដែលជាសមាជិក គ.ឃ.ស ចូលរួមក្នុងការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍ ដូចជា ការប្រមូលទិន្នន័យភូមិ ដំណើរការកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ កម្មវិធីវិនិយោគឃុំ សង្កាត់ និងការគ្រប់គ្រងគម្រោង។ល។
- ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ ពិសេសស្ត្រីក្នុងការចូលរួមដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ កម្មវិធីវិនិយោគឃុំ សង្កាត់ ការសិក្សាគម្រោង ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោង
- បណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីសមភាពយេនឌ័រដល់អ្នកពាក់ព័ន្ធ និងសមាជិក គ.ឃ.ស ដើម្បីបង្កើនការយល់ដឹង និងបញ្ចូលទស្សនៈយេនឌ័រទៅក្នុងការងារអភិវឌ្ឍន៍របស់ពួកគេ។

### ១.២). សមភាពក្នុងការចូលរួមក្នុងដំណើរការកសាងផែនការ

ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ជាឱកាសមួយសំខាន់សម្រាប់ស្ត្រីលើកឡើង និងដាក់បញ្ចូលបញ្ហាយេនឌ័រ ស្ត្រី និងកុមារសម្រាប់ដោះស្រាយ ដូចនេះ ការចូលរួមរបស់ស្ត្រី ជាការរួមចំណែកមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅថ្នាក់ឃុំ សង្កាត់។ ដើម្បីឱ្យមានសមភាពក្នុងការចូលរួមក្នុងដំណើរការកសាងផែនការឃុំ សង្កាត់ត្រូវ :

- លើកទឹកចិត្តប្រជាពលរដ្ឋ ពិសេសស្ត្រីក្នុងការចូលរួមក្នុងដំណើរការប្រមូល និងវិភាគទិន្នន័យពាក់ព័ន្ធនឹងបញ្ហាស្ត្រី និងកុមារ ដើម្បីកំណត់តម្រូវការយេនឌ័រ
- លើកទឹកចិត្ត និងផ្ដល់ឱកាសឱ្យប្រជាពលរដ្ឋ ពិសេសស្ត្រីចូលរួមក្នុងដំណើរការកសាងផែនការឃុំ សង្កាត់ ដើម្បីផ្ដល់យោបល់ និងលើកឡើងអំពីតម្រូវការរបស់ស្ត្រី និងកុមារសម្រាប់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិយោគឃុំ សង្កាត់
- កំណត់ និងជ្រើសរើសគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវផ្ដោតយកចិត្តទុកដាក់ជាអាទិភាពក្នុងការដោះស្រាយបញ្ហា និងលើកកម្ពស់ស្ថានភាពស្ត្រី និងកុមារ ។

### ១.៣). សមភាពក្នុងការចូលរួមគ្រប់គ្រងគម្រោង

សមភាពក្នុងការចូលរួមគ្រប់គ្រងគម្រោងជាឱកាសមួយសម្រាប់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រីចូលរួមតាមដានត្រួតពិនិត្យប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានរបស់ខ្លួន និងពង្រឹងគណនេយ្យភាពក្នុងការគ្រប់គ្រងការងារអភិវឌ្ឍន៍នៅមូលដ្ឋាន។ ដើម្បីធ្វើឱ្យមានសមភាពក្នុងការចូលរួមគ្រប់គ្រងការងារអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវ :

- ផ្ដល់ឱកាសឱ្យប្រជាពលរដ្ឋទាំងបុរស និងស្ត្រីចូលរួមផ្ដល់យោបល់ និងអនុវត្តគម្រោង ដូចជា ការសិក្សាលទ្ធភាព និងដោះស្រាយផលប៉ះពាល់របស់គម្រោង
- លើកទឹកចិត្តប្រជាពលរដ្ឋទាំងបុរស និងស្ត្រីចូលរួមជាសមាជិកគណៈកម្មការគ្រប់គ្រងគម្រោង និងចូលរួមតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោង
- ផ្សព្វផ្សាយលទ្ធផលនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោងដល់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រី និងលើកទឹកចិត្តពួកគាត់ឱ្យចូលរួមដោះស្រាយបញ្ហា ។

### ១.៤). សមភាពក្នុងការទទួលផលប្រយោជន៍ពីការអភិវឌ្ឍ

សមភាពក្នុងការទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍ ជាលទ្ធផលមួយយ៉ាងសំខាន់ក្នុងការលើកកម្ពស់សមភាពយេនឌ័រ។ ផលប្រយោជន៍ដែលទទួលបានពីការអភិវឌ្ឍអាចឆ្លើយតបនឹងតម្រូវការចំពោះមុខ ឬតម្រូវការជាយុទ្ធសាស្ត្ររបស់យេនឌ័រ។ ដើម្បីធ្វើឱ្យមានសមភាពក្នុងការទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍឃុំ សង្កាត់ត្រូវ :

- បង្កើនការយល់ដឹងអំពីសមភាពយេនឌ័រដល់ប្រជាពលរដ្ឋ ដើម្បីជួយកាត់បន្ថយ និងលុបបំបាត់ការរើសអើងស្ត្រី អំពើហិង្សា និងការពារជនងាយរងគ្រោះ និងការពារស្ត្រី និងកុមារ

- ផ្តល់សេវាអប់រំ សុខភាព កិច្ចការពារ និងសេវាសង្គមនានាដល់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រី កុមារា និងកុមារីប្រកបដោយគុណភាព
- លើកកម្ពស់ជីវភាព និងស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រីប្រកបដោយការផ្លាស់ប្តូរជាវិជ្ជមាន
- លើកកម្ពស់សេរីភាព និងសមភាពក្នុងការចូលរួមសកម្មភាពសង្គម សេដ្ឋកិច្ច និងនយោបាយ ដើម្បីរួមចំណែកក្នុងការគ្រប់គ្រងឃុំ សង្កាត់ប្រកបដោយអភិបាលកិច្ចល្អ។

## ១.៥. កិច្ចការពារកុមារ

### ១.៥.១. សិទ្ធិជាមូលដ្ឋានរបស់កុមារ

ក). សិទ្ធិជាមូលដ្ឋានរបស់កុមារ

សិទ្ធិជាមូលដ្ឋានរបស់កុមារមាន ៖

- សិទ្ធិក្នុងការរស់រានមានជីវិត
- សិទ្ធិក្នុងការអភិវឌ្ឍ
- សិទ្ធិទទួលបានការការពារ
- សិទ្ធិក្នុងការចូលរួម

ខ). សិទ្ធិនានាដែលស្ថិតនៅសិទ្ធិជាមូលដ្ឋានរបស់កុមារ

ខ.១). សិទ្ធិក្នុងការរស់រានមានជីវិត

- សិទ្ធិមានជីវិតរស់នៅ
- សិទ្ធិមានឈ្មោះ និងមានសញ្ជាតិ
- សិទ្ធិទទួលបានសេវាសុខភាព
- សិទ្ធិទទួលបានការប្រើប្រាស់ទឹកប្រកបដោយសុវត្ថិភាព
- សិទ្ធិទទួលបានអនាម័យ
- សិទ្ធិទទួលបានទីជម្រក និងម្ហូបអាហារ
- សិទ្ធិទទួលបានការថែទាំ ជាពិសេសកុមារពិការ

ខ.២). សិទ្ធិក្នុងការអភិវឌ្ឍន៍

- សិទ្ធិទទួលបានការអប់រំចាំបាច់ដោយឥតបង់ថ្លៃនៅសាលារដ្ឋ (ថ្នាក់អប់រំមូលដ្ឋាន)
- សិទ្ធិលេងល្បែងកំសាន្ត
- សិទ្ធិជាសមាជិកក្នុងសហគមន៍

### ខ.៣). សិទ្ធិទទួលបានការការពារ

- សិទ្ធិទទួលបានការការពារពីការធ្វើអាជីវកម្មផ្លូវភេទ ឬការរំលោភ
- សិទ្ធិទទួលបានការការពារពីការរំលោភបំពានរាងកាយ និងស្មារតី
- សិទ្ធិទទួលបានការការពារពីការកេងប្រវ័ញ្ចពលកម្មកុមារ
- សិទ្ធិទទួលបានការការពារពីការជួញដូរ
- សិទ្ធិទទួលបានការការពារពីផលវិបាកនៃសង្គ្រាម

### ខ.៤). សិទ្ធិក្នុងការចូលរួម

- សិទ្ធិក្នុងការចូលរួមមតិយោបល់
- សិទ្ធិមានសេរីភាពក្នុងការសម្តែងមតិ
- សិទ្ធិទទួលបានព័ត៌មានសមស្រប
- សិទ្ធិចូលរួមសកម្មភាពសង្គម និងសមាគម

## គ). គោលការណ៍ជាមូលដ្ឋានពាក់ព័ន្ធនឹងសិទ្ធិកុមារ

### គ.១). ការមិនរើសអើង

ការមិនរើសអើងមានន័យថា គ្រប់សិទ្ធិទាំងអស់របស់កុមារត្រូវយកទៅអនុវត្តសម្រាប់គ្រប់កុមារទាំងអស់ ដោយទទួលបាននូវសិទ្ធិដូចគ្នាក្នុងការអភិវឌ្ឍរបស់ពួកគេដោយមិនគិតថាកុមារនោះ :

- មកពីណា សម្បុរអ្វី មាន ឬក្រ ធាត់ ឬស្គម សុខភាពល្អ ឬពិការ
- កាន់សាសនាអ្វី ឬជំនឿ ឬទំនៀមទម្លាប់បែបណាមួយក៏ដោយ
- មានតែឪពុក ឬម្តាយ ឬកុមារកំព្រាក៏ដោយ
- មានភាសា ជាតិសាសន៍ ឬគំនិតយោបល់ខុសគ្នា

ទាំងនេះបង្ហាញឱ្យឃើញថា សិទ្ធិកុមារត្រូវអនុវត្តដោយគ្មានការរើសអើងចំពោះកុមារណាមួយឡើយ ។

គោលការណ៍នៃការមិនរើសអើងពុំមែនមានន័យថា កុមារគ្រប់រូបត្រូវបានអនុវត្តសិទ្ធិស្មើៗគ្នាដាច់ខាតនោះទេ គឺតម្រូវទៅតាមស្ថានភាពជាក់ស្តែង និងតម្រូវការរបស់កុមារម្នាក់ៗ ហើយត្រូវធានាថា កុមារា ឬកុមារីទាំងអស់មានឱកាសពេញលេញក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន និងគ្មានកុមារណាម្នាក់ ដែលមានសិទ្ធិតិចជាងកុមារដទៃទៀតឡើយ ។

កុមារគ្រប់រូបនៅក្នុងសហគមន៍មានសិទ្ធិស្មើៗគ្នាក្នុងការ :

- ទទួលបានសេវាសុខភាព
- ចូលរៀននៅសាលារដ្ឋ
- ទទួលបានទឹកស្អាតសម្រាប់បរិភោគ
- បញ្ចេញទស្សនៈ និងមតិយោបល់
- ទទួលបានព័ត៌មាន ។

### គ.២). ឧត្តមប្រយោជន៍របស់កុមារ

ឧត្តមប្រយោជន៍របស់កុមារមានន័យថា ជាការគិតគូរជាចម្បងលើផលប្រយោជន៍ និងឱកាសរបស់កុមារក្នុងការទទួលបានផលប្រយោជន៍ពីសង្គម ដោយធ្វើការថ្លឹងថ្លែងពីសិទ្ធិស្វ័យភាពរបស់កុមារ និងតម្រូវការការពាររបស់ពួកគេ។

អនុសញ្ញាស្តីពីសិទ្ធិកុមារក៏បានកំណត់អំពីឧត្តមប្រយោជន៍របស់កុមារ មានដូចជា ការទំនាក់ទំនងក្នុងគ្រួសារ ការការពារពីការរំលោភបំពាន ការផ្តល់នូវការថែរក្សា និងការចិញ្ចឹមបីបាច់ដោយហ្មត់ចត់ ដើម្បីឱ្យមានការអភិវឌ្ឍ និងការការពារបានពេញបរិបូរណ៍។

ឪពុកម្តាយជាអ្នកមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការការពារ និងផ្តល់ឧត្តមប្រយោជន៍ដល់កុមារ ដែលជាកូនរបស់ខ្លួន ដោយឡែកស្ថាប័ន ឬអ្នកពាក់ព័ន្ធដទៃទៀត ដូចជាស្ថាប័នសាធារណៈ ឯកជន តុលាការ ឬអង្គការនានាក៏ត្រូវមានកាតព្វកិច្ចក្នុងការលើកស្ទួយ និងការពារកុមារផងដែរ។

### គ.៣). ការរស់រានមានជីវិត និងការអភិវឌ្ឍ

កុមារមានសិទ្ធិក្នុងការរស់រានមានជីវិត និងការអភិវឌ្ឍ មានន័យថា អ្នកពាក់ព័ន្ធទាំងឡាយត្រូវធានាថា ខ្លួនបានផ្តល់សេវាជាមូលដ្ឋានដល់កុមារ និងផ្តល់ឱកាសស្មើគ្នាសម្រាប់កុមារទាំងអស់ ដើម្បីធ្វើការអភិវឌ្ឍខ្លួនគេបានពេញបរិបូរណ៍។ ការរស់រានមានជីវិត និងការអភិវឌ្ឍរបស់កុមារមានដូចជា :

- កុមារត្រូវទទួលបានការចុះសំបុត្រកំណើត ដើម្បីផ្តល់អត្តសញ្ញាណស្របច្បាប់ជាមូលដ្ឋានក្នុងការទទួលបានសេវាសង្គមនានា
- កុមារត្រូវទទួលបានសេវាសុខភាព និងអប់រំប្រកបដោយគុណភាព និងយកចិត្តទុកដាក់
- កុមារត្រូវទទួលបានកិច្ចការពារពីការរំលោភផ្លូវភេទ និងពលកម្ម
- កុមារត្រូវទទួលបានកិច្ចការពារពីគ្រោះធម្មជាតិ និងសង្គ្រាម។

### គ.៤). ការគោរពមតិយោបល់របស់កុមារ

ការគោរពមតិយោបល់របស់កុមារមានន័យថា មតិយោបល់របស់កុមារត្រូវបានទទួលយក និងប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ដូច្នេះទស្សនៈ និងការយល់ឃើញរបស់កុមារត្រូវបានគេយកទៅពិចារណាយ៉ាងល្អិតល្អន់មុនពេលធ្វើសេចក្តីសម្រេចចិត្ត។ គោលការណ៍នេះមាន ទំនាក់ទំនងទៅនឹងឧត្តមប្រយោជន៍របស់កុមារផងដែរ ដូចនេះកុមារ គប្បីចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តនានា ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ។ កុមារមានសិទ្ធិ និងលទ្ធភាពក្នុងការបង្កើតនូវការយល់ឃើញរបស់ខ្លួន និងបង្ហាញនូវការយល់ឃើញទាំងនោះដោយសេរី ពិសេស នៅពេលដែលមានការប៉ះពាល់ដល់ពួកគេ។

ការបញ្ចេញមតិយោបល់របស់កុមារអាចជួយការពារ និងកែលម្អសេវាសង្គមពាក់ព័ន្ធនឹងឧត្តមប្រយោជន៍ ការរស់រានមានជីវិត និងការអភិវឌ្ឍរបស់កុមារដូចជា :

- ការកែលម្អគុណភាពសេវាអប់រំ និងអនាម័យបរិស្ថាននៅសាលារៀន
- សាលារៀនត្រូវមានសុវត្ថិភាព និងកន្លែងលេងកំសាន្តសមស្រប
- ការចូលរៀននៅសាលារដ្ឋដោយគ្មានការបង់ប្រាក់ និងទទួលបានសេវាកម្មផ្សេងៗទៀត
- ការចូលរួមក្នុងសមាគមសិស្ស និងសកម្មភាពសង្គមនានា ដោយផ្ទាល់ ឬតាមរយៈតំណាងរបស់ខ្លួន។

ឃ). កុមារដែលត្រូវការកិច្ចការពារពិសេស

កុមារដែលត្រូវការកិច្ចការពារពិសេស គឺជាកុមារ ដែលស្ថិតក្នុងកាលៈទេសៈលំបាកពិសេស ឬកុមារដែលមានគ្រោះថ្នាក់ ហើយមានការប៉ះពាល់ដល់ការអភិវឌ្ឍរបស់ពួកគេ។

កុមារងាយរងគ្រោះ គឺជាកុមារដែលរស់នៅក្នុងកាលៈទេសៈលំបាក ហើយប្រឈមមុខនឹងគ្រោះថ្នាក់ ប៉ុន្តែពុំទាន់មានការប៉ះពាល់ដល់ការអភិវឌ្ឍរបស់ពួកគេ។

កុមារដែលត្រូវការកិច្ចការពារពិសេសមានដូចជា :

- កុមារកំព្រា
- កុមារពិការ
- កុមារដែលត្រូវបានបោះបង់ចោល
- កុមារដែលទទួលផលប៉ះពាល់ ឬផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍
- កុមារដែលទទួលរងការបំពានផ្លូវភេទ រូបរាងកាយ ឬផ្លូវចិត្ត
- កុមារអនាថាតាមចិញ្ចើមថ្នល់
- កុមារមានទំនាស់ជាមួយច្បាប់
- កុមារដែលរងគ្រោះដោយសារអំពើកេងប្រវ័ញ្ចផ្លូវភេទ ឬទម្រង់ពលកម្មប្រកបដោយគ្រោះថ្នាក់
- កុមារពិការ
- កុមារញៀនសារធាតុញៀន

### ១.៥.២. ទម្រង់នៃការរំលោភបំពានលើកុមារ

ក). ទម្រង់នៃការរំលោភបំពានសិទ្ធិកុមារ

ការរំលោភបំពានសិទ្ធិកុមារមានទម្រង់ដូចខាងក្រោម :

- ការរំលោភបំពានរូបរាងកាយ : ជាសកម្មភាព ដែលធ្វើឱ្យប៉ះពាល់ដល់រូបរាងកាយ ដូចជា ការប្រើអំពើហិង្សា ការប្រើប្រាស់គ្រឿងស្រវឹង ថ្នាំញៀន និងពលកម្មកុមារ ។ល។
- ការរំលោភបំពានសតិស្មារតី : ជាសកម្មភាព ដែលធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍ និងស្មារតីរបស់កុមារ ដោយបង្ហាញនូវកង្វះក្តី មេត្តា និងកង្វះក្តីស្រឡាញ់ ដូចជាការស្រែក ការគំរាមកំហែង ចំអកឡកឡឺយ ការរើសអើង និងការគៀបសង្កត់ផ្លូវចិត្ត ។ល។

- ការរំលោភបំពានផ្លូវភេទ : ជាសកម្មភាពនៃការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស ដែលធ្វើឱ្យបន្ទាបបន្ថោកដល់កុមារ
- ការមិនយកចិត្តទុកដាក់ : ជាការមិនបានបំពេញ ឬឆ្លើយតបតម្រូវការជាមូលដ្ឋានខាងផ្នែករូបរាងកាយ និងស្មារតីរបស់កុមារ ដូចជាការផ្តល់ចំណីអាហារមិនគ្រប់គ្រាន់ ពុំមានសម្លៀកបំពាក់គ្រប់គ្រាន់ ខ្វះការថែទាំសុខភាព និងខ្វះការសិក្សាអប់រំ ។ល។

ខ). ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

អនុសញ្ញាអន្តរជាតិខាងការងារលេខ ១៨២ បានកំណត់អំពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារមានដូចខាងក្រោម :

- គ្រប់ទម្រង់ទាំងអស់នៃទាសភាព ឬការអនុវត្តប្រហាក់ប្រហែលទៅនឹងទាសភាព ដូចជា ការលក់ការជួញដូរ ការងារដោះបំណុល និងការងារជាខ្ញុំកញ្ជះដាច់ថ្លៃ ការងារដោយបង្ខំ ឬការងារដោយកាតព្វកិច្ចដើម្បីឱ្យបម្រើក្នុងជម្លោះប្រដាប់អាវុធ
- ការប្រើប្រាស់ ការអូសទាញ ការផ្តល់ឱ្យកុមារបម្រើក្នុងពេស្យាកម្ម ការផលិតរូបភាពអាសអាភាស ឬសម្តែងអាសគ្រាម
- ការប្រើប្រាស់ ការអូសទាញ ឬផ្តល់ឱ្យកុមារបម្រើក្នុងសកម្មភាពខុសច្បាប់ ជាពិសេសការផលិត និងការជួញដូរគ្រឿងញៀន ដូចដែលបានកំណត់ក្នុងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនានា
- ការងារទាំងឡាយណា ដែលមានលក្ខណៈ ឬស្ថានភាពអាចនឹងបណ្តាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព សីលធម៌របស់កុមារ ។

### ១.៥.៣. កុមារដែលទទួលរងនូវការរំលោភបំពាន

ក). កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា

អំពើហិង្សាក្នុងគ្រួសារ សំដៅលើអំពើហិង្សា ឬការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកជីវភាពសេដ្ឋកិច្ច ដែលប្រព្រឹត្តដោយមនុស្សម្នាក់ ឬច្រើននាក់ ដើម្បីត្រួតត្រាលើមនុស្សផ្សេងទៀត ដែលកំពុងរស់នៅក្នុងគ្រួសារនោះ ។

ក.១). ផលប៉ះពាល់

កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សាអាចទទួលរងផលប៉ះពាល់ភ្លាមៗ និងផលប៉ះពាល់រយៈពេលយូរ ។

- ផលប៉ះពាល់ភ្លាមៗ
  - របួសរាងកាយ ដូចជា ស្នាមជាំ បាក់ដៃជើង ជាំភ្នែក
  - ហូបមិនបាន ដេកមិនលក់ យល់សប្តិអាក្រក់
  - មានភាពតានតឹងក្នុងអារម្មណ៍ មានសភាពភ័យខ្លាច
  - មិនចង់លេងសើចជាមួយកុមារដទៃ ឬផ្តាច់ខ្លួនពីសង្គម

- កើតទុក្ខ ក្រៀមក្រំ និងមានភាពស្រងេះស្រងោច
- ឆាប់ខឹង ងាយនឹងប្រព្រឹត្តអំពើឃោរឃៅ
- មានបញ្ហាក្នុងការផ្តោតអារម្មណ៍ ឬរៀនមិនពូកែ

- **ផលប៉ះពាល់រយៈពេលយូរ**
  - កុមារអាចចម្លងយកឥរិយាបថពីឪពុកម្តាយ អាចនាំឱ្យគេក្លាយទៅជាមនុស្សប្រព្រឹត្តអំពើហិង្សា
  - គេអាចក្លាយជាអ្នកដែលព្រមទទួលយក និងស៊ូទ្រាំអត់ធ្មត់រស់ក្នុងអំពើហិង្សា
  - កុមាររងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារអាចរត់ចេញពីផ្ទះ ឬរស់នៅតាមចិញ្ចើមថ្នល់។

**ក.២). ដំណោះស្រាយចំពោះអំពើហិង្សាក្នុងគ្រួសារ**

ដំណោះស្រាយចំពោះស្ត្រី និងកុមារដែលទទួលរងគ្រោះថ្នាក់ដោយសារអំពើហិង្សាក្នុងគ្រួសារមានដូចជា :

- **ចំពោះករណីស្រាល**
  - បើញាតិសន្តាន គ្រូបង្រៀន អ្នកជិតខាង ព្រះសង្ឃ មិត្តភក្តិ សង្ស័យថាកុមារត្រូវគេវាយដំត្រូវរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច ដែលនៅជិតបំផុតដូចជា អ្នកដឹកនាំភូមិ មេឃុំ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតដើម្បីសុំអន្តរាគមន៍
  - បើមានអំពើហិង្សាក្នុងគ្រួសារកើតឡើងម្តងម្កាល ឬពុំសូវញឹកញាប់ សាច់ញាតិ ចាស់ទុំ មិត្តភក្តិ អ្នកដឹកនាំភូមិ មេឃុំ ចៅសង្កាត់ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត អាចធ្វើការអប់រំណែនាំដល់ឪពុកម្តាយ ឬអ្នកប្រព្រឹត្តិហិង្សា។

- **ចំពោះករណីធ្ងន់ធ្ងរ**
  - បើការរំលោភបំពានមានភាពធ្ងន់ធ្ងរខ្លាំង ឬកើតមានជាបន្តបន្ទាប់ ឬមានរយៈពេលយូរ ឬកើតឡើងជាប្រចាំ អ្នកដឹកនាំភូមិ ឬភ្នាក់ងារស្ម័គ្រចិត្តភូមិ (ក្នុងតំបន់មានបណ្តាញការពារកុមារ) ត្រូវរាយការណ៍ទៅមន្ត្រីសង្គមកិច្ចក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ឬអ្នកមានសមត្ថកិច្ចដទៃទៀត ដើម្បីអន្តរាគមន៍
  - បើមានលទ្ធភាពត្រូវនាំកុមារចេញពីផ្ទះបណ្តោះអាសន្ន ដើម្បីចាត់វិធានការតាមផ្លូវច្បាប់
  - ដំណោះស្រាយដ៏ប្រសើរត្រូវបញ្ជូនកុមារឱ្យស្នាក់នៅបណ្តោះអាសន្នជាមួយញាតិសន្តាន ឬអ្នកជិតខាងនៅក្នុងសហគមន៍ ដើម្បីធានាដល់សុវត្ថិភាព និងសុខុមាលភាពរបស់កុមារ
  - បើសិនជា កុមារស្នាក់នៅបណ្តោះអាសន្នជាមួយសាច់ញាតិ ឬអ្នកជិតខាងក្នុងសហគមន៍ ហើយនៅតែទទួលរងការវាយដំ ដោយឪពុកម្តាយ ឬអាណាព្យាបាលទៀតត្រូវបញ្ជូនកុមារទៅមណ្ឌលសង្គ្រោះ ឬអង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សនៅក្រៅសហគមន៍។
  - ស្វែងរកមណ្ឌលដែលអាចផ្តល់ជម្រកឱ្យស្ត្រី ឬកុមារដែលរងគ្រោះ ដោយសារអំពើហិង្សាក្នុងគ្រួសារឱ្យស្នាក់នៅបណ្តោះអាសន្ន។

## ខ). កុមារដែលត្រូវគេរំលោភផ្លូវភេទ

ការរំលោភផ្លូវភេទលើកុមារ គឺជាសកម្មភាពនៃការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស ការប្រព្រឹត្ត អំពើអាស្រូវភាស និងសកម្មភាពរំលោភ ផ្លូវភេទផ្សេងទៀត ដើម្បីបន្ទាបបន្ថោកដល់កុមារ ទោះបីជា កុមារព្រម ឬ មិនព្រមក្តី។ ការរំលោភផ្លូវភេទលើកុមារគឺជាអំពើខុសច្បាប់។

### ខ.១). ផលប៉ះពាល់នៃការរំលោភផ្លូវភេទលើកុមារ

បន្ទាប់ពីទទួលរងនូវការរំលោភផ្លូវភេទ កុមារនឹង :

- ទទួលផលប៉ះពាល់ជាអវិជ្ជមានលើការអភិវឌ្ឍផ្នែកស្មារតី
- ទទួលការឈឺចាប់ផ្នែករាងកាយ និងផ្លូវចិត្ត
- មានសុខភាពទ្រុឌទ្រោម បាត់បង់សមត្ថភាពពលកម្ម និងបញ្ញា
- ឆ្លងជំងឺកាមរោគផ្សេងៗ ពិសេសជំងឺអេដស៍
- ឆេវឆាវ ចូលចិត្តប្រើអំពើហិង្សា ពិបាកសម្របខ្លួនជាមួយអ្នកដទៃ
- មានការភ័យខ្លាចនៅពេលនៅតែម្នាក់ឯង
- គ្មានជំនឿលើខ្លួនឯង អស់សង្ឃឹមក្នុងជីវិត
- ទទួលការរើសអើងក្នុងសង្គម
- អាចមានផ្ទៃពោះ
- អាចក្លាយជាឪពុក ម្តាយដែលមានចរិតឃោរឃៅ

### ខ.២). ការអន្តរាគមន៍ករណីមានការរំលោភផ្លូវភេទលើកុមារ

ក្នុងករណីមានការរំលោភផ្លូវភេទលើកុមារ ឪពុក ម្តាយ សាច់ញាតិ ឬអ្នកដទៃទៀតត្រូវតែផ្តល់ព័ត៌មានទៅ អ្នកដឹកនាំភូមិ មេឃុំ ចៅសង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ មន្ត្រីសង្គមកិច្ចក្រុង ស្រុក ខណ្ឌ និងអ្នកមានសមត្ថកិច្ចផ្សេងទៀតឱ្យបានឆាប់រហ័ស ដើម្បីសុំអន្តរាគមន៍។

មេឃុំ ចៅសង្កាត់ អ្នកដឹកនាំភូមិ ឪពុកម្តាយ សាច់ញាតិ និងអាណាព្យាបាលមានសមត្ថកិច្ចត្រូវចាត់វិធានការនានា ដើម្បីធានាសុវត្ថិភាពដល់កុមារដូចជា :

- ចេញឯកសារស្របច្បាប់បណ្តោះអាសន្ន ស្តីពីការចាត់ចែងទៅលើការថែទាំកុមារ
- បញ្ជូនកុមារទៅមជ្ឈមណ្ឌលផ្តល់ទីជម្រក និងការថែទាំ (បើចាំបាច់)
- នាំកុមារទៅទទួលការផ្តល់ប្រឹក្សាយោបល់ និងការថែទាំពីអ្នកដែលមានជំនាញ ជាពិសេសពីមន្ត្រីសង្គមកិច្ចក្រុង ស្រុក ខណ្ឌ ឬពីអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដូចជាអង្គការលីកាដូ អង្គការអាដហុក អង្គការចិត្ត សង្គម-អន្តរវប្បធម៌ (ធីភីអូ) ឬមណ្ឌលនានា ដែលផ្តល់សេវាទាំងនេះ
- បញ្ជូនកុមារទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាព ក្នុងរយៈពេល ២៤ម៉ោង បន្ទាប់ពីពេលកើតហេតុ ដើម្បីសង្គ្រោះបន្ទាន់ និងរកភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌ

- ត្រូវរៀបចំដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌជាជាងទទួលយកការសងជំងឺចិត្តពីជនល្មើសជាទឹកប្រាក់ ឬជាការរៀបចំចាត់ចែងរៀបអាពាហ៍ពិពាហ៍
- អប់រំប្រជាពលរដ្ឋឱ្យយល់ច្បាស់ពីការរំលោភផ្លូវភេទ និងជួយដល់កុមាររងគ្រោះ ហើយមិនត្រូវរើសអើង ឬស្អប់ខ្ពើមឡើយ និងចូលរួមប្រឆាំងរាល់ទង្វើនៃការរំលោភ។

**គ). កុមារត្រូវគេគេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ**

**គ.១). ពលកម្មកុមារ និងការងារកុមារ**



ពលកម្មកុមារ គឺជាការងារទាំងឡាយណាដែលធ្វើដោយកុមារ អាយុក្រោម១៨ឆ្នាំ ទោះជាទទួលបានកម្រៃ ឬមិនទទួលបានកម្រៃក្ដីឱ្យតែរាល់ការងារនោះប៉ះពាល់ដល់ការរីកលូតលាស់ផ្នែកចិត្តគំនិត ផ្នែករាងកាយ ផ្នែកសង្គម និងផ្នែកសីលធម៌របស់កុមារ ជាពិសេស រាំងស្ទះដល់ការអប់រំរបស់ពួកគេ។

ការងារកុមារ គឺជាការងារទាំងឡាយណា ដែលជួយអប់រំ និងបណ្ដុះបណ្ដាលដល់កុមារឱ្យចេះធ្វើការងារនៅពេលអនាគត ដែលជាផ្នែកមួយនៃវិជ្ជាជីវៈសង្គម ឬវិជ្ជាជីវៈគ្រួសារ មានន័យថា ការងារកុមារមិនមែនជាពលកម្មកុមារទេ។

ពលកម្មកុមារមិនបានរាប់បញ្ចូលកុមារដែលត្រូវធ្វើការពីរ ឬបីម៉ោង ក្នុងមួយសប្ដាហ៍ ដើម្បីជួយគ្រួសាររបស់ពួកគេលើការងារមួយចំនួន ដូចជា ការងារស្រែចម្ការ ការងារផ្ទះ និងការងារតូចតាចក្នុងមុខជំនួញរបស់គ្រួសារ ។ល។

**គ.២). ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅកម្ពុជា**

ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅកម្ពុជា ដែលត្រូវយកចិត្តទុកដាក់ជាអាទិភាពក្នុងការលុបបំបាត់មានដូចខាងក្រោម :

- **សកម្មភាពទាំងឡាយដែលផ្ទុយទៅនឹងសិទ្ធិមនុស្សជាមូលដ្ឋាន:** ការជួញដូរស្ត្រី និងកុមារ អំពើពេស្យាចារកុមារ រូបភាព និងសម្ភារៈអាសអាភាសលើកុមារ ការផលិត ការលក់ដូរ និងការជួញដូរគ្រឿងញៀន
- **ផ្នែកសេវាកម្ម :** ការងារលីសែងទំនិញ បម្រើការងារផ្ទះ និងការងាររើសកកាយកាកសំណល់
- **ផ្នែកកសិកម្ម :** ការងារចំការកៅស៊ូ ការងារចំការថ្នាំជក់ ការងារនេសាទក្នុងទឹក និងលើផ្ទៃទឹកជ្រៅ ការងារចំការផ្សេងៗទៀត ដែលមានលក្ខណៈកសិឧស្សាហកម្ម
- **ផ្នែកសិប្បកម្ម និងឧស្សាហកម្មខ្នាតតូច :** សហគ្រាសឡឥដ្ឋ សហគ្រាសស្រែអំបិល សហគ្រាស ឬសិប្បកម្មកែច្នៃជលផល ដូចជា ការបកក្ដាម និងការបកបង្គាជាដើម
- **ផ្នែករ៉ែ និងថ្ម :** ការងារបំបែកថ្មភ្នំ ការងាររាវគ្រួសអាចម៍ផ្កាយ ការងារយកខ្សាច់ និងការងារជីករករ៉ែត្បូង។

គ.៣). ផលប៉ះពាល់នៃពលកម្មកុមារ

ពលកម្មកុមារផ្តល់ផលប៉ះពាល់អវិជ្ជមានជាច្រើនដូចជា :

- កុមារលូតលាស់មិនបានល្អ ( ក្រិន)
- កុមារខ្សោយកម្លាំង ពិការដៃជើង និងពិការអវៈយវៈ
- កុមារមិនបានទទួលការសិក្សាអប់រំ
- អាចធ្វើឱ្យកុមាររងគ្រោះថ្នាក់ដល់បាត់បង់ជីវិត
- សង្គមជាតិបាត់បង់ធនធានមនុស្សទៅថ្ងៃអនាគត
- ពលកម្មកុមារជាមូលហេតុនាំឱ្យមានភាពក្រីក្រ

គ.៤). ប្រភេទការងារស្រាលអនុញ្ញាតឱ្យកុមារធ្វើការងារ

យោងតាមច្បាប់ស្តីពី ការងារបានកំណត់នូវកិច្ចការមួយចំនួន ដើម្បីជួយការពារកុមារ :

- អនីតិជនអាយុតិចជាង១៨ឆ្នាំ មិនអាចប្រើឱ្យធ្វើការនៅអណ្តូង រ៉ែ ឬការយករ៉ែ ឬយកថ្មក្នុងដីឡើយ ( មាត្រា ១៧៤)
- ការសម្រាកពេលយប់សម្រាប់ក្មេងភេទណាក៏ដោយ ត្រូវឱ្យមានថិរវេលាជាអប្បបរមា១០ម៉ោងបន្តបន្ទាប់គ្នា ( មាត្រា ១៧៦)
- ក្មេងនិយោជិត កម្មករ ឬកូនជាងមានអាយុតិចជាង១៨ឆ្នាំ មិនអាចប្រើឱ្យធ្វើការក្នុងសហគ្រាសឧស្សាហកម្ម រ៉ែ ពាណិជកម្ម សិប្បកម្ម សេវាកម្ម កសិកម្ម ការដឹកជញ្ជូនតាមផ្លូវគោក និងផ្លូវទឹក ( មាត្រា ១ និងមាត្រា ១៨២)
- អាយុអប្បបរមាអាចចូលធ្វើការជាកម្មករនិយោជិតត្រូវបានកំណត់ដល់១៨ឆ្នាំ ចំពោះមុខរបរ ឬការងារគ្រប់ប្រភេទដែលអាចធ្វើឱ្យខូចសុខភាព សន្តិសុខ ឬសីលធម៌ដោយសារតែល័ក្ខខ័ណ្ឌ ឬប្រភេទមុខរបរ និងការងារនេះបង្កឡើង ។ ក្មេងដែលមានអាយុពី១២ដល់ ១៥ឆ្នាំអាចអនុញ្ញាតឱ្យធ្វើតែការងារស្រាលៗក្នុងល័ក្ខខ័ណ្ឌការងារនោះមិនបណ្តាលឱ្យ :
  - ខូចសុខភាព ឬការអភិវឌ្ឍនៃចិត្តរបស់កុមារ
  - ប៉ះពាល់ដល់ការសិក្សាជាទៀងទាត់ និងការចូលរួមក្នុងកម្មវិធីតម្រង់ទិស ឬកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ( មាត្រា ១៧៧)

កុមារអាចអនុញ្ញាតឱ្យធ្វើការងារស្រាលៗបាន ដូចមានចែងក្នុងប្រកាស ស្តីពី ការកំណត់ប្រភេទមុខរបរ និងការងារស្រាលដែលអនុញ្ញាតឱ្យកុមារអាចធ្វើការងារចាប់ពីអាយុ ១២ឆ្នាំ ដល់១៥ឆ្នាំ លេខ ០០២/០៨ កប/ប្រក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ការងារស្រាល គឺជាប្រភេទការងារមិនបណ្តាលឱ្យខូចសុខភាព ឬការអភិវឌ្ឍនៃចិត្ត និងកាយរបស់កុមារ និងមិនបណ្តាលឱ្យប៉ះពាល់ដល់ការសិក្សាជាទៀងទាត់ ការចូលរួមក្នុងកម្មវិធីតម្រង់ទិស ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ប្រភេទការងារស្រាលមានជាអាទិ៍ :

- ការងារកសិកម្មស្រាលៗ ខាងចិញ្ចឹមសត្វ ថែទាំសត្វស្រុកតូចៗ
- ការងារកត់ត្រាទំនិញ ការត្រួតពិនិត្យមើលផលិតផល
- លក់សារព័ត៌មាន និងផលិតផលប្រហាក់ប្រហែល
- ការវេចខ្ចប់ ការជ្រើសរើស ការបែងចែកតាមប្រភេទទំនិញ
- ការបញ្ចូនឯកសារក្នុងអង្គភាព ការបែងចែកឯកសារ

ការងារកុមារប្រចាំថ្ងៃមិនត្រូវលើសពី :

- ៤ម៉ោងចំពោះថ្ងៃសិក្សារៀនសូត្រ
- ៧ម៉ោងចំពោះថ្ងៃសម្រាកពីការសិក្សា
- ១២ម៉ោងក្នុងមួយសប្តាហ៍ថ្ងៃសិក្សា
- ៣៥ម៉ោងក្នុងមួយសប្តាហ៍សម្រាប់សប្តាហ៍ឈប់សម្រាកពីការសិក្សា

គ.៥). ការអន្តរាគមន៍លើការប្រើប្រាស់ពលកម្មកុមារ

- ផ្សព្វផ្សាយ និងពន្យល់ប្រជាពលរដ្ឋ ពិសេសឪពុកម្តាយអំពីផលប៉ះពាល់អវិជ្ជមាននៃការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ
- រាយការណ៍ទៅមន្ត្រីសង្គមកិច្ចក្រុង ស្រុក ខណ្ឌ និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីអន្តរាគមន៍ និងចាត់វិធានការតាមផ្លូវច្បាប់
- មេឃុំ ចៅសង្កាត់ និងមន្ត្រីសង្គមកិច្ចក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធអាចទៅសួរសុខទុក្ខកុមារ ដើម្បីផ្តល់កម្លាំងចិត្ត និងផ្តល់ការថែទាំសមស្រប
- ទំនាក់ទំនងជាមួយក្រុមគ្រួសារ ឬស្ថាប័នពាក់ព័ន្ធ ដូចជា អង្គការមិនមែនរដ្ឋាភិបាល ឬសប្បុរសជននានា ដើម្បីការពារកុមារពីការធ្វើពលកម្មប្រកបដោយគ្រោះថ្នាក់ ។

### ១.៥.៤. ការថែទាំជំនួសចំពោះកុមារ

ក). គោលបំណង

ការថែទាំជំនួសចំពោះកុមារ មានគោលបំណងការពារសិទ្ធិរបស់កុមារ និងធានាការអភិវឌ្ឍផ្លូវកាយ ផ្លូវចិត្ត បញ្ញាស្មារតី យូរអង្វែងរបស់កុមារកំព្រា និងកុមាររងគ្រោះផ្សេងៗទៀត ដើម្បី :

- ធានាឱ្យកុមារបានទទួលផលប្រយោជន៍ពីលិខិតូបករណ៍ ច្បាប់ជាតិ និងអន្តរជាតិ ជាពិសេស អនុសញ្ញាស្តីពី សិទ្ធិកុមារ និងគោលការណ៍ទាំង៤ របស់អនុសញ្ញា

- ធានាឱ្យកុមារបានរីកចម្រើនល្អតលាស់នៅក្នុងក្រុមគ្រួសារ និងនៅក្នុងសហគមន៍ ពិសេសក្នុងគ្រួសារបង្កើត និងសហគមន៍ ជាកន្លែងដើម ឬស្រុកកំណើត
- ធានាឱ្យកុមារមានលទ្ធភាពទទួលបានសេវាសុខភាព សេវាអប់រំដោយឥតគិតថ្លៃ និងការគាំទ្រផ្លូវចិត្ត ដើម្បីឱ្យកុមារអាចរស់រាន និងអភិវឌ្ឍន៍
- បង្កើតសមត្ថភាពសហគមន៍សម្រាប់ថែទាំ និងការពារកុមារងាយរងគ្រោះ តាមរយៈការលើកស្ទួយ និងពង្រឹងបណ្តាញសុវត្ថិភាពទាំងអស់របស់សហគមន៍។

## ៦). គំរូនៃការថែទាំជំនួសចំពោះកុមារ

គំរូនៃការថែទាំជំនួសចំពោះកុមារ រួមមានសេវាពីរប្រភេទគឺ ការថែទាំក្រៅមណ្ឌល និងការថែទាំក្នុងមណ្ឌល។

### ៦.១). ការថែទាំក្រៅមណ្ឌល

ការថែទាំក្រៅមណ្ឌល គឺជាការថែទាំនៅតាមក្រុមគ្រួសារ និងនៅតាមសហគមន៍។ ការថែទាំក្រៅមណ្ឌលមានដូចជា :

- **ការថែទាំដោយឪពុកម្តាយធម៌** : គឺជាការប្រគល់កុមារឱ្យគ្រួសារមួយ ដែលជាទូទៅពុំមែនជាសាច់ញាតិរបស់កុមារ ហើយដែលបានយល់ព្រមទទួលចិញ្ចឹមថែទាំកុមារជាបណ្តោះអាសន្ន។ ជាទូទៅ ការចិញ្ចឹមថែទាំបែបនេះ ច្រើនតែមានរយៈពេលខ្លី ហើយពុំមានការពាក់ព័ន្ធទៅនឹងការផ្ទេរសិទ្ធិ និងភារកិច្ចទទួលខុសត្រូវជាអចិន្ត្រៃយ៍របស់ឪពុកម្តាយទេ។ ការអនុវត្តន៍បែបបទនេះ ក្នុងសង្គមកម្ពុជា ជាទូទៅពុំមានពាក់ព័ន្ធជាមួយកិច្ចព្រមព្រៀងផ្លូវច្បាប់ឡើយ ប៉ុន្តែ ការយកកុមារមកចិញ្ចឹមជាកូនធម៌បែបនេះ អាចផ្អែកលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងរវាងឪពុកម្តាយបង្កើត ឪពុកម្តាយធម៌ អាជ្ញាធរមូលដ្ឋាន ឬអាជ្ញាកណ្តាល ឬអង្គការណាមួយ។
- **ការថែរក្សាដោយសាច់ញាតិ** : គឺជាស្ថានភាពមួយ ដែលសមាជិកក្នុងក្រុមគ្រួសារមួយ ទទួលយកកុមារកំព្រា ឬកុមារដទៃទៀត មកចិញ្ចឹមក្នុងគ្រួសាររបស់ខ្លួន។ អ្នកថែទាំចិញ្ចឹមកុមារ ជីដូនជីតា ម្តាយធំ ឪពុកធំ ម្តាយមីង ឪពុកមា ឬជាសាច់ជាតិដទៃទៀតរបស់កុមារ។ ការអនុវត្តន៍បែបបទនេះ អាចផ្អែកលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងរវាងឪពុកម្តាយបង្កើត ឪពុកម្តាយធម៌ អាជ្ញាធរមូលដ្ឋាន ឬអាជ្ញាកណ្តាល ឬអង្គការណាមួយ។
- **សុំកូន** : គឺជាការដាក់កុមារឱ្យរស់នៅក្នុងគ្រួសារមួយជាអចិន្ត្រៃយ៍ ដោយឱ្យឪពុកម្តាយបង្កើតផ្ទេរសិទ្ធិ និងភារកិច្ចទទួលខុសត្រូវទាំងអស់ជូនទៅឪពុកម្តាយចិញ្ចឹម ហើយកុមារដែលគេចិញ្ចឹមនោះ ត្រូវមានឋានៈ សិទ្ធិ និងការព្វកិច្ចនានាដូចកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះដែរ។ ការសុំកូនយកទៅចិញ្ចឹមអាចជាការចិញ្ចឹមកូនក្នុងប្រទេស និងការចិញ្ចឹមកូនក្រៅប្រទេស។ ការសុំកូនយកទៅចិញ្ចឹមត្រូវធ្វើឡើងដោយមានកិច្ចសន្យាជាលាយលក្ខណ៍អក្សររវាងឪពុកម្តាយចិញ្ចឹម និងកុមារដែលត្រូវគេសុំយក

- ការចិញ្ចឹមថែរក្សានៅតាមទីវត្តអារាម និងទីកន្លែងជំនឿសាសនានានា : មានតួនាទីសំខាន់ក្នុងការផ្តល់ការថែទាំជំនួសដល់កុមារ។ ព្រះសង្ឃ ដូនជី និងលោកអាចារ្យ ជាអ្នកផ្តល់ដល់កុមារនូវចំណីអាហារ ជំរក ការអប់រំ ជាដើម។
- ក្រុមគ្រួសារ ឬផ្ទះដែលមានកុមារជាមេគ្រួសារ : គឺជាក្រុមកុមារកំព្រា ដែលជាបងប្អូននឹងគ្នារស់នៅក្រោមការទទួលខុសត្រូវ និងការចិញ្ចឹមថែរក្សារបស់កុមារ ដែលមានវ័យច្រើនជាង ដោយសារឪពុកម្តាយ ឬសាច់ញាតិបានស្លាប់ចោល ឬក៏ពិការសមត្ថភាព។ ដោយសារ ការឆ្លងរាលដាលនៃមេរោគ និងជំងឺអេដស៍ ជាមូលហេតុមួយធ្វើឱ្យគ្រួសារប្រភេទនេះ មានការកើនឡើង។
- ការថែទាំនៅតាមផ្ទះជាក្រុម : គឺជាការថែរក្សាជំនួស ដែលដាក់ឱ្យកុមារមួយចំនួនកំណត់ រស់នៅក្នុងផ្ទះមួយជាមួយគ្នា ជាបរិយាកាសគ្រួសារមួយក្រោមអភិបាលកិច្ចរបស់អ្នកផ្តល់សេវាថែទាំមួយក្រុមតូច ដែលពុំមែនជាសាច់ញាតិរបស់កុមារ។ ផ្ទះជាក្រុមនេះ ត្រូវបានគេរៀបចំឱ្យស្ថិតនៅក្នុងសហគមន៍មួយ ប៉ុន្តែ ពុំមែននៅក្រោមការចាត់ចែងគ្រប់គ្រងរបស់សហគមន៍ទេ។

១.២). ការថែទាំក្នុងមណ្ឌល

ការថែទាំក្នុងមណ្ឌល គឺជាការចាត់ចែងរៀបចំឱ្យកុមាររស់នៅជុំគ្នាជាក្រុម ក្រោមការថែទាំរបស់បុគ្គលិកមណ្ឌល ដែលទទួលប្រាក់បៀវត្សរ៍សម្រាប់ផ្តល់ការថែទាំ។ ការថែទាំក្នុងមណ្ឌលមានដូចជា :

- មណ្ឌលស្តារនីតិសម្បទា ឬកន្លែងផ្តល់កិច្ចការពារដល់កុមារ : មណ្ឌលផ្តល់ចំណីអាហារដល់កុមារ ដែលត្រូវបានរំលោភបំពាន ដែលត្រូវបានកេងប្រវ័ញ្ច និងដែលរងគ្រោះដោយសារគ្រឿងញៀន កុមាររស់នៅតាមចិញ្ចើមថ្នល់ ឬកុមាររស់នៅក្នុងស្ថានភាពលំបាកណាមួយផ្សេងៗទៀត។ មណ្ឌលអាចផ្តល់សេវាពិសេស ដូចជា ការផ្តល់ប្រឹក្សាពាក់ព័ន្ធនឹងស្ថានភាពដែលប៉ះពាល់ដល់ជីវិតរស់នៅរបស់កុមារ ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- មណ្ឌលកុមារកំព្រា : គឺជាមណ្ឌលសម្រាប់ស្នាក់នៅយូរអង្វែងដែលផ្តល់អ្វីៗ ទៅតាមតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍកុមារដែលបាត់បង់ឪពុក ឬម្តាយ ឬបាត់បង់ឪពុកម្តាយ។ មណ្ឌលក៏ទទួលផងដែរនូវកុមារ ដែលប្រឈមមុខនឹងគ្រោះថ្នាក់ ឬត្រូវការកិច្ចការពារពិសេស ប៉ុន្តែ មណ្ឌលពុំអាចផ្តល់សេវាពិសេសបានទេ។

## គ). ការទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ច និងភ្នាក់ងារផ្តល់ការថែទាំជំនួស

### គ.១). ការទទួលខុសត្រូវរបស់ស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋាភិបាល

- ពិនិត្យឡើងវិញ រៀបចំបង្កើតគោលនយោបាយ ច្បាប់ និងចងក្រងលិខិតបទដ្ឋានផ្សេងៗ ឱ្យស្របទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ និងថែទាំតាមមណ្ឌលស្នាក់នៅយូរអង្វែង
- ផ្សព្វផ្សាយ និងធានាការអនុវត្តន៍គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធឱ្យមានប្រសិទ្ធភាព
- តាមដានត្រួតពិនិត្យ និងវាយតម្លៃ និងផ្តល់ការអនុញ្ញាតដល់អ្នកថែទាំជំនួសរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលនានា
- បែងចែកថវិកាសម្រាប់ឧបត្ថម្ភដល់ការងារថែទាំជំនួស ស្របតាមចំនួនអ្នកទទួលផល គោលនយោបាយជាតិ បទដ្ឋានអប្បបរិមា និងគោលការណ៍ណែនាំនានា ដោយផ្តោតការយកចិត្តទុកដាក់ ពិសេស ទៅលើតួនាទីរបស់មន្ត្រីរាជការក្នុងការប្រតិបត្តិ តាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីថែទាំជំនួស
- បង្កលក្ខណៈងាយស្រួល ជួយភ្នាក់ងារផ្តល់សេវាថែទាំជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការកៀរគររកថវិកា និងជួយរកដំណោះស្រាយ និងការអនុវត្តប្រកបដោយនិរន្តរភាព
- ដឹកនាំ សម្របសម្រួល និងផ្តល់កិច្ចសហការដល់ដៃគូអភិវឌ្ឍន៍នានា។

### គ.២). ការទទួលខុសត្រូវរបស់ភ្នាក់ងារផ្តល់ការថែទាំជំនួស

- សហការជាមួយស្ថាប័នមានសមត្ថកិច្ចរបស់រដ្ឋាភិបាល ជួយពិនិត្យឡើងវិញ ការរៀបចំ ផ្សព្វផ្សាយ គោលនយោបាយ ច្បាប់ លិខិតបទដ្ឋាននានា និងគោលការណ៍ស្តីពីការថែទាំជំនួយ ឱ្យស្របទៅតាមអនុសញ្ញា ស្តីពីសិទ្ធិកុមារ និងថែទាំតាមមណ្ឌលស្នាក់នៅយូរអង្វែង
- អនុវត្តគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ និង និងគោលការណ៍ស្តីពីការថែទាំជំនួយ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពការងារផ្ទាល់ខ្លួន ផ្តល់របាយការណ៍ ព្រមទាំងជួយសម្របសម្រួលដល់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ជួយអភិវឌ្ឍ និងអនុវត្តដំណោះស្រាយប្រកបដោយនិរន្តរភាព ដោយយកចិត្តទុកដាក់ ពិសេស ទៅលើការលើកស្ទួយដំណោះស្រាយនានានៅតាមគ្រួសារ និងសហគមន៍

# ផ្នែកទី២.

# សកម្មភាពឃុំ សង្កាត់ក្នុងការ អភិវឌ្ឍផ្នែកសង្គម

# ផ្នែកទី២. សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម

## ២.១. ការរៀបចំផែនការអភិវឌ្ឍន៍ផ្នែកសង្គម

ការអនុវត្តមុខងាររបស់គណៈកម្មាការទិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ក្នុងការអភិវឌ្ឍផ្នែកសង្គមនៅឃុំ សង្កាត់ ផ្តោតជាចម្បងលើការលើកកម្ពស់សុខភាពមាតា និងទារក អនាម័យនៅមូលដ្ឋាន ការរៀបចំ និងដំណើរមត្តេយ្យសិក្សាសហគមន៍ ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ ហេតុនេះ គ.ក.ន.ក ត្រូវជួយ គ.ផ.ថ ដើម្បីវិភាគ កំណត់ និងលើកឡើងនូវរាល់តម្រូវការជាអាទិភាពសម្រាប់អភិវឌ្ឍន៍ផ្នែកសង្គមនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ (ផ.អ.ឃ/ស)និងកម្មវិធីវិនិយោគឃុំ សង្កាត់(ក.វិ.ឃ/ស)។

### ២.១.១. ការកំណត់តម្រូវការអភិវឌ្ឍន៍ផ្នែកសង្គម

ការចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ គឺជាយុទ្ធសាស្ត្រមួយយ៉ាងសំខាន់ ដើម្បីធានាថា សកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមត្រូវបានលើកឡើង និងដាក់បញ្ចូលទៅក្នុងការសកម្មភាពអភិវឌ្ឍន៍ឃុំ សង្កាត់។ ការបញ្ចូលសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមទៅក្នុងការផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ គ.ក.ន.ក អាចអនុវត្តន៍សកម្មភាពមួយចំនួនដូចខាងក្រោម :

#### ក). ការប្រមូលទិន្នន័យភូមិ និងព័ត៌មានស្ថានភាពឃុំ សង្កាត់

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវជួយ គ.ក.ន.ក ក្នុងការចូលរួមដំណើរការប្រមូលព័ត៌មាន និងទិន្នន័យជាមួយអ្នកដឹកនាំភូមិ និង គ.ផ.ថ ដើម្បីធានាថា បញ្ហាសុខភាព ការអប់រំកុមារតូច អនាម័យ និងបញ្ហាស្ត្រី កុមារ និងជនងាយរងគ្រោះត្រូវបានប្រមូល និងរៀបចំសម្រាប់ជាទិន្នន័យមូលដ្ឋានក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់

#### ខ). ការលើកឡើងអំពីតម្រូវការអភិវឌ្ឍន៍ផ្នែកសង្គមក្នុងដំណើរការ ផ.អ.ឃ/ស និង ក.វិ.ឃ/ស

គ.ក.ន.ក ត្រូវចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ដើម្បីជួយ គ.ផ.ថ ក្នុងការកំណត់សកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា អនាម័យ ការអប់រំកុមារតូច សមភាពយេនឌ័រ និងកិច្ចការពារកុមារ។ ការបញ្ចូលសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមទៅក្នុងការផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ គ.ក.ន.ក អាចធ្វើឡើងតាមរយៈ :

- ការវិភាគទិន្នន័យភូមិ និងព័ត៌មានស្ថានភាពឃុំ សង្កាត់ ជាមួយ គ.ផ.ថ ដើម្បីធានាថា បញ្ហា និងតម្រូវការផ្នែកសុខភាពមាតា និងទារក អនាម័យ ការអប់រំកុមារតូច សមភាពយេនឌ័រ និងកិច្ចការពារកុមារត្រូវបានពិនិត្យ ពិចារណា និងលើកឡើងនៅក្នុងកិច្ចប្រជុំនៅថ្នាក់ឃុំ សង្កាត់ និងកិច្ចប្រជុំជាមួយប្រជាពលរដ្ឋតាមភូមិ ដើម្បីដាក់បញ្ចូលបញ្ហា និងតម្រូវការទាំងនេះទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់

- ពិភាក្សា និងកំណត់គម្រោងអាទិភាពទាក់ទងនឹងការអភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតានិង ទារក អនាម័យ ការអប់រំកុមារតូច សមភាពយេនឌ័រ និងកិច្ចការពារកុមារ ដើម្បីដាក់បញ្ចូលគម្រោង ទាំងនោះទៅក្នុងកម្មវិធីវិនិយោគ និងតារាងម៉ាទ្រិចសម្រាប់សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក
- បង្ហាញ និងលើកឡើងគម្រោងអាទិភាពអភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា និងទារក អនាម័យ ការអប់រំកុមារតូច សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅសិក្ខាសាលា សមាហរណកម្ម ផែនការថ្នាក់ស្រុក ដើម្បីស្វែងរកការគាំទ្រពីមន្ទីរជំនាញ និងដៃគូអភិវឌ្ឍន៍នានា (ទោះការគាំទ្រផ្នែក បច្ចេកទេសក៏ដោយ)
- បន្ទាប់ពីសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក គ.ក.ន.ក ត្រូវសហការជា គ.ផ.ថ ដើម្បីពិនិត្យ មើលគម្រោងអាទិភាពអភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតានិង ទារក អនាម័យ ការអប់រំ កុមារតូច សមភាពយេនឌ័រ និងកិច្ចការពារកុមារ ដែលពុំមានការគាំទ្រ ដើម្បីជ្រើសរើសគម្រោង អភិវឌ្ឍន៍ផ្នែកសង្គមទាំងនោះសម្រាប់ប្រើប្រាស់មូលនិធិឃុំ សង្កាត់។

## ២.១.២. ការរៀបចំផែនការសកម្មភាព និងផែនការថវិកាសម្រាប់ការអភិវឌ្ឍផ្នែកសង្គម

### ក). ការរៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ

បន្ទាប់ពីបានកំណត់ និងជ្រើសរើសគម្រោងអភិវឌ្ឍន៍ផ្នែកសង្គមសម្រាប់ប្រើប្រាស់មូលនិធិឃុំ សង្កាត់ មក គ.ក.ន.ក ត្រូវបានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ (ទម្រង់ទី១) និងផែនការថវិកាប្រចាំឆ្នាំ (ទម្រង់ទី២) រួច ដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័ត។

បន្ទាប់ពីផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការថវិកាប្រចាំឆ្នាំត្រូវបានអនុម័ត គ.ក.ន.ក ត្រូវធ្វើការ ផ្សព្វផ្សាយផែនការនេះ ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់។ ការផ្សព្វផ្សាយអាចធ្វើឡើងតាមរយៈ:

- អ្នកដឹកនាំភូមិត្រូវរៀបចំកិច្ចប្រជុំតាមភូមិ ដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ
- អ្នកដឹកនាំភូមិចុះផ្សព្វផ្សាយតាមគ្រួសារ ពិសេសគ្រួសារដែលមានបញ្ហាពាក់ព័ន្ធនិងផែនការ សកម្មភាព
- មេឃុំ ចៅសង្កាត់ត្រូវបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មានឃុំ សង្កាត់ និងទីសាធារណៈ។

ឧទាហរណ៍

ទម្រង់ទី១

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..................................................

ក្រុង ស្រុក ខណ្ឌ : ..................................................

ឃុំ សង្កាត់ : ..................................................

## ផែនការសកម្មភាពប្រចាំឆ្នាំ២០១០

## ស្តីពីការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

| ល.រ | សកម្មភាព និងលទ្ធផល | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | ខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១ | **ការលើកកម្ពស់សុខភាពមាតា** | | | | | | | | | | | | | | | | | |
| ១.១. | ពង្រឹងបណ្តាញភ្នាក់ងារសុខភាពភូមិ | ប្រជុំ | ១ | សាលាឃុំ | ២៥ | ១៥ | | | | | | | | | ■ | | | |
| ១.២. | ផ្សព្វផ្សាយអំពី ការចាក់ថ្នាំការពារដល់ស្ត្រីមានផ្ទៃពោះ និងកុមារ | ប្រជុំ | ២ | ភូមិ ខ និងភូមិ គ | ៥០ | ៣៥ | | | | | | | | | ■ | ■ | | |
| ១.៣. | គាំទ្រការធ្វើដំណើរសម្រាប់សម្រាលកូននៅមណ្ឌលសុខភាព | នាក់ | ១៥ | ភូមិ ខ និងភូមិ គ | ១៥ | ១៥ | | | | | | | | | | ■ | ■ | |
| ១.៤. | ផ្តល់អាហារដល់ស្ត្រីក្នុងអំឡុងពេលសម្រាលកូននៅមណ្ឌលសុខភាព | នាក់.ថ្ងៃ | ៣០ | ភូមិ ខ និងភូមិ គ | ១៥ | ១៥ | | | | | | | | | | ■ | ■ | |
| ២ | **ការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍** | | | | | | | | | | | | | | | | | |
| ២.១. | កំណត់ទីតាំង និងរៀបចំថ្នាក់មត្តេយ្យសិក្សាសហគមន៍ | ប្រជុំ | ១ | ភូមិ គ | ១៥ | ៥ | | | | | | | | ■ | | | | |
| ២.២. | ផ្សព្វផ្សាយ និងចលនាមាតាបិតាសិស្សឱ្យបញ្ជូនកូនទៅរៀន | ប្រជុំ | ១ | ភូមិ ខ ភូមិ គ និងភូមិ ឃ | ៥០ | ៣០ | | | | | | | | | ■ | | | |
| ២.៣. | ជ្រើសរើស និងធ្វើកិច្ចសន្យាជាមួយគ្រូមត្តេយ្យសិក្សាសហគមន៍ | ប្រជុំ | ១ | សាលាឃុំ | ១០ | ៥ | | | | | | | | | ■ | | | |
| ២.៤. | បណ្តុះបណ្តាលគ្រូមត្តេយ្យសហគមន៍ដោយមន្ទីរអប់រំ យុវជន និងកីឡា | នាក់ | ១ | សាលាស្រុក | ១ | ១ | | | | | | | | | ■ | | | |
| ២.៥. | ដំណើរការរទុវគ្គមត្តេយ្យសិក្សាសហគមន៍ | ខែ | ៣ | ភូមិ គ | ២៥ | ១៣ | | | | | | | | | | ■ | ■ | ■ |

| ល.រ | សកម្មភាព និងលទ្ធផល | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | ខែ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ៣ | **ការលើកកម្ពស់អនាម័យនៅមូលដ្ឋាន** | | | | | | | | | | | | | | | | | |
| ៣.១. | ពង្រឹងបណ្តាញការងារអនាម័យនៅមូលដ្ឋាន | ប្រជុំ | ១ | សាលាឃុំ | ២៥ | ១៥ | | | | | | | | | ■ | ■ | | |
| ៣.២. | ផ្សព្វផ្សាយអំពី សារប្រយោជន៍នៃអនាម័យ | ប្រជុំ | ២ | ភូមិ ត និងភូមិ ង | ៥០ | ៣០ | | | | | | | | | ■ | ■ | | |
| ៣.៣. | ផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ | បង្គន់ | ៣ | ភូមិ ត | ១៥ | ៧ | | | | | | | | | | ■ | ■ | |
| ៣.៤. | ផ្តល់ធុងចម្រោះទឹកស្អាត | ធុង | ៣ | ភូមិ ង | ១៥ | ៨ | | | | | | | | | | ■ | ■ | |
| ៤ | **ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ** | | | | | | | | | | | | | | | | | |
| ៤.១. | ពង្រឹងបណ្តាញការងារយេនឌ័រ និងកិច្ចការពារកុមារ | ប្រជុំ | ១ | សាលាឃុំ | ៣០ | ២០ | | | | | | | | | | ■ | | |
| ៤.២. | ផ្សព្វផ្សាយអំពី សារប្រយោជន៍នៃការបញ្ជូនកូនស្រីទៅរៀន | ប្រជុំ | ២ | ភូមិ ត និងភូមិ ឃ | ៩០ | ៧០ | | | | | | | | | ■ | ■ | | |
| ៤.៣. | គាំទ្រការធ្វើដំណើរដល់ជនរងគ្រោះទៅកាន់កន្លែងផ្តល់សេវាសង្គ្រោះ | នាក់ | ៣ | ភូមិ ច | ៣ | ៣ | | | | | | | | | | ■ | ■ | ■ |
| ៥ | **ការប្រជុំ និងតាមដានរបស់ គ.ក.ន.ក** | | | | | | | | | | | | | | | | | |
| ៥.១. | ការប្រជុំប្រចាំខែរបស់ គ.ក.ន.ក | ប្រជុំ | ១២ | សាលាឃុំ | ២៤០ | ១២០ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៥.២. | ការចុះតាមដានត្រួតពិនិត្យ | លើក | ១២ | | ១២ | ៦ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

ថ្ងៃទី........ ខែ............ ឆ្នាំ..................

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

ថ្ងៃទី........ ខែ............ ឆ្នាំ..................

មេឃុំ ចៅសង្កាត់

ឧទាហរណ៍

ទម្រង់ទី២ — ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..............................................

ក្រុង ស្រុក ខណ្ឌ : ..............................................

ឃុំ សង្កាត់ : ..............................................

## ផែនការថវិកាប្រចាំឆ្នាំ២០១០

## សម្រាប់ការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា | សរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | ការលើកកម្ពស់សុខភាពមាតា និងទារក | | | | | |
| ១.១. | ការប្រជុំ និងផ្សព្វផ្សាយអំពីសុខភាពមាតា | | | | 345,000 | |
| | *អាហារសម្រន់* | *នាក់* | 75 | 4,000 | 300,000 | |
| | *សម្ភារៈ និងឯកសារផ្សព្វផ្សាយ* | *ប្រជុំ* | 3 | 15,000 | 45,000 | |
| ១.២. | ការគាំទ្រស្ត្រីមានផ្ទៃពោះសម្រាលកូននៅមណ្ឌលសុខភាព | | | | 720,000 | |
| | *ថ្លៃធ្វើដំណើរទៅកាន់ និងត្រឡប់មកពីមណ្ឌលសុខភាព* | *នាក់* | 15 | 32,000 | 480,000 | |
| | *ថ្លៃអាហារនៅអំឡុងពេលសម្រាលកូននៅមណ្ឌលសុខភាព* | *នាក់.ថ្ងៃ* | 30 | 8,000 | 240,000 | |
| | សរុប | | | | 1,065,000 | |
| ២ | មត្តេយ្យសិក្សាសហគមន៍ | | | | | |
| ២.១. | ការប្រជុំរៀបចំមត្តេយ្យសិក្សាសហគមន៍ | | | | 345,000 | |
| | *អាហារសម្រន់* | *នាក់* | 75 | 4,000 | 300,000 | |
| | *សម្ភារៈ និងឯកសារផ្សព្វផ្សាយ* | *ប្រជុំ* | 3 | 15,000 | 45,000 | |
| ២.២. | កិច្ចដំណើរការមត្តេយ្យសហគមន៍ | | | | 580,000 | |
| | *ប្រាក់ឧបត្ថម្ភប្រចាំខែដល់គ្រូមត្តេយ្យសិក្សាសហគមន៍* | *នាក់.ខែ* | 10 | 50,000 | 500,000 | |
| | *សម្ភារៈ និងឧបករណ៍* | *ខែ* | 10 | 8,000 | 80,000 | |
| | សរុប | | | | 925,000 | |
| ៣ | ការលើកកម្ពស់អនាម័យនៅមូលដ្ឋាន | | | | | |
| ៣.១. | ការប្រជុំ ការផ្សព្វផ្សាយ និងទិវាអំពីអនាម័យនៅមូលដ្ឋាន | | | | 345,000 | |
| | *អាហារសម្រន់* | *នាក់* | 75 | 4,000 | 300,000 | |
| | *សម្ភារៈ និងឯកសារផ្សព្វផ្សាយ* | *ប្រជុំ* | 3 | 15,000 | 45,000 | |
| ៣.២. | ការផ្ដល់សម្ភារៈសម្រាប់ការងារអនាម័យ | | | | 360,000 | |
| | *ផ្ដល់សម្ភារៈសម្រាប់ការសាងសង់បង្គន់អនាម័យ* | *គ្រឿង* | 3 | 80,000 | 240,000 | |
| | *ផ្ដល់ធុងចម្រោះទឹកស្អាត* | *ធុង* | 3 | 40,000 | 120,000 | |
| | សរុប | | | | 705,000 | |

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា | សរុប |ផ្សេងៗ |
|---|---|---|---|---|---|---|
| ៤ | ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ | | | | | |
| ៤.១. | ការប្រជុំ និងផ្សព្វផ្សាយការងារយេនឌ័រនិងកិច្ចការពារកុមារ | | | | 525,000 | |
| | *អាហារសម្រន់* | *នាក់* | 120 | 4,000 | 480,000 | |
| | *សម្ភារៈ និងឯកសារផ្សព្វផ្សាយ* | *ប្រជុំ* | 3 | 15,000 | 45,000 | |
| ៤.២. | ការគាំទ្រថ្លៃធ្វើដំណើរជនរងគ្រោះទៅកន្លែងផ្តល់សេវាសង្គ្រោះ | | | | 48,000 | |
| | *ថ្លៃធ្វើដំណើររបស់ជនរងគ្រោះទៅកាន់កន្លែងផ្តល់សេវាសង្គ្រោះ* | *នាក់* | 3 | 16,000 | 48,000 | |
| សរុប | | | | | 573,000 | |
| ៥ | កិច្ចដំណើរការ និងការប្រជុំរបស់ គ.ក.ន.ក | | | | | |
| | *ការរៀបចំប្រជុំ (អាហារសម្រន់ និងឯកសារ)* | *ប្រជុំ* | 12 | 16,000 | 192,000 | |
| | *សម្ភារៈការិយាល័យ* | *ខែ* | 12 | 16,000 | 192,000 | |
| | *ថ្លៃធ្វើដំណើរ គ.ក.ន.ក ប្រជុំទៅឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ* | *រូម* | 1 | 416,000 | 416,000 | |
| | សរុប | | | | 800,000 | |
| | សរុបរួម | | | | 4,068,000 | |

ថ្ងៃទី......... ខែ............ ឆ្នាំ...................

ស្មៀនឃុំ សង្កាត់

ថ្ងៃទី......... ខែ............... ឆ្នាំ..................

មេឃុំ ចៅសង្កាត់

**ខ). ការរៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំត្រីមាស**

ផ្អែកលើផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវជួយ គ.ក.ន.ក ក្នុងការរៀបចំផែនការសកម្មភាពប្រចាំត្រីមាស (ទម្រង់ទី៣) និងផែនការថវិកាប្រចាំត្រីមាស (ទម្រង់ទី៤) រួចដាក់ទៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ន.ក ដើម្បីពិនិត្យ និងបែងចែកការទទួលខុសត្រូវដល់សមាជិក គ.ក.ន.ក ។

ឧទាហរណ៍

ទម្រង់ទី៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :.......................

ក្រុង ស្រុក ខណ្ឌ :....................

ឃុំ សង្កាត់ :.........................

# ផែនការសកម្មភាពប្រចាំត្រីមាសទី៤ ឆ្នាំ២០១០

## ស្តីពីការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

| ល.រ | សកម្មភាព និងលទ្ធផល | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | តុលា | | | | វិច្ឆិកា | | | | ធ្នូ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
| ១ | **ការលើកកម្ពស់សុខភាពមាតា** | | | | | | | | | | | | | | | | | |
| ១.២. | ផ្សព្វផ្សាយអំពី ការថែទាំការពារដល់ស្ត្រីមានផ្ទៃពោះ និងកុមារ | ប្រជុំ | ១ | ភូមិ ក | ៥០ | ៣៥ | | | ■ | | | | | | | | | |
| ១.៣. | គាំទ្រការធ្វើដំណើរសម្រាប់សម្រាលកូនទៅមណ្ឌលសុខភាព | នាក់ | ១០ | ភូមិ ខ និងភូមិ គ | ១០ | ១០ | | | | | | ■ | | | | | | |
| ១.៤. | ផ្តល់អាហារដល់ស្ត្រីក្នុងរយៈពេលសម្រាលកូននៅមណ្ឌលសុខភាព | នាក់.ថ្ងៃ | ១៦ | ភូមិ ខ និងភូមិ គ | ៨ | ៨ | | | | | | | ■ | | | | | |
| ២ | **ការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍** | | | | | | | | | | | | | | | | | |
| ២.៥. | ដំណើរការអនុវត្តមត្តេយ្យសិក្សាសហគមន៍ | ខែ | ៣ | ភូមិ ក | ២៥ | ១៣ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៣ | **ការលើកកម្ពស់អនាម័យនៅមូលដ្ឋាន** | | | | | | | | | | | | | | | | | |
| ៣.១. | ពង្រឹងបណ្តាញការងារអនាម័យនៅមូលដ្ឋាន | ប្រជុំ | ១ | សាលាឃុំ | ២៥ | ១៥ | | ■ | | | | | | | | | | |
| ៣.២. | ផ្សព្វផ្សាយអំពី សារប្រយោជន៍នៃអនាម័យ | ប្រជុំ | ១ | ភូមិ ង | ៥០ | ៣០ | | | | | ■ | | | | | | | |
| ៣.៣. | ផ្តល់សម្ភារៈសាងសង់បង្គន់អនាម័យ | បង្គន់ | ៣ | ភូមិ គ | ១៥ | ៧ | | | | | | | ■ | | | | | |
| ៣.៤. | ផ្តល់ធុងចម្រោះទឹកស្អាត | ធុង | ៣ | ភូមិ ង | ១៥ | ៨ | | | | | | | ■ | | | | | |

| ល.រ | សកម្មភាព និងលទ្ធផល | លទ្ធផលគ្រោង | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | តុលា | | | | វិច្ឆិកា | | | | ធ្នូ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
| ៤ | ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ | | | | | | | | | | | | | | | | | |
| ៤.១. | ពង្រឹងបណ្តាញការងារយេនឌ័រ និងកិច្ចការពារកុមារ | ប្រជុំ | ១ | សាលាឃុំ | ៣០ | ២០ | | | | | ■ | | | | | | | |
| ៤.២. | ផ្សព្វផ្សាយអំពី សារប្រយោជន៍នៃការបញ្ជូនកូនស្រីទៅរៀន | ប្រជុំ | ២ | ភូមិ ត និងភូមិ យ | ៤០ | ៧០ | | | | | | ■ | | | | | | |
| ៤.៣. | គាំទ្រការធ្វើដំណើរដល់ជនរងគ្រោះទៅកាន់កន្លែងផ្តល់សេវាសង្គ្រោះ | នាក់ | ៣ | ភូមិ ច | ៣ | ៣ | | | | ■ | | | ■ | | | ■ | | |
| ៥ | ការប្រជុំ និងតាមដានរបស់ គ.ក.ន.ក | | | | | | | | | | | | | | | | | |
| ៥.១. | ការប្រជុំប្រចាំខែរបស់ គ.ក.ន.ក | ប្រជុំ | ៣ | សាលាឃុំ | ៤០ | ៣០ | | | | ■ | | | | ■ | | | | ■ |
| ៥.២. | ការចុះតាមដានត្រួតពិនិត្យ | លើក | ៣ | | ៣ | ២ | | | ■ | | | | ■ | | | | ■ | |

ថ្ងៃទី......... ខែ.................. ឆ្នាំ..................

**អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ**

ថ្ងៃទី......... ខែ.................. ឆ្នាំ..................

**មេឃុំ ចៅសង្កាត់**

**ឧទាហរណ៍**

**ទម្រង់ទី៤**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត :** ..............................................

**ក្រុង ស្រុក ខណ្ឌ :** ..............................................

**ឃុំ សង្កាត់ :** ..............................................

## ផែនការថវិកាប្រចាំត្រីមាសទី៤ ឆ្នាំ២០១០

## សម្រាប់ការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា | សរុប |ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | **ការលើកកម្ពស់សុខភាពមាតា និងទារក** | | | | | |
| *១.១.* | *ផ្សព្វផ្សាយអំពី ការចាក់ថ្នាំការពារដល់ស្ត្រី និងកុមារ* | | | | 130,000 | |
| | *អាហារសម្រន់* | *នាក់* | 30 | 4,000 | 120,000 | |
| | *សម្ភារៈ និងឯកសារផ្សព្វផ្សាយ* | *ប្រជុំ* | 1 | 10,000 | 10,000 | |
| *១.២.* | *ការគាំទ្រស្ត្រីមានផ្ទៃពោះសម្រាលកូននៅមណ្ឌលសុខភាព* | | | | 448,000 | |
| | *ថ្លៃធ្វើដំណើរទៅកាន់ និងត្រឡប់មកពីមណ្ឌលសុខភាព* | *នាក់* | 10 | 32,000 | 320,000 | |
| | *ថ្លៃអាហារនៅអំឡុងពេលសម្រាលកូននៅមណ្ឌលសុខភាព* | *នាក់.ថ្ងៃ* | 16 | 8,000 | 128,000 | |
| **សរុប** | | | | | 578,000 | |
| ២ | **មត្តេយ្យសិក្សាសហគមន៍** | | | | | |
| *២.២.* | *កិច្ចដំណើរការមត្តេយ្យសហគមន៍* | | | | 174,000 | |
| | *ប្រាក់ឧបត្ថម្ភប្រចាំខែដល់គ្រូមត្តេយ្យសិក្សាសហគមន៍* | *នាក់.ខែ* | 3 | 50.000 | 150,000 | |
| | *សម្ភារៈ និងឧបករណ៍* | *ខែ* | 3 | 8,000 | 24,000 | |
| **សរុប** | | | | | 174,000 | |
| ៣ | **ការលើកកម្ពស់អនាម័យនៅមូលដ្ឋាន** | | | | | |
| *៣.១.* | *ការប្រជុំ ការផ្សព្វផ្សាយ និងទិវាអំពីអនាម័យនៅមូលដ្ឋាន* | | | | 95,000 | |
| | *អាហារសម្រន់* | *នាក់* | 25 | 4,000 | 80.000 | |
| | *សម្ភារៈ និងឯកសារផ្សព្វផ្សាយ* | *ប្រជុំ* | 1 | 15,000 | 15,000 | |
| *៣.២.* | *ការផ្តល់សម្ភារៈសម្រាប់ការងារអនាម័យ* | | | | 360,000 | |
| | *ផ្តល់សម្ភារៈសម្រាប់ការសាងសង់បង្គន់អនាម័យ* | *គ្រឿង* | 3 | 80,000 | 240,000 | |
| | *ផ្តល់ធុងចម្រោះទឹកស្អាត* | *ធុង* | 3 | 40,000 | 120,000 | |
| **សរុប** | | | | | 455,000 | |

| ល.រ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃឯកតា | សរុប | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៤ | ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ | | | | | |
| ៤.១. | ការប្រជុំ និងផ្សព្វផ្សាយការងារយេនឌ័រនិងកិច្ចការពារកុមារ | | | | 525,000 | |
| | អាហារសម្រន់ | នាក់ | 30 | 4,000 | 480,000 | |
| | សម្ភារៈ និងឯកសារផ្សព្វផ្សាយ | ប្រជុំ | 3 | 15,000 | 45,000 | |
| ៤.២. | ការគាំទ្រថ្លៃធ្វើដំណើរជនរងគ្រោះទៅកន្លែងផ្តល់សេវាសង្គ្រោះ | | | | 48,000 | |
| | ថ្លៃធ្វើដំណើររបស់ជនរងគ្រោះទៅកាន់កន្លែងផ្តល់សេវាសង្គ្រោះ | នាក់ | 3 | 16,000 | 48,000 | |
| សរុប | | | | | 573,000 | |
| ៥ | កិច្ចដំណើរការ និងការប្រជុំរបស់ គ.ក.ន.ក | | | | | |
| | ការរៀបចំប្រជុំ (អាហារសម្រន់ និងឯកសារ) | ប្រជុំ | 3 | 16,000 | 48,000 | |
| | សម្ភារៈការិយាល័យ | ខែ | 3 | 16,000 | 48,000 | |
| | ថ្លៃធ្វើដំណើរ គ.ក.ន.ក ប្រជុំនៅឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ | រូប | 1 | 16,000 | 16,000 | |
| សរុប | | | | | 112,000 | |
| សរុបរួម | | | | | 1,892,000 | |

ថ្ងៃទី......... ខែ.................. ឆ្នាំ..................

ស្មៀនឃុំ សង្កាត់

ថ្ងៃទី......... ខែ.................. ឆ្នាំ..................

មេឃុំ ចៅសង្កាត់

## ២.២. ការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គម

### ២.២.១. ការអនុវត្តសកម្មភាពអប់រំផ្សព្វផ្សាយ

**ក). គោលបំណង**

ការអប់រំផ្សព្វផ្សាយ មានគោលបំណង បង្កើនការយល់ដឹង ដើម្បីធ្វើឱ្យការចូលរួមក្នុងការអនុវត្តសកម្មភាពលើកកម្ពស់សុខភាពមាតា និងទារក អនាម័យ ការអប់រំកុមារតូចនៅសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់កាន់តែមានប្រសិទ្ធិភាព សំដៅរួមចំណែកធ្វើឱ្យសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

**ខ). លក្ខខណ្ឌទូទៅ**

ការអប់រំផ្សព្វផ្សាយត្រូវពិចារណាលើលក្ខខណ្ឌមួយចំនួនដូចខាងក្រោម :

- ក្រុមគោលដៅ : ការកំណត់អ្នកចូលរួមវគ្គផ្សព្វផ្សាយ ត្រូវពិនិត្យទៅលើកម្រិតយល់ដឹង កម្រិតនៃការប្រតិបត្តិ និងបញ្ហាប្រឈមរបស់ក្រុមគោលដៅ ដើម្បីជួយតម្រង់ទិសអនុវត្តន៍ និងលើកកម្ពស់ស្ថានភាពក្រុមគោលដៅឱ្យកាន់តែប្រសើរឡើង។ គ.ក.ន.ក អាចកំណត់ក្រុមគោលដៅដោយពិនិត្យ និងពិចារណាទៅតាមប្រធានបទអប់រំផ្សព្វផ្សាយមួយចំនួនដូចខាងក្រោម :
  - សុខភាពមាតា និងទារក : ផ្តោតលើស្ត្រីមានផ្ទៃពោះ ឬស្ត្រីជាមាតា គ្រួសារ មានកូនតូច

  - អនាម័យ : ផ្តោតលើគ្រួសារដែលរស់នៅក្នុងភូមិ ឬតំបន់ដែលខ្វះអនាម័យខ្លាំង ពិសេសគ្រួសារដែលរស់នៅក្នុងតំបន់ដែលងាយបង្កបញ្ហាអនាម័យដល់ប្រភពទឹក
  - មត្តេយ្យសិក្សាសហគមន៍ : ផ្តោតលើគ្រួសារដែលមានកូនអាយុពី ៣ឆ្នាំ-៥ឆ្នាំ
  - សមភាពយេនឌ័រ : ផ្តោតលើគ្រួសារដែលមានអំពើហិង្សាក្នុងគ្រួសារ គ្រួសារដែលមានកូន ឬកូនស្រីពុំទាន់បានចូលរៀន និងស្ត្រីជាអ្នកដឹកនាំភូមិ
  - កិច្ចការពារកុមារ : ផ្តោតលើគ្រួសារដែលមានពលកម្មកុមារ ជនងាយរងគ្រោះ និងតំបន់ដែលមានការរំលោភបំពានលើកុមារ
- ទីកន្លែងផ្សព្វផ្សាយ : ជាការប្រសើរ ការអប់រំផ្សព្វផ្សាយគួររៀបចំនៅតាមភូមិរបស់ក្រុមគោលដៅ ឬប្រមូលផ្តុំនៅតំបន់ដែលក្រុមគោលដៅរស់នៅផ្ទាល់តែម្តង ឬធ្វើការផ្សព្វផ្សាយតាមគ្រួសារ ឬផ្ទះរបស់ក្រុមគោលដៅ (បើអាច) ។

គ). ការរៀបចំការផ្សព្វផ្សាយ

- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវជួយ គ.ក.ន.ក ក្នុងការរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យ និងកំណត់ប្រធានបទ និងកម្មវិធីដែលត្រូវធ្វើការផ្សព្វផ្សាយ (ទម្រង់ទី៥) ។
- បន្ទាប់មក គ.ក.ន.ក ត្រូវពិនិត្យអំពីលទ្ធភាពនៃធនធានមនុស្សសម្រាប់សម្របសម្រួលការផ្សព្វផ្សាយ ។ គ.ក.ន.ក អាចស្វែងរកធនធានមនុស្ស ដូចខាងក្រោម :
  - ចំពោះប្រធានបទ និងខ្លឹមសារផ្សព្វផ្សាយដែលឃុំ សង្កាត់អាចធ្វើការផ្សព្វផ្សាយដោយខ្លួនឯងបាន ឃុំ សង្កាត់គួរពិនិត្យ និងប្រើប្រាស់ធនធានមនុស្សក្នុងឃុំ សង្កាត់របស់ខ្លួន ដូចជា : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ភ្នាក់ងារសេវាសុខភាពសហគមន៍ អ្នកសម្របសម្រួលអនាម័យសហគមន៍ និងគ្រូមត្តេយ្យសិក្សាសហគមន៍ ។ល។
  - ពិនិត្យមើលគម្រោងនានាដែលបានព្រមព្រៀងក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ដោយមន្ទីរ ឬដៃគូអភិវឌ្ឍន៍នានា ទោះជាការសន្យានេះជាការសន្យាផ្តល់បច្ចេកទេសក៏ដោយ ដើម្បីស្វែងរកធនធានមនុស្សពីបណ្តាស្ថាប័នទាំងនោះសម្រាប់ជួយសម្របសម្រួលក្នុងការផ្សព្វផ្សាយ
  - ក្នុងករណីប្រធានបទ និងខ្លឹមសារផ្សព្វផ្សាយដែលឃុំ សង្កាត់ពុំមានធនធានមនុស្ស សម្រាប់សម្របសម្រួលក្នុងការផ្សព្វផ្សាយ គ.ក.ន.ក អាចដាក់បញ្ហានេះទៅក្នុងកិច្ចប្រជុំប្រចាំខែ ឬកិច្ចប្រជុំប្រចាំត្រីមាស គ.ក.ន.ក ដើម្បីស្វែងរកការគាំទ្រធនធានមនុស្សពីមណ្ឌលសុខភាព ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ សាលាបឋមសិក្សា ការិយាល័យស្រុក ឬមន្ទីរពាក់ព័ន្ធ ឬអង្គការមិនមែនរដ្ឋាភិបាល
- ទីចាត់ការផែនការ និងវិនិយោគអាចជួយសម្របសម្រួល និងទំនាក់ទំនងជាមួយ ការិយាល័យស្រុក មន្ទីរ ឬដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកការគាំទ្រពីបណ្តាស្ថាប័នទាំងនោះ
- គ.ក.ន.ក និងអ្នកដឹកនាំភូមិត្រូវរៀបចំ និងសម្របសម្រួលការងារនៅមូលដ្ឋាន ដូចជា ប្រមូលប្រជាពលរដ្ឋ រៀបចំទីកន្លែង សម្ភារៈ និងអាហារសម្រន់ ។ល ។

ឧទាហរណ៍

ទម្រង់ទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..................................

ក្រុង ស្រុក ខណ្ឌ : ..................................

ឃុំ សង្កាត់ : ..................................

## កម្មវិធីផ្សព្វផ្សាយ

១. ប្រធានបទផ្សព្វផ្សាយ: *ការថែរក្សាអនាម័យនៅមូលដ្ឋាន*

២. គោលបំណង : *បង្កើនការយល់ដឹង ដើម្បីពង្រឹងការចូលរួមក្នុងសកម្មភាពថែរក្សាអនាម័យនៅមូលដ្ឋាន*

៣. ក្រុមគោលដៅ : *ប្រជាពលរដ្ឋមកពីភូមិពន្លា ចំនួន ៣០នាក់*

៤. អ្នកសម្របសម្រួល : *អ្នកសម្របសម្រួលអនាម័យសហគមន៍ និងមន្ទីរអភិវឌ្ឍន៍ជនបទ*

៥. ទីកន្លែង : *ភូមិពន្លា*

៦. កាលបរិច្ឆេទ : *ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ វេលាព្រឹក ម៉ោង ០៨.០០ ដល់ ១១.០០*

៧. របៀបវារៈ:

| ពេលវេលា | សកម្មភាព | អ្នកសម្របសម្រួល |
|---|---|---|
| *០៨.០០-០៨.១០* | *ពិធីបើកវគ្គផ្សព្វផ្សាយ សេចក្តីផ្តើម និងការបង្ហាញពីគោលបំណង* | *លោក. ជា សុវណ្ណ* |
| *០៨.១០-០៨.៣០* | *បញ្ហា និងកត្តានាំឱ្យមានបញ្ហាអនាម័យនៅមូលដ្ឋាន* | *លោក. ជា សុវណ្ណ* |
| *០៨.៣០-០៩.០០* | *ជំងឺ និងផលវិបាកនានាដែលបង្កឡើងដោយការខ្វះអនាម័យ* | *លោកស្រី មាស តូច* |
| *០៩.០០-០៩.៣០* | *ដំណោះស្រាយសំខាន់ៗ ក្នុងការជួយលើកកម្ពស់អនាម័យ* | *លោកស្រី មាស តូច* |
| *០៩.៣០-០៩.៤៥* | *សម្រាកអាហារសម្រន់* | |
| *០៩.៤៥-១០.៣០* | *យន្តការ និងតួនាទីរបស់អ្នកពាក់ព័ន្ធសំខាន់ៗ* | *លោក សុខ ណា* |
| *១០.៣០-១០.៥០* | *ការរៀបចំផែនការសកម្មភាពក្នុងការថែរក្សាអនាម័យនៅមូលដ្ឋាន* | *លោក សុខ ណា* |
| *១០.៥០-១១.០០* | *ពិធីបិទវគ្គផ្សព្វផ្សាយ* | *លោក. ជា សុវណ្ណ* |

ថ្ងៃទី......... ខែ......... ឆ្នាំ.............

បានពិនិត្យ និងឯកភាព

ថ្ងៃទី......... ខែ......... ឆ្នាំ.............

មេឃុំ ចៅសង្កាត់

រៀបចំដោយ : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

ឃ). ការសម្របសម្រួលការអប់រំផ្សព្វផ្សាយ

ការផ្សព្វផ្សាយការលើកកម្ពស់សុខភាពមាតា និងទារក អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់អាចអនុវត្តន៍តាមមធ្យោបាយដូចខាងក្រោម ៖

- ឃុំ សង្កាត់ប្រើប្រាស់ធនធានមនុស្សរបស់ឃុំ សង្កាត់ ដូចជា អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ភ្នាក់ងារសេវាសុខភាពសហគមន៍ អ្នកសម្របសម្រួលអនាម័យសហគមន៍ និងគ្រូមត្តេយ្យសិក្សាសហគមន៍ ។ល។ ដើម្បីដឹកនាំ និងសម្របសម្រួលធ្វើការអប់រំផ្សព្វផ្សាយ
- មន្ទីរ ដៃគូអភិវឌ្ឍន៍ ឬស្ថាប័នពាក់ព័ន្ធនានាដែលបានគាំទ្រការអប់រំផ្សព្វផ្សាយរបស់ឃុំ សង្កាត់អាចគាំទ្រការផ្សព្វផ្សាយដូចខាងក្រោម ៖
  - ផ្តល់ការអប់រំផ្សព្វផ្សាយដោយផ្ទាល់ពីស្ថាប័នទាំងនោះទៅឱ្យប្រជាពលរដ្ឋនៅតាមភូមិ ឬឃុំ សង្កាត់ តាមកាលវិភាគដែលបានព្រមព្រៀងជាមួយឃុំ សង្កាត់
  - ផ្តល់វត្ថុធាតុទ្រទ្រង់ និងផ្តល់ជំនួយបច្ចេកទេសដល់ធនធានមនុស្សរបស់ឃុំ សង្កាត់ ដើម្បីធ្វើការផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋ
- ទីចាត់ការផែនការ និងវិនិយោគអាចជួយឃុំ សង្កាត់ក្នុងការទំនាក់ទំនង និងសម្របសម្រួលជាមួយមន្ទីរពាក់ព័ន្ធ ឬដៃគូអភិវឌ្ឍន៍នានា ដើម្បីផ្តល់ការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ។

ង). ការត្រួតពិនិត្យ និងជំរុញការអនុវត្ត

- អ្នកដឹកនាំភូមិ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវតាមដានត្រួតពិនិត្យការរៀបចំ និងការអនុវត្តការផ្សព្វផ្សាយ ដើម្បីធានាថា ការចូលរួមរបស់ប្រជាពលរដ្ឋ និងរៀបចំ និងដំណើរការអនុវត្តត្រូវបានអនុវត្តន៍តាមការគ្រោងទុក
- មន្ទីរ ដៃគូអភិវឌ្ឍន៍ ឬស្ថាប័នពាក់ព័ន្ធនានាត្រូវចុះតាមដានត្រួតពិនិត្យការអនុវត្តការផ្សព្វផ្សាយ ដើម្បីធានាថា ដំណើរការ និងខ្លឹមសារត្រូវបានអនុវត្តតាមការគ្រោងទុក
- អ្នកដឹកនាំភូមិ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ តាមដានត្រួតពិនិត្យអំពីការអនុវត្តចំណេះដឹងទទួលបានពីវគ្គផ្សព្វផ្សាយ និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យផ្សព្វផ្សាយបន្ត ។

### ២.២.២. ការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារដល់ស្ត្រីមានផ្ទៃពោះ

ក). គោលបំណង

ការគាំទ្រមធ្យោបាយធ្វើដំណើរ និងអាហារមានគោលបំណង ជួយដល់ស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេឱ្យទទួលបានការសម្រាលកូនប្រកបដោយសុវត្ថិភាពនៅមណ្ឌលសុខភាព ។

ខ). លក្ខខណ្ឌនៃការគាំទ្រ

ការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារសម្រាប់ស្ត្រីមានផ្ទៃពោះត្រូវផ្អែកលើលក្ខខណ្ឌមួយចំនួនដូចខាងក្រោម ៖

- ស្ត្រីមានផ្ទៃពោះដែលគ្រួសារមានជីវភាពក្រីក្រជាងគេ ស្ត្រីជាមេគ្រួសារ ហើយរស់នៅក្នុងភូមិឆ្ងាយដាច់ស្រយាល ឬភូមិដែលពុំមានសេវាសុខភាពគ្រប់គ្រាន់
- ការគាំទ្រមធ្យោបាយធ្វើដំណើរត្រូវផ្តល់សម្រាប់ការធ្វើដំណើរទៅមក ដើម្បីទទួលសេវាសម្រាលកូននៅមណ្ឌលសុខភាពដែលនៅជិតបំផុត
- ការផ្តល់អាហារសម្រាប់តែអំឡុងពេលសម្រាកនៅមណ្ឌលសុខភាព ពេលរង់ចាំការសម្រាល ពេលសម្រាល ឬពេលរង់ចាំចាកចេញពីមណ្ឌលសុខភាព
- ស្ត្រីមានផ្ទៃពោះដែលស្ថិតក្នុងបញ្ជីត្រូវផ្តល់អាទិភាពក្នុងការគាំទ្រ លើកលែងតែករណីសង្គ្រោះបន្ទាន់។
- ការផ្តល់ជាថវិកាសម្រាប់មធ្យោបាយធ្វើដំណើរ ឬនិង អាហារអាចផ្តល់ឱ្យក្នុងតម្លៃមួយសមស្រប ហើយថវិកាដែលផ្តល់ឱ្យមិនមានតម្លៃស្មើគ្នាទាំងអស់នោះទេ វាអាស្រ័យលើលទ្ធភាពគាំទ្រ និងការចំណាយជាក់ស្តែង។

ក). ដំណើរការនៃការផ្តល់គាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារ

ក.១). ផ្សព្វផ្សាយព័ត៌មាន

ការផ្សព្វផ្សាយព័ត៌មានអំពី ការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង ការផ្តល់អាហារដល់ស្ត្រីមានផ្ទៃពោះដើម្បីសម្រាលកូននៅមណ្ឌលសុខភាពត្រូវធ្វើឡើងឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់។ ការផ្សព្វផ្សាយអាចធ្វើឡើងតាមរយៈ :

- អ្នកដឹកនាំភូមិ ឬភ្នាក់ងារសេវាសុខភាពសហគមន៍ចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមផ្ទះ
- អ្នកដឹកនាំភូមិ ឬភ្នាក់ងារសេវាសុខភាពសហគមន៍រៀបចំជាកិច្ចប្រជុំជាមួយប្រជាពលរដ្ឋតាមភូមិនីមួយៗ
- មេឃុំ ចៅសង្កាត់ត្រូវបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មានឃុំ សង្កាត់ និងទីសាធារណៈតាមភូមិ។

ក.២). ស្រង់ទិន្នន័យស្ត្រីមានផ្ទៃពោះ

- ភ្នាក់ងារសេវាសុខភាពសហគមន៍ និងអ្នកដឹកនាំភូមិត្រូវស្រង់ទិន្នន័យស្ត្រីដែលមានផ្ទៃពោះតាមភូមិនីមួយៗ និងស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេ និងពេលវេលាដែលត្រូវសម្រាលកូន
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវធ្វើការបូកសរុបចំនួនស្ត្រីមានផ្ទៃពោះ (ទម្រង់ទី៦) និងដាក់ជូនកិច្ចប្រជុំ គ.ក.ន.ក ដើម្បីកំណត់ស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេ និងពិនិត្យលទ្ធភាពសម្រាប់ការផ្តល់ការគាំទ្រ
- បន្ទាប់មក អ្នកដឹកនាំភូមិ ឬភ្នាក់ងារសេវាសុខភាពសហគមន៍ត្រូវផ្តល់ព័ត៌មានដល់ស្ត្រីមានផ្ទៃពោះអំពីលទ្ធភាពនៃការគាំទ្ររបស់ឃុំ សង្កាត់ និងលក្ខខ័ណ្ឌនានា ដែលអាចទទួលបានការគាំទ្រ។ ការពិចារណាអំពីលទ្ធភាពក្នុងការគាំទ្រ ផ្តោតជាចម្បងចំពោះស្ត្រីមានផ្ទៃពោះ ជិតដល់ខែសម្រាល (ក្នុងអំឡុងពេលខែទី៨ ឬខែទី៩) លើកលែងតែការសង្គ្រោះបន្ទាន់។

ឧទាហរណ៍

ទម្រង់ទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..........................................
ក្រុង ស្រុក ខណ្ឌ : ....................................
ឃុំ សង្កាត់ : ..................................................

### ទិន្នន័យស្ត្រីមានផ្ទៃពោះតាមភូមិនីមួយៗ ប្រចាំខែកញ្ញា ឆ្នាំ២០១០

| ល.រ | ភូមិ | ចំនួនស្ត្រីមានផ្ទៃពោះ តាមខែមានផ្ទៃពោះ | | | | | | | | | សរុប | ចំនួនស្ត្រីក្រីក្រជាងគេ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | | | |
| ១ | ភូមិមានជ័យត្បូង | | | | | | | ១ | ១ | ១ | ៣ | ២ | |
| ២ | ភូមិមានជ័យជើង | | | | | | ១ | ១ | ១ | ១ | ៤ | ១ | |
| ៣ | ភូមិមិត្តភាពកើត | | | | | | ១ | ១ | | | ២ | 0 | |
| ៤ | ភូមិមិត្តភាពលិច | | | | | | | ១ | | | ១ | 0 | |
| សរុប | | | | | | | ២ | ៤ | ២ | ២ | ១០ | ៣ | |

ថ្ងៃទី......... ខែ......... ឆ្នាំ..............
រៀបចំដោយ : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

បានពិនិត្យ និងឯកភាព
ថ្ងៃទី......... ខែ......... ឆ្នាំ..............
មេឃុំ ចៅសង្កាត់

គ.៣). ការស្នើសុំការគាំទ្រ

ការស្នើសុំការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង ការផ្តល់អាហារដល់ស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ (ទម្រង់ទី៧) ដោយ :

- សាមីខ្លួន ឬក្រុមគ្រួសារអាចធ្វើការស្នើសុំការគាំទ្រដោយផ្ទាល់ទៅមេឃុំ ចៅសង្កាត់ ឬតាមរយៈអ្នកដឹកនាំភូមិ ឬសមាជិក គ.ក.ន.ក
- គ.ក.ន.ក អ្នកដឹកនាំភូមិ ឬភ្នាក់ងារសេវាសុខភាពសហគមន៍ ក៏អាចជួយក្នុងការសម្របសម្រួលក្នុងការរៀបចំពាក្យស្នើសុំផងដែរ ក្នុងករណីមានការស្នើសុំពីសាមីខ្លួន
- ការស្នើសុំការគាំទ្រធ្វើឡើងឱ្យបានមុនពេលសម្រាលកូន លើកលែងតែករណីសង្គ្រោះបន្ទាន់។

ឧទាហរណ៍

ទម្រង់ទី៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សំណើសុំ

ខ្ញុំបាទ នាងខ្ញុំឈ្មោះ ....*ចាន់ រាសនា*.... ភេទ ...*ស្រី*... សញ្ជាតិ ...*ខ្មែរ*... ឆ្នាំកំណើត ...*១៩៧៥*... អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ...*០១០០៣៥១១៥*... មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ...*១៣២*... ផ្លូវលេខ ... *២២១*.... ឃុំ សង្កាត់ ..*មានជ័យ*... ក្រុង ស្រុក ខណ្ឌ............... រាជធានី ខេត្ត.................................។

គោរពជូន

លោក លោកស្រីមេឃុំ ចៅសង្កាត់ មានជ័យ

**កម្មវត្ថុ :** សំណើសុំ....*ជួយផ្តល់មធ្យោបាយធ្វើដំណើរ និងថ្លៃអាហារសម្រាប់ការសម្រាលកូននៅមណ្ឌល*........។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ នាងខ្ញុំសូមជម្រាបជូនលោក លោកស្រីមេឃុំ ចៅសង្កាត់មេត្តាជ្រាបថា ដោយសារគ្រួសាររបស់ខ្ញុំបាទ នាងខ្ញុំមានជីវភាពខ្វះខាត និងពុំមានថវិកាសម្រាប់..*ថ្លៃធ្វើដំណើរ និងថ្លៃអាហារក្នុងពេលសម្រាលកូននៅមណ្ឌលសុខភាពមានជ័យ ដែលនឹងសម្រាលនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០*..។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំ ចៅសង្កាត់មេត្តាពិនិត្យ និងផ្តល់ការគាំទ្រដល់ខ្ញុំបាទ នាងខ្ញុំដោយអនុគ្រោះ ។

សូមលោក លោកស្រីមេឃុំ ចៅសង្កាត់មេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំបាទ នាងខ្ញុំ។

ថ្ងៃទី*២៥* ខែ*កញ្ញា* ឆ្នាំ*២០១០*

**អ្នកស្នើសុំ**

*( ហត្ថលេខា ឬស្នាមមេដៃស្តាំ*

គ.៤). ការប្រជុំពិនិត្យសម្រេច

- ក្រោយពីទទួលបានសំណើសុំពីស្ត្រីមានផ្ទៃពោះ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវចុះពិនិត្យអំពីស្ថានភាពគ្រួសារដែលបានស្នើសុំ ដើម្បីជួយ គ.ក.ន.ក ក្នុងការសម្រេចចិត្តឱ្យបានត្រឹមត្រូវ
- គ.ក.ន.ក ត្រូវរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យសំណើសុំ និងធ្វើការសម្រេចផ្តល់ការគាំទ្រដល់ស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេ ( ទម្រង់ទី៨) ។ អ្នកដឹកនាំភូមិ ឬភ្នាក់ងារសេវាសុខភាពសហគមន៍ ក៏ត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំ ដើម្បីផ្តល់យោបល់ផងដែរ

- បន្ទាប់មក អ្នកដឹកនាំភូមិ ឬភ្នាក់ងារសេវាសុខភាពសហគមន៍ត្រូវផ្តល់ព័ត៌មានអំពីលទ្ធផលនៃការសម្រេចរបស់ គ.ក.ន.ក ដល់ស្ត្រីមានផ្ទៃពោះ។ ករណីមិនបានផ្តល់ការគាំទ្រដល់ស្ត្រីដែលមានផ្ទៃពោះត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។ ការឆ្លើយតបចំពោះការស្នើសុំត្រូវធ្វើឡើងជាបន្ទាន់ ដើម្បីធានាថាការផ្តល់ការគាំទ្របានទាន់ពេលវេលា
- ករណីសង្គ្រោះបន្ទាន់ មេឃុំ ចៅសង្កាត់អាចធ្វើការសម្រេចដោយពុំចាំបាច់ឆ្លងកាត់ការប្រជុំ ឬមានពាក្យស្នើសុំឡើយ។ ទោះជាយ៉ាងនេះក្តី មេឃុំ ចៅសង្កាត់ត្រូវផ្តល់ព័ត៌មានអំពីករណីនេះនៅក្នុងកិច្ចប្រជុំ គ.ក.ន.ក ហើយសាមីខ្លួនត្រូវរៀបចំពាក្យស្នើសុំការគាំទ្រនៅពេលបន្ទាប់។

ឧទាហរណ៍

ទម្រង់ទី៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ....................................

ក្រុង ស្រុក ខណ្ឌ : ................................

ឃុំ សង្កាត់ : .......................................

ចញ្ជីឈ្មោះស្ត្រីមានផ្ទៃពោះទទួលបានការគាំទ្រប្រចាំខែវិច្ឆិកា

| លរ | ឈ្មោះ | ថ្ងៃខែឆ្នាំគ្រោងសម្រាល | សម្រេចផ្តល់ការគាំទ្រ (រៀល) | | ចំណាយសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ធ្វើដំណើរ | អាហារ | | |
| ១ | មាស មករា | ០៥/០៩/២០១០ | ៣០.០០០ | ២០.០០០ | ៥០.០០០ | ភូមិមានជ័យត្បូង |
| ២ | សុខ វណ្ណា | ១០/០៩/២០១០ | | ២០.០០០ | ២០.០០០ | ភូមិមានជ័យជើង |
| ៣ | ប្រាក់ សុវណ្ណ | ១៥/០៩/២០១០ | ២៥.០០០ | | ២៥.០០០ | ភូមិមានជ័យជើង |
| សរុប | | | ៥៥.០០០ | ៦០.០០០ | ៩៥.០០០ | |

ថ្ងៃទី......... ខែ......... ឆ្នាំ.............

បានពិនិត្យ និងឯកភាព

ថ្ងៃទី......... ខែ......... ឆ្នាំ.............

មេឃុំ ចៅសង្កាត់

រៀបចំដោយ : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

គ.៥). ការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិងអាហារ

ការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារ ឃុំ សង្កាត់អាចធ្វើឡើងតាមមធ្យោបាយដូចខាងក្រោម :

- រៀបចំជាមធ្យោបាយធ្វើដំណើរដល់ស្ត្រីមានផ្ទៃពោះ ដូចជា ម៉ូតូឌុប និងរ៉ឺម៉ក ។ល។
- រៀបចំផ្តល់ជាកញ្ចប់អាហារដល់ស្ត្រីមានផ្ទៃពោះ ដូចជា អង្ករ និងត្រីខកំប៉ុង ។ល។
- ផ្តល់ជាថវិកា ដើម្បីឱ្យស្ត្រីមានផ្ទៃពោះរៀបចំចាត់ចែងមធ្យោបាយធ្វើដំណើរ ឬទិញអាហាររបស់ខ្លួនដោយខ្លួនឯង។

ឃ). ការត្រួតពិនិត្យ និងការជំរុញការអនុវត្ត

- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អ្នកដឹកនាំភូមិ ឬភ្នាក់ងារសេវាសុខភាពសហគមន៍ត្រូវទំនាក់ទំនងជាមួយអ្នកផ្តល់សេវាដឹកជញ្ជូន ដើម្បីធានាថា ការផ្តល់សេវាដឹកជញ្ជូនបានទាន់ពេលវេលា
- មេឃុំ ចៅសង្កាត់ និង គ.ក.ន.ក ត្រូវទំនាក់ទំនង និងផ្តល់ព័ត៌មានដល់មណ្ឌលសុខភាព ដើម្បីធានាថាមណ្ឌលសុខភាពផ្តល់សេវាដល់ស្ត្រីមានផ្ទៃពោះជាប្រចាំ និងទាន់ពេលវេលា
- មេឃុំ ចៅសង្កាត់ត្រូវតាមដានត្រួតពិនិត្យដំណើរការអនុវត្ត ដើម្បីធានាថា ការគាំទ្របានធ្វើឡើងប្រកបដោយតម្លាភាពទាន់ពេលវេលា ការចំណាយអនុវត្តន៍តាមនីតិវិធី និងរៀបចំកិច្ចបញ្ជីកាត្រឹមត្រូវតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។

## ២.២.៣. ការចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ

ក). គោលបំណង

ការចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ មានគោលបំណងបង្កើនការអនុវត្តអនាម័យផ្ទាល់ខ្លួន និងអនាម័យបរិស្ថាន ដើម្បីឈានទៅបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល។

ខ). លក្ខខណ្ឌនៃការគាំទ្រ

ការផ្តល់សម្ភារៈបង្គន់អនាម័យត្រូវមានលក្ខខណ្ឌមួយចំនួនដូចខាងក្រោម :

- គ្រួសារមានជីវភាពក្រីក្រជាងគេ ស្ត្រីជាមេគ្រួសារ ជនងាយរងគ្រោះ និងងាយបង្កបញ្ហាអនាម័យដល់ប្រភពទឹកប្រើប្រាស់ និងទីសាធារណៈ
- ផ្តល់សម្ភារៈមួយចំនួនតែប៉ុណ្ណោះ មិនត្រូវផ្តល់ជាថវិកាឡើយ
- គ្រួសារដែលទទួលបានការគាំទ្រត្រូវបំពេញបន្ថែមនូវរាល់សម្ភារៈចាំបាច់នានា ដើម្បីធានាថា អាចបញ្ចប់ការសាងសង់ទាំងមូលបាន និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព
- ការផ្តល់សម្ភារៈអាចផ្តល់ឱ្យសាលារៀនបឋមសិក្សា ឬមត្តេយ្យសិក្សាសហគមន៍ផងដែរ
- ការផ្តល់សម្ភារៈមិនត្រូវបង្កជាឧបសគ្គដល់ការស្ម័គ្រចិត្តចូលរួមសាងសង់បង្គន់របស់ប្រជាពលរដ្ឋឡើយ។

គ). ដំណើរការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យតាមគ្រួសារ

គ.១). ប្រមូលព័ត៌មានអំពីការប្រើប្រាស់បង្គន់អនាម័យក្នុងឃុំ សង្កាត់

- អ្នកសម្របសម្រួលអនាម័យសហគមន៍ និងអ្នកដឹកនាំភូមិត្រូវស្រង់ទិន្នន័យអំពីគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ និងពុំមានបង្គន់អនាម័យប្រើប្រាស់តាមភូមិនីមួយៗ រួចបញ្ជូនមក គ.ក.ន.ក
- បន្ទាប់មក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ធ្វើការបូកសរុបចំនួនគ្រួសារ ដែលពុំមានបង្គន់អនាម័យប្រើប្រាស់ និងគ្រួសារដែលក្រីក្រជាងគេ (ទម្រង់ទី៩) ដើម្បីដាក់ជូន គ.ក.ន.ក ពិនិត្យលទ្ធភាពក្នុងការគាំទ្រ និងដោះស្រាយ។

ឧទាហរណ៍

ទម្រង់ទី៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..........................................
ក្រុង ស្រុក ខណ្ឌ : ......................................
ឃុំ សង្កាត់ : ..................................................

ទិន្នន័យនៃការប្រើប្រាស់បង្គន់អនាម័យតាមគ្រួសារក្នុងឆ្នាំ ២០១០

| លរ | ឈ្មោះភូមិ | ចំនួនគ្រួសារក្នុងភូមិនីមួយៗ | | ចំនួនគ្រួសារក្រីក្រជាងគេគ្មានបង្គន់ | ផ្សេងៗ |
|---|---|---|---|---|---|
| | | សរុប | គ្មានបង្គន់អនាម័យ | | |
| ១ | ភូមិសំរោងក្រោម | ១៥០ | ៥០ | ៥ | |
| ២ | ភូមិសំរោងលើ | ២០០ | ៦០ | ៦ | |
| ៣ | ភូមិថ្នល់បត់ជើង | ២៧០ | ៧០ | ៧ | |
| ៤ | ភូមិថ្នល់បត់ត្បូង | ៣០០ | ៨០ | ៨ | |
| សរុប | | ៩២០ | ២៦០ | ២៦ | |

ថ្ងៃទី......... ខែ......... ឆ្នាំ..............
រៀបចំដោយ : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

បានពិនិត្យ និងឯកភាព
ថ្ងៃទី......... ខែ......... ឆ្នាំ..............
មេឃុំ ចៅសង្កាត់

គ.២). ការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ

- គ.ក.ន.ក រៀបចំកិច្ចប្រជុំជាមួយអ្នកសម្របសម្រួលអនាម័យសហគមន៍ និងអ្នកដឹកនាំភូមិ ដើម្បីពិភាក្សាកំណត់នូវលទ្ធភាព វិធីសាស្ត្រ និងផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍នៃការបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ដើម្បីជំរុញប្រជាពលរដ្ឋស្ម័គ្រចិត្តសាងសង់បង្គន់អនាម័យតាមគ្រួសារ និងលទ្ធភាពនៃការគាំទ្រសម្ភារៈមួយចំនួនដល់គ្រួសារក្រីក្រជាងគេ
- អ្នកសម្របសម្រួលអនាម័យសហគមន៍ និងអ្នកដឹកនាំភូមិពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដែលពុំមានបង្គន់អនាម័យប្រើប្រាស់ ដើម្បីកំណត់លទ្ធភាពនៃការសាងសង់បង្គន់អនាម័យ និងការព្រមព្រៀងសាងសង់បង្គន់អនាម័យតាមគ្រួសារ ពិសេសគ្រួសារក្រីក្រជាងគេ។ ការពិគ្រោះយោបល់អាចធ្វើតាមមធ្យោបាយដូចខាងក្រោម :

- អ្នកសម្របសម្រួលអនាម័យសហគមន៍ និងអ្នកដឹកនាំភូមិអាចរៀបចំប្រជុំជាមួយប្រជាពលរដ្ឋតាមភូមិ
- អ្នកសម្របសម្រួលអនាម័យសហគមន៍ និងអ្នកដឹកនាំភូមិអាចពិភាក្សាជាមួយប្រជាពលរដ្ឋតាមផ្ទះ

- អ្នកសម្របសម្រួលអនាម័យសហគមន៍ និងអ្នកដឹកនាំភូមិរៀបចំបញ្ជីគ្រួសារ ដែលបានព្រមព្រៀងសាងសង់បង្គន់អនាម័យ និងគ្រួសារក្រីក្រជាងគេ
- គ.ក.ន.ក ត្រូវរៀបចំកិច្ចប្រជុំពិភាក្សា ដើម្បីពិនិត្យលទ្ធភាពគាំទ្រសម្ភារៈបង្គន់អនាម័យដល់គ្រួសារក្រីក្រជាងគេ (ទម្រង់ទី១០)។ អ្នកសម្របសម្រួលអនាម័យភូមិ និងអ្នកដឹកនាំភូមិត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះផងដែរ។ គ.ក.ន.ក ត្រូវពិចារណាឱ្យបានល្អិតល្អន់ក្នុងការសម្រេចចិត្តផ្តល់សម្ភារៈបង្គន់អនាម័យដល់គ្រួសារក្រីក្រជាងគេ ដើម្បីជៀសវាងការជះឥទ្ធិពលអវិជ្ជមានដល់គ្រួសារដែលស្ម័គ្រចិត្តចូលរួមក្នុងការសាងសង់បង្គន់អនាម័យ។

ឧទាហរណ៍

ទម្រង់ទី១០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..........................................
ក្រុង ស្រុក ខណ្ឌ : ..................................
ឃុំ សង្កាត់ : ..............................................

ប្រជាពលរដ្ឋចូលរួមសាងសង់បង្គន់អនាម័យ ឆ្នាំ២០១០

| លរ | ភូមិ | ចំនួនគ្មានបង្គន់អនាម័យ | ចំនួនគ្រួសារព្រមព្រៀងសង់បង្គន់ | | លទ្ធភាពគាំទ្រ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | សរុប | ត្រូវការគាំទ្រ | បានបង្គន់ | លូ | |
| ១ | ភូមិសំរោងក្រោម | ៥០ | ២៥ | ៥ | ៥ | | |
| ២ | ភូមិសំរោងលើ | ៦០ | ៣០ | ៦ | | ១២ | |
| ៣ | ភូមិថ្នល់បត់ជើង | ៧៥ | ៣៥ | ៧ | ៧ | | |
| ៤ | ភូមិថ្នល់បត់ត្បូង | ៨០ | ៤០ | ៨ | | ១៦ | |
| សរុប | | ២៦៥ | ១៣០ | ២៦ | ១២ | ២៨ | |

ថ្ងៃទី......... ខែ......... ឆ្នាំ..............

រៀបចំដោយ : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

បានពិនិត្យ និងឯកភាព
ថ្ងៃទី......... ខែ......... ឆ្នាំ..............
មេឃុំ ចៅសង្កាត់

### គ.៣). ផ្សព្វផ្សាយព័ត៌មាន

ការផ្សព្វផ្សាយព័ត៌មានអំពី ការផ្តល់សម្ភារៈបង្គន់អនាម័យត្រូវធ្វើឡើងឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ពិសេសគ្រួសារក្រីក្រខ្លាំងជាងគេ គ្រួសារដែលស្ត្រីជាមេគ្រួសារ និងលទ្ធភាពនៃការផ្តល់សម្ភារៈបង្គន់អនាម័យ។ ការផ្សព្វផ្សាយអាចធ្វើឡើងតាមរយៈ :

- អ្នកដឹកនាំភូមិ ឬភ្នាក់ងារសេវាសុខភាពសហគមន៍ចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមផ្ទះ
- អ្នកដឹកនាំភូមិ ឬអ្នកសម្របសម្រួលអនាម័យសហគមន៍រៀបចំជាកិច្ចប្រជុំជាមួយប្រជាពលរដ្ឋតាមភូមិ
- មេឃុំ ចៅសង្កាត់ត្រូវបិទផ្សាយព័ត៌មានទៅលើក្តារព័ត៌មានឃុំ សង្កាត់ និងទីសាធារណៈតាមភូមិ។

### គ.៤). ការស្នើសុំការគាំទ្រ

ការផ្តល់សម្ភារៈបង្គន់អនាម័យអាចផ្តល់ឱ្យបាន លុះត្រាតែ :

- មានការស្នើសុំដោយផ្ទាល់ពីសាមីខ្លួន ហើយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅមេឃុំ ចៅសង្កាត់ផ្ទាល់ ឬតាមរយៈអ្នកដឹកនាំភូមិ (ទម្រង់ទី៧)
- អ្នកស្នើសុំអាចស្នើសុំ តែផ្នែកណាមួយនៃសម្ភារៈបង្គន់អនាម័យ ដូចជា ចានបង្គន់ ឬលូមួយចំនួន
- អ្នកស្នើសុំត្រូវផ្គត់ផ្គង់បន្ថែមដោយខ្លួនឯងនូវសម្ភារៈចាំបាច់មួយចំនួន និងការសាងសង់ ដើម្បីធានាថាសម្ភារៈដែលបានផ្តល់ឱ្យអាចសាងសង់ និងផ្តល់ការប្រើប្រាស់បាន។

### គ.៥). ការសម្រេចផ្តល់សម្ភារៈបង្គន់អនាម័យ

- ក្រោយពីទទួលបានសំណើសុំពីប្រជាពលរដ្ឋ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវចុះពិនិត្យនិងវាយតម្លៃអំពីស្ថានភាពគ្រួសារដែលបានស្នើសុំ ដើម្បីជួយ គ.ក.ន.ក ក្នុងការសម្រេចចិត្តឱ្យបានត្រឹមត្រូវ
- បន្ទាប់មក គ.ក.ន.ក ត្រូវរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យ និងសម្រេចផ្តល់សម្ភារៈបង្គន់អនាម័យដល់គ្រួសារក្រីក្រជាងគេ (ទម្រង់ទី១១)។ អ្នកដឹកនាំភូមិ និងអ្នកសម្របសម្រួលអនាម័យសហគមន៍ ក៏ត្រូវបានអញ្ជើញចូលរួមប្រជុំ ដើម្បីផ្តល់យោបល់ផងដែរ
- អ្នកដឹកនាំភូមិ ឬអ្នកសម្របសម្រួលអនាម័យសហគមន៍ត្រូវផ្តល់ព័ត៌មានអំពីលទ្ធផលនៃការសម្រេចរបស់ គ.ក.ន.ក។ ករណីគ្រួសារដែលពុំបានផ្តល់ការគាំទ្រត្រូវផ្តល់ព័ត៌មាន និងបញ្ជាក់ពីមូលហេតុឱ្យបានច្បាស់លាស់
- ឃុំ សង្កាត់ត្រូវផ្តល់ជាសម្ភារៈបង្គន់អនាម័យ។ ការផ្តល់សម្ភារៈបង្គន់អនាម័យ ត្រូវមានកិច្ចសន្យា (ទម្រង់ទី១២) ដើម្បីធានាថា សម្ភារៈទាំងនោះ ត្រូវបានប្រើប្រាស់ស្របតាមគោលបំណងកំណត់។ ករណីពុំបានអនុវត្តន៍តាមកិច្ចសន្យា ឃុំ សង្កាត់អាចដកយកសម្ភារៈទាំងនោះមកវិញ ដើម្បីផ្តល់ឱ្យប្រជាពលរដ្ឋផ្សេងទៀត។

ឧទាហរណ៍

ទម្រង់ទី១១

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ...........................................
ក្រុង ស្រុក ខណ្ឌ : ....................................
ឃុំ សង្កាត់ : ................................................

**បញ្ជីឈ្មោះគ្រួសារដែលត្រូវផ្តល់សម្ភារៈបង្គន់អនាម័យ ឆ្នាំ២០១០**

| ល.រ | ឈ្មោះ | សម្រេចផ្តល់សម្ភារៈ | | អ្នកទទួលផល (នាក់) | មកពីភូមិ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ចានបង្គន់ | លូបង្គន់ | | | |
| ១ | មាស មករា | ១ | ២ | ៥ | ភូមិសំរោងក្រោម | |
| ២ | សុខ វណ្ណា | | ២ | ៦ | ភូមិសំរោងក្រោម | |
| ៣ | ប្រាក់ សុវណ្ណ | ១ | | ៥ | ភូមិសំរោងក្រោម | |
| ៤ | សុក សម្បត្តិ | ១ | | ៧ | ភូមិសំរោងក្រោម | |
| ៥ | ជា បូរិទ្ធិ | ១ | | ៨ | ភូមិសំរោងលើ | |
| សរុប | | ៣ | ៤ | ៣១ | | |

ថ្ងៃទី......... ខែ......... ឆ្នាំ..............

**រៀបចំដោយ : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ**

**បានពិនិត្យ និងឯកភាព**
ថ្ងៃទី......... ខែ......... ឆ្នាំ..............
**មេឃុំ សង្កាត់**

ឧទាហរណ៍

ទម្រង់ទី១២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យាផ្តល់សម្ភារៈបង្គន់អនាម័យ

ខ្ញុំបាទ នាងខ្ញុំឈ្មោះ... *ជា រិទ្ធ*.. ភេទ.. *ស្រី*... សញ្ជាតិ.. *ខ្មែរ*.... ឆ្នាំកំណើត ...*១៩៧០*... អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ..*១០០ ២០០ ៣០០*.. មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ..*១២៣*.. ផ្លូវលេខ..*៤៥៦*.. ឃុំ សង្កាត់ ..*បារាយណ៍*.. ក្រុង ស្រុក ខណ្ឌ.................................. រាជធានី ខេត្ត.................................. ។

បានទទួលសម្ភារៈបានបង្គន់អនាម័យចំនួន ..*០១*..គ្រឿង លូបង្គន់ចំនួន ..*០១*.. លូ និងសម្ភារៈ................. ពីសាលាឃុំ..*មានជ័យ*...សម្រាប់ការសាងសង់បង្គន់អនាម័យតាមគ្រួសារ។ ចំពោះសម្ភារៈនានា និងការសាងសង់ ខ្ញុំបាទ នាងខ្ញុំ សូមធានារ៉ាប់រងទាំងស្រុង ដើម្បីឱ្យដំណើរការសាងសង់ និងការដាក់ឱ្យប្រើប្រាស់ឱ្យបានមុនថ្ងៃទី..*៣០*.. ខែ..*តុលា*..ឆ្នាំ..*២០១០*. ដើម្បីបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ករណីពុំបានធ្វើតាមការកំណត់នោះទេ ខ្ញុំបាទ នាងខ្ញុំនឹងយកមកប្រគល់ជូនឃុំ សង្កាត់វិញដោយគ្មានល័ក្ខខ័ណ្ឌ។

ដើម្បីជាសក្ខីភាពទៅលើកិច្ចសន្យានេះ ខ្ញុំបាទ នាងខ្ញុំបានសូមចុះហត្ថលេខាដូចខាងក្រោម :

ថ្ងៃទី.. *០៥*... ខែ..*តុលា*.. ឆ្នាំ..*២០១០*..

អ្នកស្នើសុំ

បានពិនិត្យ និងឯកភាព

ថ្ងៃទី......... ខែ......... ឆ្នាំ.............

មេឃុំ សង្កាត់

គ.៦). ការបណ្តុះបណ្តាលបច្ចេកទេសសាងសង់បង្គន់អនាម័យ

- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ជួយ គ.ក.ឌ.ក ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសសាងសង់បង្គន់អនាម័យ (ទម្រង់ទី១៣)
- គ.ក.ឌ.ក រៀបចំកិច្ចប្រជុំពិភាក្សា ដើម្បីស្វែងរកអ្នកបណ្តុះបណ្តាលបច្ចេកទេសសាងសង់បង្គន់អនាម័យ ឃុំ សង្កាត់អាចប្រើប្រាស់ធនធានមនុស្សរបស់ឃុំ សង្កាត់ ដូចជា អ្នកសម្របសម្រួលអនាម័យសហគមន៍ (បើអាច) ឬដៃគូអភិវឌ្ឍន៍នានាក្នុងឃុំ សង្កាត់

- ពិនិត្យមើលគម្រោងនានាដែលបានព្រមព្រៀងក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ដែលបានការសន្យាផ្តល់បច្ចេកទេសដោយមន្ទីរអភិវឌ្ឍន៍ជនបទ ឬដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកធនធានមនុស្សសម្រាប់បណ្តុះបណ្តាលបច្ចេកទេសសាងសង់បង្គន់អនាម័យដល់ប្រជាពលរដ្ឋ
- គ.ក.ន.ក អាចលើកបញ្ហានេះនៅក្នុងកិច្ចប្រជុំប្រចាំត្រីមាសរបស់ គ.ក.ន.ក ដើម្បីស្វែងរកការគាំទ្រពីការិយាល័យអភិវឌ្ឍន៍ជនបទ ឬមន្ទីរអភិវឌ្ឍន៍ជនបទ ឬដៃគូអភិវឌ្ឍន៍នានា។ ការបណ្តុះបណ្តាលអាចធ្វើឡើងតាមរយៈ :
  - ផ្តល់ការបណ្តុះបណ្តាលដោយផ្ទាល់ពីស្ថាប័នទាំងនោះទៅឱ្យប្រជាពលរដ្ឋនៅតាមភូមិ ឬឃុំ សង្កាត់ តាមកាលវិភាគដែលបានព្រមព្រៀងជាមួយឃុំ សង្កាត់
  - ផ្តល់វគ្គគ្រូឧទ្ទេស និងផ្តល់ជំនួយបច្ចេកទេសដល់ធនធានមនុស្សរបស់ឃុំ សង្កាត់ ដើម្បីធ្វើការបណ្តុះបណ្តាលបន្តដល់ប្រជាពលរដ្ឋ។
- ទីចាត់ការផែនការ និងវិនិយោគអាចជួយឃុំ សង្កាត់ក្នុងការទំនាក់ទំនង និងសម្របសម្រួលជាមួយមន្ទីរអភិវឌ្ឍន៍ជនបទ ដើម្បីបណ្តុះបណ្តាលបច្ចេកទេសសាងសង់បង្គន់អនាម័យដល់ប្រជាពលរដ្ឋ។

**ឧទាហរណ៍**

**ទម្រង់ទី១៣**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..............................
ក្រុង ស្រុក ខណ្ឌ : ..............................
ឃុំ សង្កាត់ : ..............................

**កម្មវិធីបណ្តុះបណ្តាលស្តីពី បច្ចេកទេសសាងសង់បង្គន់អនាម័យដល់ប្រជាពលរដ្ឋ**

| លរ | ឃុំ សង្កាត់ | ចំនួនវគ្គ | អ្នកចូលរួម | | កាលបរិច្ឆេទ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | សរុប | ស្ត្រី | | |
| ១ | ភូមិសំរោងក្រោម | ១ | ៥០ | ២៥ | កញ្ញា | |
| ២ | ភូមិសំរោងលើ | ១ | ៦០ | ១០ | កញ្ញា | |
| ៣ | ភូមិថ្នល់បត់ជើង | ១ | ៧៥ | ២៥ | កញ្ញា | |
| ៤ | ភូមិថ្នល់បត់ត្បូង | ២ | ៨០ | ៥០ | តុលា | |
| | សរុប | ៥ | ២៦៥ | ១១០ | | |

ថ្ងៃទី......... ខែ......... ឆ្នាំ.............
រៀបចំដោយ : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

បានពិនិត្យ និងឯកភាព
ថ្ងៃទី......... ខែ......... ឆ្នាំ.............
មេឃុំ សង្កាត់

គ.៣). ដំណើរការអនុវត្តការសាងសង់បង្គន់អនាម័យ

- បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលបច្ចេកទេសសាងសង់បង្គន់អនាម័យ ឬសម្ភារៈបង្គន់អនាម័យ ប្រជាពលរដ្ឋត្រូវចាប់ផ្តើមសាងសង់បង្គន់អនាម័យ ដើម្បីបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល
- អ្នកដឹកនាំភូមិ ឬអ្នកសម្របសម្រួលអនាម័យសហគមន៍អាចផ្តល់ការណែនាំបច្ចេកទេសបន្ថែមអំពីរបៀបសាងសង់បង្គន់អនាម័យតាមគ្រួសារ ដើម្បីធានាថាការសាងសង់ស្របតាមការណែនាំ
- មន្ទីរអភិវឌ្ឍន៍ជនបទអាចផ្តល់ការណែនាំ ឬផ្តល់យោបល់បន្ថែមដល់ប្រជាពលរដ្ឋ អ្នកដឹកនាំភូមិ ឬអ្នកសម្របសម្រួលអនាម័យសហគមន៍ បើសិនជាមានការស្នើសុំ។

ឃ). ការត្រួតពិនិត្យ និងការជំរុញការអនុវត្ត

- អ្នកដឹកនាំភូមិ និងអ្នកសម្របសម្រួលអនាម័យសហគមន៍ត្រូវចុះតាមដានត្រួតពិនិត្យដំណើរការសាងសង់បង្គន់អនាម័យតាមគ្រួសារ ដើម្បីធានាថា គ្រួសារដែលបានព្រមព្រៀងបានសាងសង់តាមផែនការគ្រោងទុក (ទម្រង់ទី១៤)
- អ្នកដឹកនាំភូមិ ឬអ្នកសម្របសម្រួលអនាម័យសហគមន៍ត្រូវរាយការណ៍ដល់ គ.ក.ន.ក អំពីការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ និងបញ្ហានានា ដើម្បីដោះស្រាយឱ្យបានទាន់ពេលវេលា
- អ្នកដឹកនាំភូមិ ឬអ្នកសម្របសម្រួលអនាម័យសហគមន៍ណែនាំ និងជំរុញប្រជាពលរដ្ឋប្រើប្រាស់បង្គន់អនាម័យ និងប្រជាពលរដ្ឋផ្សេងៗទៀតពុំទាន់បានសាងសង់ឱ្យធ្វើការសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ ដើម្បីឈានទៅបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល
- មេឃុំ ចៅសង្កាត់ត្រូវតាមដានត្រួតពិនិត្យដំណើរការនៃការអនុវត្ត ដើម្បីធានាថា ការគាំទ្រសម្ភារៈបង្គន់អនាម័យបានធ្វើឡើងប្រកបដោយតម្លាភាព ការចំណាយស្របទៅតាមនីតិវិធី និងការរៀបចំកិច្ចបញ្ជីកាតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។

ឧទាហរណ៍

ទម្រង់ទី១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ...............................................
ក្រុង ស្រុក ខណ្ឌ : .......................................
ឃុំ សង្កាត់ : ...................................................

តារាងតាមដានភាពរីកចម្រើននៃការសាងសង់បង្គន់អនាម័យ គិតមកដល់ខែកញ្ញា ឆ្នាំ២០១០

| លរ | ភូមិ | ចំនួនគ្រួសារ | ចំនួនបង្គន់អនាម័យបានសាងសង់តាមខែនីមួយៗ | | | | | | | | | | | សម្រេចលទ្ធផល | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | សរុប | ភាគរយ |
| ១ | ភូមិសំរោងក្រោម | ២៥ | | | | | | ៥ | ១០ | ៥ | | | | ២០ | ៨០% |
| ២ | ភូមិសំរោងលើ | ៣០ | | | | | | ១០ | ៥ | ៦ | | | | ២១ | ៧០% |
| ៣ | ភូមិថ្នល់បត់ជើង | ៣៥ | | | | | | ៧ | ១០ | ៧ | | | | ២៤ | ៦៩% |
| ៤ | ភូមិថ្នល់បត់ត្បូង | ៤០ | | | | | | ១០ | ១២ | ៨ | | | | ៣០ | ៧៥% |
| សរុប | | ១៣០ | | | | | | ៣២ | ៣៧ | ២៦ | | | | ៩៥ | ៧៣% |

ថ្ងៃទី......... ខែ......... ឆ្នាំ..............

បានពិនិត្យ និងឯកភាព　　　　　　រៀបចំដោយ : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

ថ្ងៃទី......... ខែ......... ឆ្នាំ..............

មេឃុំ ចៅសង្កាត់

## ២.២.៤. ការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍

មត្តេយ្យសិក្សាសហគមន៍ គឺជាថ្នាក់ ឬមណ្ឌលមត្តេយ្យដែលបានរៀបចំ និងគ្រប់គ្រងដោយសហគមន៍ ឬឃុំ សង្កាត់សម្រាប់ផ្តល់ការសិក្សាដល់កុមារតូចអាយុពី៣-៥ឆ្នាំ នៅក្នុងសហគមន៍ ឬឃុំ សង្កាត់របស់ខ្លួន។

ក). គោលបំណង

ការរៀបចំ និងដំណើការមត្តេយ្យសិក្សាសហគមន៍ មានគោលបំណងបង្កើនការចូលរៀនរបស់កុមារអាយុ ៣-៥ឆ្នាំ ដើម្បីពង្រីកការផ្តល់សេវាគាំពារ និងការអភិវឌ្ឍកុមារតូចនៅឃុំ សង្កាត់ តាមរយៈការហាត់រៀនរបស់កុមារតូចនៅមណ្ឌល/ថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងជួយឱ្យកុមារបានត្រៀមខ្លួនចូលរៀនថ្នាក់បឋមសិក្សា។

ខ). លក្ខខណ្ឌទូទៅ

ខ.១). លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសទីតាំង

- ទីតាំងថ្នាក់មត្តេយ្យសិក្សាសហគមន៍ : ទីតាំងមត្តេយ្យត្រូវស្ថិតនៅជិតលំនៅដ្ឋាន កុមារអាយុ៣-៥ឆ្នាំភាគច្រើនក្នុងសហគមន៍ និងមានលក្ខណៈងាយស្រួលដល់ការធ្វើដំណើរទៅមក សហគមន៍ដែលមាន

កុមារពុំបានទទួលការសិក្សា ឬមានឱកាសក្នុងការទទួលបានការសិក្សាតិចតួចបំផុត ភូមិដាច់ស្រយាល ពុំមានមត្តេយ្យ និងជាតំបន់ជនជាតិដើមភាគតិច

- ថ្នាក់មត្តេយ្យសិក្សាសហគមន៍ : ក្នុងស្ថានភាពបច្ចុប្បន្ន មត្តេយ្យសិក្សាសហគមន៍អាចដំណើរការនៅទីតាំងសមស្របមួយចំនួន ដូចជា ផ្ទះប្រជាពលរដ្ឋ សាលាឆទាន វត្តអារាម ស្នាក់ការភូមិ មណ្ឌលអប់រំសហគមន៍ សាលាបឋមសិក្សា។ល។
- ការថែទាំ និងការជួសជុល : ករណីដែលទីតាំង និងអគារសម្រាប់មត្តេយ្យសិក្សាសហគមន៍មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលទាមទារឱ្យមានការជួសជុលកែលម្អក្នុងកម្រិតតិចតួច ឬសាងសង់បង្គន់អនាម័យ ឃុំ សង្កាត់អាចពិចារណាប្រើប្រាស់មូលនិធិឃុំ សង្កាត់ ឬទុនចូលរួមរបស់ប្រជាពលរដ្ឋក្នុងការជួសជុលកែលម្អបានផងដែរ។

មត្តេយ្យសិក្សាសហគមន៍ត្រូវស្ថិតនៅទីតាំងអចិន្ត្រៃយ៍មួយជាក់លាក់ ហេតុនេះ ឃុំ សង្កាត់គួរពិភាក្សាជាមួយម្ចាស់ផ្ទះ ដើម្បីឯកភាពផ្តល់ទីតាំងសម្រាប់ដំណើរការមត្តេយ្យសិក្សាសហគមន៍ក្នុងរយៈពេលមួយវែងសមស្រប យ៉ាងហោចណាស់ក៏មួយឆ្នាំសិក្សា។

នាពេលអនាគត នៅពេលដែលឃុំ សង្កាត់មានលទ្ធភាពគ្រប់គ្រាន់ ឃុំ សង្កាត់អាចសាងសង់មត្តេយ្យសិក្សាសហគមន៍របស់ខ្លួន ថវិកាគាំទ្រកិច្ចការទាំងនេះ គួរមានការចូលរួមធនធានពីប្រជាពលរដ្ឋនៅមូលដ្ឋាន ឬការគាំទ្រពីសប្បុរសជន ឬការគាំទ្រដោយដៃគូអភិវឌ្ឍន៍នានា។

### ១.២). បទដ្ឋានអប្បបរមានៃមត្តេយ្យសិក្សាសហគមន៍

- ទំហំថ្នាក់ : ទំហំសមស្រប ៥ម៉ែត្រ គុណនឹង៦ម៉ែត្រ ឬធំជាងនេះ ដែលអាចឱ្យកុមាររៀនសូត្រពី ២០នាក់ ទៅ ២៥នាក់
- សុវត្ថិភាព : ថ្នាក់/មណ្ឌលមត្តេយ្យសិក្សាសហគមន៍ត្រូវមានទំហំទីធ្លា សមស្របសម្រាប់លេងកំសាន្ត មានម្លប់ បរិស្ថានល្អ មានបង្គន់អនាម័យ អគារមានសភាពរឹងមាំ ដំបូលអគារអាចការពារកម្តៅ និងភ្លៀង មានអនាម័យ មិនមានសត្វ គ្មានក្លិនស្អុយ មិនស្ថិតនៅក្បែរត្រពាំងទឹកពេក និងមិនស្ថិតនៅកៀកផ្លូវពេក។

### ១.៣). កម្រិតអាយុកុមារចូលរៀន

មត្តេយ្យសិក្សាសហគមន៍អាចផ្តល់ការសិក្សាសម្រាប់កុមារដែលមានអាយុ៣-៥ឆ្នាំ។ ករណីតំបន់ដែលមានកុមារច្រើនលើសពី២៥នាក់ កុមារទាំងនោះក៏អាចអនុញ្ញាតិឱ្យចូលរៀនបានផងដែរ តែត្រូវមានជម្រើសដូចខាងក្រោម :

- ផ្តល់អាទិភាពដល់កុមារអាយុ៥ឆ្នាំ ចូលរៀន ដើម្បីឱ្យពួកគេអាចត្រៀមខ្លួនចូលរៀននៅបឋមសិក្សា និងត្រូវផ្តល់អាទិភាពដល់កុមារអាយុ៤ឆ្នាំ និង៣ឆ្នាំជាបន្តបន្ទាប់ ពិសេសកុមារគ្រួសារក្រីក្រ
- ចែកពេលបង្រៀន ដើម្បីឱ្យកុមារទាំងអស់បានចូលរៀន ដូចជា បង្រៀនមួយម៉ោងកន្លះ សម្រាប់កុមារដែលមានអាយុ៤-៥ឆ្នាំ និងមួយម៉ោងទៀតសម្រាប់កុមារអាយុ៣ឆ្នាំ
- រៀបចំថ្នាក់រយៈពេលបីថ្ងៃ ក្នុងមួយសប្តាហ៍សម្រាប់កុមារ៤-៥ឆ្នាំ និងរយៈពេលពីរថ្ងៃក្នុងមួយសប្តាហ៍សម្រាប់កុមារ៣ឆ្នាំ។

ខ.៤). លក្ខណៈសម្បត្តិគ្រូមត្តេយ្យសិក្សាសហគមន៍

បេក្ខជនជាគ្រូមត្តេយ្យសិក្សាសហគមន៍ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម :

- មានកម្រិតវប្បធម៌យ៉ាងហោចណាស់រៀនចប់បឋមសិក្សា ឬសមមូល
- ជាអ្នកចង់ទទួលនូវការបណ្តុះបណ្តាលលើជំនាញបង្រៀន មត្តេយ្យសិក្សាសហគមន៍
- មានចំណង់ចំណូលចិត្តក្នុងការបង្រៀន និងការជួយកុមារ
- ជាអ្នកដែលរស់នៅក្នុងឃុំ សង្កាត់
- ជាមនុស្សអំណត់អត់ធ្មត់
- មានអាយុ ១៨ឆ្នាំឡើងទៅ។

ខ.៥). ប្រតិទិនសិក្សាប្រចាំឆ្នាំ និងពេលវេលា

- ប្រតិទិនសិក្សាប្រចាំឆ្នាំ ចាប់ផ្តើមពីខែតុលា ដល់ខែកក្កដាមានរយៈពេល៩ខែក្នុងមួយឆ្នាំ។
- ការឈប់សម្រាកជាផ្លូវការអនុវត្តតាមប្រតិទិនឈប់សម្រាកជាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា
- ប្រតិទិនសិក្សាត្រូវសរសេរឱ្យបានច្បាស់ពីខែដែលត្រូវបង្រៀន និងសម្រាក ហើយបិទផ្សាយជាសាធារណៈ
- គ្រូមត្តេយ្យសិក្សាសហគមន៍តម្រូវឱ្យមានកិច្ចសន្យា និងបង្រៀនតាមប្រតិទិនបង្រៀនកុមារយ៉ាងហោចណាស់ ២ម៉ោងក្នុងមួយថ្ងៃ និង៥ថ្ងៃក្នុង មួយសប្តាហ៍ ចាប់ផ្តើមពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ។
- ករណីខ្លះ គ្រូមត្តេយ្យតម្រូវឱ្យធ្វើការលើសពីពេលម៉ោងកំណត់ផងដែរ ដូចជា ការចូលរួមក្នុងសកម្មភាពអប់រំមាតាបិតាសិស្ស ផ្សព្វផ្សាយ កៀរគរ ស្វែងរកការគាំទ្រ និងការប្រជុំ។ល។

គ). ដំណើរការនៃការរៀបចំមត្តេយ្យសិក្សាសហគមន៍

គ.១). ការកំណត់ និងជ្រើសរើសទីតាំង

- **ស្រង់ស្ថិតិចំនួនកុមារដែលមានអាយុពី៣.៥ឆ្នាំ** : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និង អ្នកដឹកនាំភូមិត្រូវស្រង់ស្ថិតិចំនួនកុមារដែលមានអាយុពី៣-៥ឆ្នាំ ពីទិន្នន័យភូមិ និងស្ថានភាពឃុំ សង្កាត់ និងទិន្នន័យដទៃទៀត ដើម្បីកំណត់ពីចំនួនកុមារអាយុ៣-៥ឆ្នាំ តាមភូមិនីមួយៗ (ទម្រង់ទី១៥)
- **កំណត់ទីតាំងសម្រាប់មត្តេយ្យសិក្សាសហគមន៍** : បន្ទាប់មក គ.ក.ន.ក រៀបចំប្រជុំជាមួយអ្នកដឹកនាំភូមិ ពិនិត្យចំនួនកុមារតាមភូមិនីមួយៗ និងលក្ខណៈវិនិច្ឆ័យផ្សេងៗទៀត (សុវត្ថិភាព ទំហំ និងភាពងាយស្រួលធ្វើដំណើរទៅមក) ដើម្បីកំណត់ភូមិសម្រាប់ជាទីតាំងថ្នាក់មត្តេយ្យសិក្សាសហគមន៍
- **ការចុះពិនិត្យ និងវាយតម្លៃទីតាំង** : បន្ទាប់ពីបានកំណត់ភូមិ និងទីតាំងសម្រាប់រៀបចំមត្តេយ្យសិក្សាសហគមន៍ គ.ក.ន.ក និងអ្នកដឹកនាំភូមិត្រូវចុះពិនិត្យ និងវាយតម្លៃទីតាំង និងអគារដល់ទីកន្លែងដោយ :
  - ពិនិត្យទីតាំង និងស្ថានភាពអគារ ថាតើមានលក្ខណៈសមស្របសម្រាប់រៀបចំថ្នាក់មត្តេយ្យសិក្សាសហគមន៍ដែរឬទេ?

- ពិភាក្សាជាមួយម្ចាស់ទីតាំង ឬម្ចាស់ផ្ទះ ដើម្បីព្រមព្រៀងក្នុងការផ្តល់ទីតាំង ឬការជួសជុលកែលម្អទីតាំង ឬអគារ (ករណីចាំបាច់) សម្រាប់ដំណើរការមត្តេយ្យសិក្សាសហគមន៍។ ការផ្តល់ទីតាំង និងអគារគួរផ្តល់ឱ្យក្នុងរយៈពេលវែងសមស្រប យ៉ាងហោចណាស់មានរយៈពេលមួយឆ្នាំសិក្សា
- ពិគ្រោះយោបល់ជាមួយមាតាបិតាកុមារ : គ.ក.ន.ក និង អ្នកដឹកនាំភូមិត្រូវប្រជុំពិគ្រោះយោបល់ជាមួយមាតាបិតាកុមារ អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សាកុមារ អំពីមត្តេយ្យសិក្សាសហគមន៍ និងការព្រមព្រៀងបញ្ជូនកូនទៅរៀនមត្តេយ្យសិក្សាសហគមន៍ និងលទ្ធភាពនៃការចូលរួមរបស់មាតាបិតា និងអាណាព្យាបាល។

**ឧទាហរណ៍**

**ទម្រង់ទី១៥**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..........................................
ក្រុង ស្រុក ខណ្ឌ : ..................................
ឃុំ សង្កាត់ : ...............................................

**កុមារអាយុ៣-៥ឆ្នាំ តាមភូមិនីមួយៗ**

| លរ | ឈ្មោះភូមិ | កុមារ៣-៥ ឆ្នាំសរុប | ចំនួនកុមារមិនបានចូលរៀនមត្តេយ្យសិក្សា | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ៣ឆ្នាំ | ៤ឆ្នាំ | ៥ឆ្នាំ | សរុប | កុមារី | |
| ១ | ភូមិដូងខាងជើង | ១៥ | ៦ | ៥ | ៤ | ១៥ | ៧ | |
| ២ | ភូមិដូងខាងត្បូង | ១២ | ២ | ៤ | ៦ | ១២ | ៧ | |
| ៣ | ភូមិត្នោតកើត | ១២ | ៣ | ៤ | ៥ | ១២ | ៦ | |
| ៤ | ភូមិត្នោតលិច | ៨ | ២ | ៣ | ៣ | ៨ | ៤ | |
| ៥ | ភូមិស្វា | ៧ | ២ | ៣ | ២ | ៧ | ៥ | |
| | សរុប | ៥៤ | ១៥ | ១៩ | ២០ | ៥៤ | ២៩ | |

ថ្ងៃទី......... ខែ......... ឆ្នាំ..............
រៀបចំដោយ : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

បានពិនិត្យ និងឯកភាព
ថ្ងៃទី......... ខែ......... ឆ្នាំ..............
មេឃុំ សង្កាត់

គ.២). ចលនាមាតាបិតាបញ្ជូនកូនទៅរៀន

- ផ្សព្វផ្សាយដល់មាតាបិតាឱ្យបញ្ជូនកូនទៅរៀន : អ្នកដឹកនាំភូមិត្រូវផ្សព្វផ្សាយដល់គ្រួសារដែលមានកូនអាយុ៣-៥ឆ្នាំ ដើម្បីបញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យសិក្សាសហគមន៍ ដោយពន្យល់ពីសារសំខាន់នៃការបញ្ជូនកូនទៅរៀនមត្តេយ្យសិក្សាសហគមន៍ ទីកន្លែងមត្តេយ្យសិក្សាសហគមន៍ និងប្រតិទិនសិក្សា។ ការផ្សព្វផ្សាយអាចធ្វើឡើងតាមរយៈ :
  - អ្នកដឹកនាំភូមិចុះពន្យល់ប្រជាពលរដ្ឋដែលមានកូនអាយុ៣-៥ឆ្នាំ តាមផ្ទះ ឬ
  - អ្នកដឹកនាំភូមិរៀបចំកិច្ចប្រជុំតាមភូមិជាមួយប្រជាពលរដ្ឋ ពិសេស គ្រួសារដែលមានកូនអាយុ ៣-៥ឆ្នាំ និង
  - មេឃុំ ចៅសង្កាត់ត្រូវបិទផ្សាយព័ត៌មាននៅលើក្ដារព័ត៌មាន ឃុំ សង្កាត់ និងទីសាធារណៈ។

គ.៣). ការស្រង់ឈ្មោះ និងចុះឈ្មោះចូលរៀន

- អ្នកដឹកនាំភូមិត្រូវស្រង់ឈ្មោះសិស្ស និងចុះឈ្មោះសិស្សដែលត្រូវចូលរៀនមត្តេយ្យសិក្សាសហគមន៍ រួចបញ្ជូនទៅ គ.ក.ន.ក
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវបូកសរុបចំនួនកុមារដែលត្រូវចូលរៀន
- ករណីដែលកុមារចុះឈ្មោះចូលរៀនមានចំនួនច្រើន គ.ក.ន.ក ត្រូវពិចារណាអំពីលទ្ធភាពទទួលយកកុមារឱ្យចូលរៀន ជាអតិបរមាតាមដែលអាចធ្វើទៅបាន (ទម្រង់ទី១៦។

ឧទាហរណ៍

ទម្រង់ទី១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..........................................
ក្រុង ស្រុក ខណ្ឌ : ..........................................
ឃុំ សង្កាត់ : ..........................................

បញ្ជីឈ្មោះសិស្សចូលរៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍

| ល.រ | ឈ្មោះសិស្ស | អាយុ (ឆ្នាំ) | ភេទ | | មកពីភូមិ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ស្រី | ប្រុស | | |
| ១ | ជា វណ្ណា | ៤ | ✓ | | ភូមិដូងខាងជើង | |
| ២ | សុក សុខា | ៤ | ✓ | | ភូមិដូងខាងត្បូង | |
| | .......... | | | | | |
| | សរុប | | | | | |

ថ្ងៃទី......... ខែ......... ឆ្នាំ.............
រៀបចំដោយ : អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

បានពិនិត្យ និងឯកភាព
ថ្ងៃទី......... ខែ......... ឆ្នាំ.............
មេឃុំ សង្កាត់

គ.៤). ការបញ្ជូនកូនទៅរៀន

- អ្នកដឹកនាំភូមិត្រូវជូនដំណឹងអំពីការទទួលឱ្យចូលរៀន និងកាលវិភាគសិក្សាដល់មាតាបិតាសិស្ស ។ ករណី មិនអាចទទួលកុមារឱ្យចូលរៀនបានទាំងអស់ អ្នកដឹកនាំភូមិត្រូវជូនព័ត៌មាននេះដល់មាតាបិតាកុមារ ដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់
- ពេលបើកបវេសនកាលមត្តេយ្យសិក្សាសហគមន៍ អ្នកដឹកនាំភូមិត្រូវជម្រាបដល់មាតាបិតាសិស្សឱ្យបានច្បាស់អំពីទីតាំងសាលាមត្តេយ្យ ម៉ោងសិក្សា និងការបញ្ជូនកូនទៅរៀន
- មាតាបិតាសិស្ស ឬអាណាព្យាបាលសិស្សនាំកូន និងជំរុញកូនរបស់ខ្លួនទៅថ្នាក់មត្តេយ្យសិក្សាសហគមន៍ឱ្យបានទាន់ពេលវេលា ទៀងទាត់ និងជាប្រចាំ ។

គ.៥). ការជ្រើសរើស និងការធ្វើកិច្ចសន្យាជាមួយគ្រូមត្តេយ្យ

- ការរៀបចំព័ត៌មានជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍ : មេឃុំ ចៅសង្កាត់ រៀបចំសេចក្តីបរិយាយមុខងារ លក្ខណសម្បត្តិ កិច្ចសន្យា និងសមាសភាពគណៈកម្មការជ្រើសរើស ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងសម្រេច
- ការបង្កើតគណៈកម្មការជ្រើសរើស អាចមានសមាសភាពមួយចំនួនដូចខាងក្រោម :
  - មេឃុំ ចៅសង្កាត់
  - ជំទប់ទី២ ចៅសង្កាត់រងទី២
  - តំណាងសាលារៀន (សមាជិក គ.ក.ន.ក)
  - អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ និង
  - ស្មៀនឃុំ សង្កាត់ ។
- ការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ : បន្ទាប់ពីបានទទួលសំណើ ស្តីពី ការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំប្រជុំ ដើម្បីពិនិត្យ និងសម្រេចអំពីការបង្កើតគណៈកម្មការជ្រើសរើស និងការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍
- ការផ្សព្វផ្សាយដំណឹងស្តីពីការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍ : បន្ទាប់ពីក្រុមប្រឹក្សា ឃុំ សង្កាត់បានអនុម័តរួច មេឃុំ ចៅសង្កាត់ត្រូវរៀបចំ និងធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការជ្រើសរើសគ្រូមត្តេយ្យសិក្សាមត្តេយ្យឱ្យបានទូលំទូលាយ ។

  ការផ្សព្វផ្សាយអាចធ្វើឡើងតាមមធ្យោបាយ :
  - ការបិទផ្សាយនៅក្តារព័ត៌មានឃុំ សង្កាត់ និងទីសាធារណៈ
  - អ្នកដឹកនាំភូមិផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន ឬ
  - តាមមធ្យោបាយផ្សេងទៀតដែលឃុំ សង្កាត់អាចធ្វើបាន ។

- ការប្រគល់ពាក្យ និងទទួលពាក្យ : ស្មៀនឃុំ សង្កាត់ត្រូវ :
  - ចែកពាក្យសុំចូលបម្រើការងារ និងទម្រង់ប្រវត្តិរូបសង្ខេបដល់បេក្ខជនដោយឥតបង់ថ្លៃ
  - ទទួល និងពិនិត្យពាក្យសុំចូលបម្រើការងារ និងប្រវត្តិរូបសង្ខេបរបស់បេក្ខជន
  - រៀបចំបញ្ជីឈ្មោះបេក្ខជនដាក់ជូនគណៈកម្មការជ្រើសរើស ដើម្បីពិនិត្យ និងជ្រើសរើសទៅតាមនីតិវិធី
- ការជ្រើសរើសបេក្ខជន : នីតិវិធីជ្រើសរើសអាចធ្វើឡើងតាម :
  - ការជ្រើសរើសប្រវត្តិរូបសង្ខេប ឬ
  - ការប្រលងជ្រើសរើស

ការជ្រើសរើសគ្រូមត្តេយ្យ ឃុំ សង្កាត់អាចស្នើសុំឱ្យអ្នកពាក់ព័ន្ធ ដូចជា មន្ទីរអប់រំ យុវជន និងកីឡា ឬ ទីចាត់ការផែនការ និងវិនិយោគ ដើម្បីផ្តល់យោបល់ក្នុងការជ្រើសរើសគ្រូមត្តេយ្យ ហើយតំណាងសហគមន៍ ឬ មាតាបិតាសិស្ស អាចអញ្ជើញចូលរួមសង្កេតការណ៍អំពីដំណើរការជ្រើសរើសគ្រូមត្តេយ្យសិក្សាសហគមន៍ផងដែរ ។

- ការសម្រេចផ្តល់កិច្ចសន្យា
  - គណៈកម្មការជ្រើសរើសត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការជ្រើសរើស និងវាយតម្លៃបេក្ខជន ហើយដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យ និងសម្រេច
  - ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំប្រជុំ ដើម្បីពិនិត្យ និងអនុម័តសម្រេចយកបេក្ខជនសម្រាប់បម្រើការងារ
  - មេឃុំ ចៅសង្កាត់ត្រូវបិទផ្សាយឈ្មោះបេក្ខជនដែលត្រូវបានជ្រើសរើសនៅលើក្តារព័ត៌មានឃុំ សង្កាត់
  - មេឃុំ ចៅសង្កាត់ត្រូវរៀបចំកិច្ចសន្យាបម្រើការងារសម្រាប់គ្រូមត្តេយ្យសិក្សាសហគមន៍ ។ កិច្ចសន្យានេះត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ និងគ្រូមត្តេយ្យសិក្សាសហគមន៍(ទម្រង់ទី១៧) ។

គ.៦). បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍

- គ.ក.ន.ក ត្រូវបញ្ជូនឈ្មោះគ្រូមត្តេយ្យសិក្សាសហគមន៍ទៅទីចាត់ការផែនការ និងវិនិយោគ
- ផែនការ និងវិនិយោគត្រូវសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីរៀបចំបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍
- មន្ទីរអប់រំ យុវជន និងកីឡាត្រូវផ្តល់វគ្គបណ្តុះបណ្តាលពីជំនាញ បង្រៀនមត្តេយ្យសិក្សាសហគមន៍ដល់គ្រូមត្តេយ្យសិក្សាសហគមន៍
- មន្ទីរអប់រំ យុវជន និងកីឡាត្រូវផ្តល់ឯកសារ និងសម្ភារៈចាំបាច់មួយចំនួនសម្រាប់ការបង្រៀនមត្តេយ្យសិក្សាសហគមន៍ដល់ឃុំ សង្កាត់ ។

ឧទាហរណ៍

ទម្រង់ទី១៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..................................
ក្រុង ស្រុក ខណ្ឌ : ..............................
ឃុំ សង្កាត់ : .......................................
លេខ : .......................................

## កិច្ចសន្យាផ្តល់សេវាបង្រៀនមត្តេយ្យសិក្សាសហគមន៍

កិច្ចសន្យានេះធ្វើឡើងនៅថ្ងៃទី*០១* ខែ*មករា* ឆ្នាំ*២០១០* រវាង*ឃុំចម្រើនផល* នៃស្រុក.................. រាជធានី ខេត្ត................................ ហៅកាត់ថា "ឃុំ សង្កាត់" និង លោក *មាស វេសនា* ដែលមានអាសយដ្ឋាន *ផ្ទះលេខ២១១ ផ្លូវលេខ ៦១០ ឃុំចម្រើនផល* ស្រុក................ ខេត្ត .............. ហៅកាត់ថា "គ្រូមត្តេយ្យ"។

ភាគីទាំងពីរព្រមព្រៀងគ្នាដូចតទៅ :

### ១. លក្ខខណ្ឌការងារ

ក). គ្រូមត្តេយ្យនឹងបំពេញការងារជូនដល់ឃុំ សង្កាត់ ដូចខាងក្រោម :

- ផ្សព្វផ្សាយប្រតិទិនសិក្សាប្រចាំឆ្នាំរបស់មត្តេយ្យសិក្សាសហគមន៍ដល់មាតាបិតាសិស្ស
- សហការជាមួយ គ.ក.ន.ក ក្នុងការអប់រំ ផ្សព្វផ្សាយ និងចលនាមាតាបិតាបញ្ជូនកូនមករៀន
- រៀបចំចុះឈ្មោះកុមារសម្រាប់ការចូលរៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍
- រៀបចំកិច្ចតែងការបង្រៀនប្រចាំថ្ងៃ សម្រាប់ការបង្រៀន
- បង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ឱ្យបានទៀងទាត់ទៅតាមប្រតិទិន និងពេលវេលាដែលបានឯកភាព
- អនុវត្តវិធីសាស្ត្របង្រៀនទៅការណែនាំរបស់ក្រសួង ឬមន្ទីរអប់រំ យុវជន និងកីឡា
- រៀបចំទុកដាក់សម្ភារៈ និងឧបករណ៍បង្រៀនឱ្យបានត្រឹមត្រូវ និងគង់វង្ស
- ចូលរួមរៀបចំកម្មវិធីមត្តេយ្យសិក្សាសហគមន៍ ការបណ្តុះបណ្តាល និងសិក្ខាសាលា
- តាមដានត្រួតពិនិត្យ និងចុះវត្តមានរបស់សិស្សប្រចាំថ្ងៃ
- រៀបចំរបាយការណ៍ប្រចាំខែស្តីពីការបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍។

ខ). គ្រូមត្តេយ្យនឹងធ្វើការងារក្រោមការគ្រប់គ្រងផ្ទាល់របស់មេឃុំ ចៅសង្កាត់។

គ). គ្រូមត្តេយ្យនឹងបំរើការងារនៅ*ភូមិជាលា* ។

### ២. រយៈពេលនៃកិច្ចសន្យា

កិច្ចសន្យានេះធ្វើឡើងសម្រាប់រយៈពេល០៩ខែ ចាប់ផ្តើមទៅថ្ងៃទី*០១* ខែ*មករា* ឆ្នាំ*២០១០* ដល់ថ្ងៃទី*៣០* ខែ*កញ្ញា* ឆ្នាំ*២០១០*។

## ៣. ប្រាក់ឧបត្ថម្ភ

ឃុំ សង្កាត់នឹងបើកជូនគ្រូមត្តេយ្យនូវប្រាក់ឧបត្ថម្ភចំនួន*៦០.០០០ រៀល* ក្នុងមួយខែ*( ប្រាំមួយម៉ឺនរៀលគត់ )*។ ការទូទាត់ប្រាក់នឹងត្រូវធ្វើឡើងនៅដំណាច់ខែនីមួយៗ បន្ទាប់ពី គ្រូមត្តេយ្យដាក់ជូនរបាយការណ៍ប្រចាំខែស្តីពីការបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ និងរបាយការណ៍តាមដានវត្តមានសិស្សប្រចាំខែ។

## ៤. ថិរវេលាធ្វើការ

គ្រូមត្តេយ្យនឹងបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ចំនួន*២*ម៉ោងក្នុង១ថ្ងៃ ៥ថ្ងៃក្នុងមួយសប្តាហ៍ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ។ ពេលម៉ោងបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍ គឺចាប់ផ្តើមពីម៉ោង*០៨.០០*ដល់ម៉ោង*១០.០០*។

## ៥. ការឈប់សម្រាកផ្លូវការ និងការឈប់សំរាកពិសេស

គ្រូមត្តេយ្យមានសិទ្ធិទទួលបាននូវការឈប់សម្រាកផ្លូវការ (បុណ្យជាតិ) តាមប្រតិទិនឈប់សម្រាកជាផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា។

គ្រូមត្តេយ្យមានសិទ្ធិទទួលបាននូវការឈប់សម្រាកពិសេស ក្នុងឱកាសមានព្រឹត្តិការណ៍ដែលប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃបុគ្គលិកនោះ។

ចំពោះគ្រូមត្តេយ្យជាស្ត្រីមានសិទ្ធិឈប់សម្រាកលំហែមាតុភាពរយៈពេល០៣ខែ ដោយទទួលបាននូវប្រាក់ឧបត្ថម្ភប្រចាំខែ។

## ៦. ការបញ្ចប់កិច្ចសន្យា

ភាគីណាមួយក៏អាចបញ្ចប់កិច្ចសន្យានេះពេលណាក៏បាន ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតចំនួន៣០ថ្ងៃជាមុន។

ក្នុងករណីត្រូវបានបណ្តេញចេញពីការងារ ដោយសារការប្រព្រឹត្តខុសឆ្គងធ្ងន់ធ្ងរ កិច្ចសន្យាត្រូវបានបញ្ចប់ដោយចូលជាធរមានភ្លាម។

## ៧. ការដោះស្រាយជំរឿស

ជម្លោះណាមួយដែលកើតឡើងទាក់ទងនឹងកិច្ចសន្យានេះ ត្រូវដាក់ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីពិនិត្យនិងសម្រេច។

កិច្ចសន្យានេះត្រូវធ្វើឡើងចំនួន០២ច្បាប់ ហើយត្រូវរក្សាទុកនៅភាគីទាំងពីរ ។

ដើម្បីជាសក្ខីភាពទៅលើកិច្ចសន្យាបម្រើការនេះ ភាគីទាំងពីរបានចុះហត្ថលេខាដូចខាងក្រោម :

**មេឃុំ ចៅសង្កាត់** **គ្រូមត្តេយ្យសិក្សាសហគមន៍**

ឃ). ការបង្រៀន និងការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍

ឃ.១). បង្រៀននៅមត្តេយ្យសិក្សាសហគមន៍

- កាលវិភាគនៃការបង្រៀនត្រូវអនុវត្តតាមកិច្ចសន្យា
- កម្មវិធី ខ្លឹមសារ និងវិធីសាស្ត្រត្រូវអនុវត្តតាមគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា
- មុខវិជ្ជាសំខាន់ៗរួមមាន : បុរេគណិត បុរេសំណេរ សិក្សាសង្គម និងវិទ្យាសាស្ត្រអនុវត្តន៍។ល។

ឃ.២). ការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍

- ចូលរួមសកម្មភាពផ្សព្វផ្សាយដល់មាតាបិតាសិស្ស និងកិច្ចប្រជុំរបស់ គ.ក.ន.ក ក្រុមប្រឹក្សាឃុំ សង្កាត់តាមការស្នើសុំ
- គ្រប់គ្រង និងថែទាំឧបករណ៍ និងសម្ភារៈរបស់ថ្នាក់មត្តេយ្យសិក្សាសហគមន៍
- តាមដានត្រួតពិនិត្យវត្តមានសិស្ស (ទម្រង់ទី១៨) និងរៀបចំរបាយការណ៍ប្រចាំខែ (ទម្រង់ទី១៩) និងប្រជុំផ្ទះបញ្ចាំងពីដំណើរការមត្តេយ្យសិក្សាសហគមន៍ជាមួយមាតាបិតាសិស្ស
- រាយការណ៍ដល់ គ.ក.ន.ក និងមេឃុំ ចៅសង្កាត់ជាប្រចាំអំពីបញ្ហាដែលបានកើតឡើង ដើម្បីដោះស្រាយឱ្យបានទាន់ពេលវេលា។

ឧទាហរណ៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា

ទម្រង់ទី១៨

រាជធានី ខេត្ត :..........................
ក្រុង ស្រុក ខណ្ឌ :..........................
ឃុំ សង្កាត់ :..........................

## របាយការណ៍តាមដានវត្តមានសិស្ស

ប្រចាំខែកញ្ញា ឆ្នាំ២០១០

| ល.រ | ឈ្មោះសិស្ស | ភេទ | | វត្តមានរបស់សិស្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | សរុបតាមសិស្ស | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្រី | ប្រុស | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | វត្តមាន | អវត្តមាន |
| 1 | មាស មាន់ | ✓ | | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | × | × | | | ✓ | ✓ | × | ✓ | ✓ | | | ✓ | ✓ | ✓ | × | × | | | ✓ | ✓ | ✓ | × | 16 | 6 |
| 2 | កន វាសនា | | ✓ | ✓ | ✓ | × | | | ✓ | ✓ | × | × | × | | | × | ✓ | ✓ | × | × | | | × | ✓ | ✓ | ✓ | × | | | ✓ | ✓ | ✓ | × | 12 | 10 |
| 3 | កង ថា | ✓ | | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | × | | | ✓ | ✓ | ✓ | ✓ | ✓ | | | × | ✓ | ✓ | ✓ | ✓ | | | × | ✓ | ✓ | ✓ | 19 | 3 |
| 4 | ជា សំណោង | | | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | × | × | ✓ | ✓ | | | ✓ | × | ✓ | ✓ | ✓ | | | ✓ | × | ✓ | ✓ | 18 | 4 |
| 5 | វ៉ាន វ៉ន | | ✓ | ✓ | ✓ | ✓ | | | ✓ | × | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | × | ✓ | | | ✓ | ✓ | × | ✓ | ✓ | | | ✓ | ✓ | × | ✓ | 18 | 4 |
| 6 | ចាយ រ៉ា | | ✓ | ✓ | × | ✓ | | | ✓ | ✓ | × | ✓ | ✓ | | | ✓ | × | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | × | ✓ | | | ✓ | ✓ | ✓ | × | 17 | 5 |
| 7 | កាន់ ថា | ✓ | | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | × | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | × | | | ✓ | ✓ | ✓ | × | 19 | 3 |
| 8 | ផា មែន | ✓ | | ✓ | × | ✓ | | | ✓ | × | ✓ | × | ✓ | | | ✓ | × | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | × | ✓ | | | ✓ | ✓ | × | ✓ | 16 | 6 |
| 9 | សង មន | | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | × | ✓ | ✓ | | | ✓ | ✓ | × | ✓ | ✓ | | | ✓ | ✓ | × | ✓ | ✓ | | | ✓ | × | ✓ | ✓ | 18 | 4 |
| 10 | មិន ថា | ✓ | | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | × | ✓ | ✓ | ✓ | | | × | ✓ | ✓ | ✓ | 20 | 2 |
| 11 | លេង មា | ✓ | | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | × | ✓ | ✓ | ✓ | | | × | ✓ | ✓ | ✓ | 20 | 2 |
| 12 | ចន ផន | ✓ | | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | × | ✓ | ✓ | ✓ | | | × | ✓ | ✓ | ✓ | 20 | 2 |
| | សរុបវត្តមានតាមថ្ងៃ | | | 12 | 10 | 11 | | | 12 | 10 | 9 | 8 | 9 | | | 11 | 9 | 9 | 10 | 11 | | | 10 | 8 | 10 | 9 | 9 | | | 8 | 10 | 10 | 8 | | |
| | សរុបអវត្តមានតាមថ្ងៃ | | | 0 | 2 | 1 | | | 0 | 2 | 3 | 4 | 3 | | | 1 | 3 | 3 | 2 | 1 | | | 2 | 4 | 2 | 3 | 3 | | | 4 | 2 | 2 | 4 | | |

កំណត់សម្គាល់ : វត្តមាន ✓ អវត្តមាន X

ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០
គ្រូបង្គោលសិក្សាសហគមន៍

ឧទាហរណ៍

ទម្រង់ទី១៩

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត : ..............................

ក្រុង ស្រុក ខណ្ឌ : ..........................

ឃុំ សង្កាត់ : ....................................

## របាយការណ៍ស្តីពីការបង្រៀនថ្នាក់មត្តេយ្យសិក្សាសហគមន៍

ប្រចាំខែកញ្ញា ឆ្នាំ២០១០

| ថ្ងៃ ខែ ឆ្នាំ | ម៉ោងសិក្សា | | | ចំនួនសិស្ស | | មេរៀនដែលបានបង្រៀន |
|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | ចំនួនម៉ោង | វត្តមាន | អវត្តមាន | |
| 01/09/2010 | 08.00 | 10.00 | 2 | 12 | 0 | *បុរេគណិត* |
| 02/09/2010 | 08.00 | 10.00 | 2 | 10 | 2 | *បុរេសំណេរ* |
| 03/09/2010 | 08.00 | 10.00 | 2 | 11 | 1 | *សិក្សាសង្គម* |
| 06/09/2010 | 08.00 | 10.00 | 2 | 12 | 0 | *វិទ្យាសាស្ត្រអនុវត្ត* |
| 07/09/2010 | 08.00 | 10.00 | 2 | 10 | 2 | *សិក្សាសង្គម* |
| 08/09/2010 | 08.00 | 10.00 | 2 | 9 | 3 | |
| .................... | | | | | | |
| .................... | | | | | | |
| 28/09/2010 | 08.00 | 10.00 | 2 | 10 | 2 | *បុរេគណិត* |
| 29/09/2010 | 08.00 | 10.00 | 2 | 10 | 2 | *បុរេសំណេរ* |
| 30/09/2010 | 08.00 | 10.00 | 2 | 8 | 4 | *សិក្សាសង្គម* |

សង្ខេបលទ្ធផលប្រចាំខែ :

ចំនួនថ្ងៃបង្រៀនសរុប : *២២ថ្ងៃ*

ចំនួនម៉ោងបង្រៀនសរុប : *៤៤ ម៉ោង*

ចំនួនភាគរយសិស្សវត្តមាន :*៨២%*

ចំនួនភាគរយសិស្សអវត្តមាន : *១៨%*

ចំនួនមេរៀនដែលបានបង្រៀនសរុប :*៤ មេរៀន*

ថ្ងៃទី.......... ខែ.......... ឆ្នាំ.............

គ្រូមត្តេយ្យសិក្សាសហគមន៍

ថ្ងៃទី.......... ខែ.......... ឆ្នាំ.............

មេឃុំ ចៅសង្កាត់

## ២.២.៥. ការរៀបចំវេទិកាលើកកម្ពស់យេនឌ័រ និងកិច្ចការពារកុមារ

ការពង្រឹងបណ្ដាញការងារយេនឌ័រ និងកិច្ចការពារកុមារនៅមូលដ្ឋាន អាចធ្វើឡើងតាមរយៈការប្រជុំផ្លាស់ប្ដូរយោបល់ និងវេទិកាជាមួយនឹងស្ត្រីជាអ្នកដឹកនាំភូមិ និងសហគមន៍ជាដើម ដើម្បីពិភាក្សាលើប្រធានបទជាក់លាក់ណាមួយទាក់ទងការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅមូលដ្ឋាន។ វេទិកាសាធារណៈ ក៏ត្រូវបានប្រើប្រាស់ផងដែរ សម្រាប់លើកកម្ពស់សកម្មភាពសេវាសង្គមនានាផងដែរ ដូចជា ការអប់រំ ការថែទាំសុខភាព អនាម័យ និងសន្តិសុខសណ្ដាប់ធ្នាប់ ។ល។

ការរៀបចំវេទិកាសាធារណៈ គួររៀបចំនៅទីសាធារណៈ ដែលអាចផ្ដល់ឱកាសឱ្យប្រជាពលរដ្ឋគ្រប់រូបអាចចូលរួមបាន ដូចជា សាលាឃុំ សង្កាត់ ផ្ទះប្រជាពលរដ្ឋ វត្តអារាម ឬសាលារៀន ។ល។

### ក). វេទិកាសាធារណៈ

វេទិកាសាធារណៈ ជាកិច្ចប្រជុំមួយដែលផ្ដល់ឱកាសឱ្យប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដែលមានបទពិសោធន៍ ដើម្បីចែករំលែកព័ត៌មាន ទស្សនៈ ចំណេះដឹង និងបទពិសោធន៍លើបញ្ហា ឬប្រធានបទជាក់លាក់ណាមួយ ក្នុងការស្វែងរកដំណោះស្រាយ និងជំរើសនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់ប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា។

### ខ). គោលបំណងនៃការរៀបចំវេទិកាសាធារណៈ

វេទិកាសាធារណៈ មានគោលបំណងបង្កើនការយល់ដឹង និងដោះស្រាយបញ្ហាយេនឌ័រ ដើម្បីជួយកាត់បន្ថយការរើសអើង ផ្ដត់ផ្ដិតជាអវិជ្ជមានលើស្ត្រី និងកុមារ និងលើកកម្ពស់ការអនុវត្តសិទ្ធិស្មើភាពរវាងបុរស និង ស្ត្រីនៅក្នុងការធ្វើសេចក្ដីសម្រេច និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

### គ). សារប្រយោជន៍នៃវេទិកាសាធារណៈ

វេទិកាសាធារណៈមានសារប្រយោជន៍ ក្នុងការជួយ :

- កែលម្អគុណភាព និងប្រសិទ្ធភាពសេវា សាធារណៈរបស់ឃុំ សង្កាត់ ក៏ដូចជាសេវារបស់ស្ថាប័ននានាផងដែរ ដូចជា ការអប់រំ ការថែទាំសុខភាព និងសន្តិសុខ សណ្ដាប់ធ្នាប់ ។ល។
- បង្កើនតម្លាភាព និងគណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្ថាប័នពាក់ព័ន្ធនានា ដែលបានផ្ដល់សេវាសាធារណៈនៅមូលដ្ឋាន
- បង្កើតនូវវប្បធម៌ជជែកពិភាក្សាគ្នារវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រង ការអភិវឌ្ឍ និងការសម្រេចចិត្តនានា

## ឃ). ការរៀបចំ និងដំណើរការវេទិកាសាធារណៈ

### ឃ.១). ការកំណត់តម្រូវការ

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវពិភាក្សា ដើម្បីកំណត់អំពី :
  - គោលបំណង
  - ប្រធានបទ និងខ្លឹមសារ
  - ក្រុមគោលដៅចូលរួម
  - វិធីសាស្ត្រ
  - អ្នកសម្របសម្រួល និងវាគ្មិន
  - ទីកន្លែងរៀបចំវេទិកា
  - កម្មវិធី និងរបៀបវារៈ

### ឃ.២). ទំនាក់ទំនងស្វែងរកការគាំទ្រ

- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ជួយ គ.ក.ន.ក ក្នុងការរៀបចំកម្មវិធីវេទិកាសាធារណៈលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ (ទម្រង់ទី៥)
- គ.ក.ន.ក រៀបចំកិច្ចប្រជុំពិភាក្សា ដើម្បីស្វែងរកអ្នកសម្របសម្រួល និងវាគ្មិនសម្រាប់វេទិកាសាធារណៈ ដោយប្រើប្រាស់ធនធានមនុស្សក្នុងឃុំ សង្កាត់ ដូចជា ក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ។ល។ ឬដៃគូអភិវឌ្ឍន៍នានាក្នុងឃុំ សង្កាត់ ដើម្បីសម្របសម្រួល និងដឹកនាំវេទិកាសាធារណៈ (បើអាច)
- ពិនិត្យអំពីគម្រោងដែលបានព្រមព្រៀងក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ដែលមានការសន្យាដោយមន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរពាក់ព័ន្ធ ឬដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកធនធានមនុស្សសម្រាប់វេទិកាសាធារណៈ
- គ.ក.ន.ក អាចលើកបញ្ហានេះនៅក្នុងកិច្ចប្រជុំប្រចាំខែ ប្រចាំត្រីមាសរបស់ គ.ក.ន.ក ក្នុងការស្វែងរកការគាំទ្រពីការិយាល័យកិច្ចការនារី ឬមន្ទីរពាក់ព័ន្ធ ឬដៃគូអភិវឌ្ឍន៍នានា ដើម្បី :
  - រៀបចំវេទិកាសាធារណៈដោយស្ថាប័នទាំងនោះនៅតាមភូមិ ឬឃុំ សង្កាត់ តាមកម្មវិធីដែលបានព្រមព្រៀងជាមួយឃុំ សង្កាត់
  - ផ្តល់ការណែនាំ និងផ្តល់ជំនួយបច្ចេកទេសដល់ធនធានមនុស្សរបស់ឃុំ សង្កាត់ ដើម្បីធ្វើការរៀបចំវេទិកាសាធារណៈ
- ទីចាត់ការផែនការ និងវិនិយោគអាចជួយឃុំ សង្កាត់ក្នុងការទំនាក់ទំនង និងសម្របសម្រួលជាមួយ មន្ទីរកិច្ចការនារី មន្ទីរពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយឃុំ សង្កាត់ក្នុងការរៀបចំវេទិកាសាធារណៈ ។

ឃ.៣). ការត្រៀមរៀបចំវេទិកាសាធារណៈ

- បន្ទាប់ពីទទួលបានការគាំទ្រពីបណ្តាមន្ទីរពាក់ព័ន្ធ ( មន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ឬអ្នកពាក់ព័ន្ធមក គ.ក.ន.ក ត្រូវជួបប្រជុំជាមួយស្ថាប័នដែលផ្តល់ការគាំទ្រទាំងនេះ ដើម្បីពិភាក្សាឯកភាពលើការងារមួយចំនួនដូចខាងក្រោម :
  - កម្មវិធី និងវិធីសាស្រ្ត
  - កំណត់ចំនួន និងក្រុមគោលដៅ
  - អ្នកសម្របសម្រួល និងវាគ្មិន
  - ការរៀបចំទីកន្លែង
  - ការរៀបចំឯកសារ និងសម្ភារៈផ្សព្វផ្សាយ
  - បែងចែកការទទួលខុសត្រូវ
  - . . .។ល។
- គ.ក.ន.ក អ្នកដឹកនាំភូមិ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវផ្តល់ព័ត៌មាន និងប្រមូលប្រជាពលរដ្ឋចូលរួម និងរៀបចំទីកន្លែង និងមធ្យោបាយគាំទ្រផ្សេងៗទៀតដូចជា សម្ភារៈ ឧបករណ៍ បំពងសម្លេង និងអាហារសម្រន់។ល។

ឃ.៤). ដំណើរការវេទិកាសាធារណៈ

វេទិកាសាធារណៈអាចដំណើរការដូចខាងក្រោម :

- បទស្វាគមន៍ និងការណែនាំខ្លួន
- បង្ហាញអំពីគោលបំណង និងកម្មវិធី
- ការកំណត់អំពីវិន័យសម្រាប់ការចូលរួម
- ការធ្វើបទឧទ្ទេសនាម
- នាទីសំណួរ និងចម្លើយ
- ការបូកសរុបលទ្ធផលការងារ
- ពិធីបិទវេទិកា ( ការថ្លែងអំណរគុណ...)

ង). ការអនុវត្តលទ្ធផលវេទិកាសាធារណៈ

ង.១). ការពិនិត្យលទ្ធផលវេទិកា និងការឆ្លើយតប

ចំពោះបញ្ហានានាដែលបានលើកឡើងក្នុងឱកាសវេទិកាសាធារណៈ ហើយពុំទាន់បានដោះស្រាយ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវជួយ គ.ក.ន.ក ក្នុងការកត់ត្រាសំណើ ឬសំណូមពរ ឬសំណួរនានា ឬរៀបចំរបាយការណ៍ ដើម្បីដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងស្វែងរកវិធានការណ៍ដោះស្រាយ។ អាស្រ័យលើខ្លឹមសារ និងតម្រូវការដោះស្រាយក្រុមប្រឹក្សាឃុំ សង្កាត់អាចឆ្លើយតបទឹងបញ្ហាទាំងនោះដូចខាងក្រោម :

- ជួបពិភាក្សាដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ឬសហគមន៍ដែលមានបញ្ហា ដើម្បីធ្វើការដោះស្រាយ
- សហការជាមួយផ្នែកពាក់ព័ន្ធ ដើម្បីចូលរួមដោះស្រាយបញ្ហាដែលបានកើតឡើង
- ផ្តល់ព័ត៌មានអំពីបញ្ហាទាំងនោះ ទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីជំរុញឱ្យមានការដោះស្រាយ
- រៀបចំផែនការសកម្មភាព និងបែងចែកការទទួលខុសត្រូវដល់សមាជិកក្នុងឃុំ សង្កាត់ ដើម្បីដោះស្រាយ

ង.២). ការត្រួតពិនិត្យ និងការជំរុញការអនុវត្ត

- ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំវេទិកាសាធារណៈ (មន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការមិនមែនរដ្ឋាភិបាល ។ល។) ត្រូវចុះត្រួតពិនិត្យដំណើរការវេទិកាសាធារណៈ ដើម្បីធានាថា ដំណើរការ និងខ្លឹមសារត្រូវបានអនុវត្តន៍តាមការគ្រោងទុក
- គ.ក.ន.ក អ្នកដឹកនាំភូមិ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវចុះត្រួតពិនិត្យការរៀបចំ និងការអនុវត្តវេទិកាសាធារណៈ ដើម្បីធានាថា ការចូលរួមរបស់ប្រជាពលរដ្ឋ ដំណើរការ និងខ្លឹមសារត្រូវបានអនុវត្តន៍តាមការគ្រោងទុក
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវរៀបចំរបាយការណ៍ ឬកំណត់ហេតុ ដោយកត់ត្រាសំណូមពរ និងបញ្ហានានាដែលបានលើកឡើង ដើម្បីរាយការណ៍នៅក្នុងកិច្ចប្រជុំរបស់ គ.ក.ន.ក និងក្រុមប្រឹក្សាឃុំ សង្កាត់ និងចាត់វិធានការដោះស្រាយ ឬបញ្ជូនសំណូមពរទៅសមត្ថកិច្ចពាក់ព័ន្ធ
- គ.ក.ន.ក និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ត្រូវត្រួតពិនិត្យអំពី វិធានការដោះស្រាយ ដើម្បីធានាថាបញ្ហា ឬសំណូមពររបស់ប្រជាពលរដ្ឋត្រូវបានដោះស្រាយ ។

## ២.២.៦. ការគាំទ្រមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ

### ក). លក្ខខណ្ឌនៃការគាំទ្រមធ្យោបាយធ្វើដំណើរ

ការគាំទ្រមធ្យោបាយធ្វើដំណើរសម្រាប់សង្គ្រោះជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារត្រូវផ្អែកតាមលក្ខខណ្ឌដូចខាងក្រោម :

- ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារជាស្ត្រី និងកុមារត្រូវផ្តល់ការគាំទ្រជាអាទិភាព
- ស្ត្រីដែលស្ថិតនៅក្នុងគ្រួសារមានជីវភាពក្រីក្រជាងគេ ពុំមានលទ្ធភាពទៅមណ្ឌលសុខភាព ឬកន្លែងផ្តល់សេវាសង្គ្រោះ
- ការគាំទ្រផ្តោតជាអាទិភាពសម្រាប់ជាមធ្យោបាយធ្វើដំណើរសម្រាប់តែការសង្គ្រោះបន្ទាន់ និងទីកន្លែងដែលអាចសង្គ្រោះបាន និងជិតបំផុត
- រាល់ការស្នើសុំត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរពីសាមីខ្លួន ឬក្រុមគ្រួសារ។ ញាតិជិតខាង ឬអ្នកដឹកនាំភូមិក៏អាចស្នើសុំឱ្យសាមីខ្លួនបានផងដែរ ក្នុងករណីមានការស្នើសុំពីសាមីខ្លួន

- ករណីសង្គ្រោះបន្ទាន់ មេឃុំ ចៅសង្កាត់អាចសម្រេចផ្តល់ការគាំទ្រដោយមិនចាំបាច់មានសំណើសុំជាលាយលក្ខណ៍អក្សរជាមុន
- ចំនួនថវិកាគាំទ្រដល់មធ្យោបាយធ្វើដំណើរសម្រាប់ជនរងគ្រោះ ពីអំពើហិង្សាក្នុងគ្រួសារ ផ្អែកតាមភាពជាក់ស្តែងនៃតម្លៃដឹកជញ្ជូន ចម្ងាយ និងលទ្ធភាពនៃការគាំទ្រ។

២). ដំណើរការផ្តល់ការគាំទ្រ

២.១). ការស្នើសុំការគាំទ្រ

- សាមីខ្លួន ឬក្រុមគ្រួសារអាចដាក់ពាក្យស្នើសុំការគាំទ្រទៅមេឃុំ ចៅសង្កាត់ ឬតាមរយៈ អ្នកដឹកនាំភូមិ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (ទម្រង់ទី៧)
- អ្នកដឹកនាំភូមិ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ ឬញាតិជិតខាង ក៏អាចជួយសម្របសម្រួលក្នុងការរៀបចំពាក្យស្នើសុំ ឬស្នើសុំផងដែរ ករណីមានការស្នើសុំពីសាមីខ្លួន ឬក្រុមគ្រួសារ
- ការស្នើសុំត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាមុន លើកលែងតែការសង្គ្រោះបន្ទាន់។

២.២). ការពិនិត្យសម្រេច

- បន្ទាប់ពីទទួលបានសំណើសុំ មេឃុំ ចៅសង្កាត់អាចពិគ្រោះយោបល់ជាមួយអ្នកដឹកនាំភូមិ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដើម្បីពិនិត្យ និងសម្រេច
- មេឃុំ ចៅសង្កាត់ត្រូវផ្តល់ព័ត៌មានអំពីការសម្រេចចិត្តរបស់ខ្លួនដល់អ្នកស្នើសុំជាបន្ទាន់ បន្ទាប់ពីបានទទួលសំណើ
- មេឃុំ ចៅសង្កាត់ត្រូវរាយការណ៍ពីលទ្ធផលនៃការគាំទ្រមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារក្នុងកិច្ចប្រជុំ គ.ក.ន.ក
- ករណីសង្គ្រោះបន្ទាន់ មេឃុំ ចៅសង្កាត់អាចធ្វើការសម្រេចផ្តល់ការគាំទ្របានដោយមិនចាំបាច់មានសំណើជាលាយលក្ខណ៍អក្សរជាមុន។ ករណីនេះ សាមីខ្លួន ឬតំណាងអាចជួយរៀបចំពាក្យស្នើសុំជាក្រោយ។

២.៣). ការគាំទ្រមធ្យោបាយធ្វើដំណើរ

- ឃុំ សង្កាត់ត្រូវរៀបចំជាមធ្យោបាយធ្វើដំណើរជូនដល់ជនរងគ្រោះ ពីអំពើហិង្សាក្នុងគ្រួសារដោយទំនាក់ទំនងជាមួយអ្នកមានមធ្យោបាយដឹកជញ្ជូននៅមូលដ្ឋាន ពិសេសករណីសង្គ្រោះបន្ទាន់
- ឃុំ សង្កាត់ក៏អាចផ្តល់ជាថវិកា ដើម្បីឱ្យជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសាររៀបចំមធ្យោបាយធ្វើដំណើរទៅកាន់មណ្ឌលសុខភាព ឬកន្លែងផ្តល់សេវាសង្គ្រោះដោយខ្លួនឯង។

ឥ. ការត្រួតពិនិត្យ និងការជំរុញការអនុវត្ត

- មេឃុំ ចៅសង្កាត់ អ្នកដឹកនាំភូមិ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវទំនាក់ទំនងជាមួយអ្នកផ្តល់សេវាដឹកជញ្ជូន ដើម្បីធានាថាការផ្តល់សេវាដឹកជញ្ជូនឱ្យបានទាន់ពេលវេលា
- មេឃុំ ចៅសង្កាត់ត្រូវទំនាក់ទំនង និងផ្តល់ព័ត៌មានដល់មណ្ឌលសុខភាព ដើម្បីធានាថា មណ្ឌលសុខភាពផ្តល់សេវាសង្គ្រោះបន្ទាន់ជាប្រចាំ និងទាន់ពេលវេលា
- មេឃុំ ចៅសង្កាត់ អ្នកដឹកនាំភូមិ ឬអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវផ្តល់ការណែនាំដល់ជនបង្កអំពើហិង្សាក្នុងគ្រួសារឱ្យបញ្ឈប់សកម្មភាពហិង្សាក្នុងគ្រួសារ ឬចាត់វិធានការតាមផ្លូវច្បាប់
- មេឃុំ ចៅសង្កាត់ត្រូវតាមដានត្រួតពិនិត្យដំណើរការនៃការអនុវត្ត ដើម្បីធានាថា ការគាំទ្រមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារត្រូវបានដោះស្រាយទាន់ពេលវេលា ប្រកបដោយតម្លាភាព ការចំណាយអនុវត្តតាមនីតិវិធី និងរៀបចំកិច្ច បញ្ជីកាត្រឹមត្រូវតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់។

## ២.៣. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ សង្កាត់ និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ត្រូវជួយមេឃុំ ចៅសង្កាត់ និង គ.ក.ន.ក ក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីសកម្មភាព និងលទ្ធផលដែលមាននៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃអាចធ្វើឡើងតាមរយៈ :

- ការចុះតាមដានត្រួតពិនិត្យដំណើរការអនុវត្តសកម្មភាព និងលទ្ធផលការងារ និងរៀបចំរបាយការណ៍រីកចម្រើនស្តីពី ការអនុវត្តសកម្មភាព (ទម្រង់ទី២០) និងរបាយការណ៍រីកចម្រើនស្តីពី ការអនុវត្តថវិកា (ទម្រង់ទី២១) ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បី :
  - រាយការណ៍ជូន គ.ក.ន.ក នៅក្នុងកិច្ចប្រជុំប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
  - រាយការណ៍អំពីភាពរីកចម្រើននៃការអនុវត្តសកម្មភាព និងថវិកាជូន គ.ក.ន.ក និងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដោះស្រាយបញ្ហានានា
- ការសហការជាមួយស្ថាប័នពាក់ព័ន្ធ ក្នុងការវាយតម្លៃផលប៉ះពាល់នៃការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់។

ឧទាហរណ៍

ទម្រង់ទី២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :.........................

ក្រុង ស្រុក ខណ្ឌ :.........................

ឃុំ សង្កាត់ :.........................

របាយការណ៍រីកចម្រើនស្តីពីការអនុវត្តសកម្មភាព

អភិវឌ្ឍន៍ផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

ប្រចាំ *ត្រីមាសទី៣* ឆ្នាំ*២០១០*

| ល.រ | សកម្មភាព និងលទ្ធផល | លទ្ធផល | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | កាលបរិច្ឆេទអនុវត្ត | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | | |
| ១ | ការលើកកម្ពស់សុខភាពមាតា | | | | | | | |
| ១.១. | *ផ្សព្វផ្សាយអំពីសុខភាពមាតា* | *វគ្គ* | *២* | *ភូមិ ក និងភូមិ ខ* | *៥០* | *៣០* | *១០/០៧/១០* | |
| ១.២. | *ការនាំស្ត្រីមានផ្ទៃពោះសម្រាលកូននៅមណ្ឌលសុខភាព* | *នាក់* | *៦* | *ភូមិ ក ភូមិ ខ និងភូមិ គ* | *៦* | *៦* | *១៥/០៨/១០* | |
| ២ | ការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍ | | | | | | | |
| ២.១. | *ការប្រជុំរៀបចំមត្តេយ្យសិក្សាសហគមន៍* | *ប្រជុំ* | *២* | *សាលាឃុំ* | *១០* | *៥* | *២០/០៧/១០* | |
| ២.២. | *ដំណើរការមត្តេយ្យសហគមន៍* | *ថ្នាក់* | *១* | *ភូមិ ក* | *២៥* | *១៥* | *២៥/០៨/១០* | |

| ល.រ | សកម្មភាព និងលទ្ធផល | លទ្ធផល | | ទីតាំង | អ្នកទទួលផលផ្ទាល់ | | កាលបរិច្ឆេទ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ឯកតា | ចំនួន | | សរុប | ស្រី | អនុវត្ត | |
| ៣ | ការលើកកម្ពស់អនាម័យនៅមូលដ្ឋាន | | | | | | | |
| ៣.១. | ផ្សព្វផ្សាយអំពីអនាម័យនៅមូលដ្ឋាន | វគ្គ | ២ | ភូមិ ឃ និងភូមិ ឈ | ៥០ | ៣០ | ១០/០៨/១០ | |
| ៣.២. | ការផ្ដល់សម្ភារៈបង្គន់អនាម័យ | គ្រឿង | ១០ | ភូមិ ក ភូមិខ និងភូមិ គ | ៥០ | ២៥ | ១៥/០៩/១០ | |
| ៤ | ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ | | | | | | | |
| ៤.១. | ផ្សព្វផ្សាយសមភាពយេនឌ័រ និងកិច្ចការពារកុមារ | វគ្គ | ២ | ភូមិ ក និងភូមិ គ | ៥០ | ៣០ | ១៥/០៧/១០ | |
| ៤.២. | គាំទ្រការធ្វើដំណើរដល់ជនរងគ្រោះទៅសង្គ្រោះ | នាក់ | ៣ | ភូមិ ឈ | ៣ | ៣ | ២០/០៨/១០ | |
| ៥ | ការប្រជុំ និងតាមដានត្រួតពិនិត្យរបស់ គ.ក.ន.ក | | | | | | | |
| ៥.១. | ការរៀបចំប្រជុំ គ.ក.ន.ក | ប្រជុំ | ៩ | សាលាឃុំ និងសាលាស្រុក | ៩០ | ៥០ | ២៥/០៧-០៩/១០ | |
| ៥.២. | ចុះតាមដានត្រួតពិនិត្យសកម្មភាពអនុវត្ត | លើក | ១០ | ភូមិ ក ភូមិ ខ និងភូមិ គ | ១០ | ៥ | ២៥/០៨/១០ | |

ថ្ងៃទី........ ខែ........... ឆ្នាំ.............

អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ

ថ្ងៃទី........ ខែ........... ឆ្នាំ.............

មេឃុំ ចៅសង្កាត់

ឧទាហរណ៍

ទម្រង់ទី២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត :........................
ក្រុង ស្រុក ខណ្ឌ :......................
ឃុំ សង្កាត់ :...........................

**របាយការណ៍រកចម្រើនស្តីពីការអនុវត្តថវិកា**

**សម្រាប់ការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា មត្តេយ្យសិក្សាសហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារ**

ប្រចាំ......*មេសា*..... ឆ្នាំ...*២០១០*...

| ល.រ | ការបរិយាយ | ថវិកាគ្រោង | ការចំណាយ | | | សមតុល្យ |
|---|---|---|---|---|---|---|
| | | | កន្លងមក | ក្នុងខែ | បូកយោង | |
| ១ | ការលើកកម្ពស់សុខភាពមាតា | **1,065,000** | ***266,250*** | ***88,750*** | ***355,000*** | ***710,000*** |
| | ការប្រជុំ និងផ្សព្វផ្សាយអំពីសុខភាពមាតា | 345,000 | *86,250* | *28,750* | *115,000* | *230,000* |
| | ការគាំទ្រស្ត្រីមានផ្ទៃពោះក្នុងការសម្រាលកូននៅមណ្ឌលសុខភាព | 720,000 | *180,000* | *60,000* | *240,000* | *480,000* |
| ២ | មត្តេយ្យសិក្សាសហគមន៍ | **925,000** | ***231,250*** | ***77,083*** | ***308,333*** | ***616,667*** |
| | ការប្រជុំរៀបចំមត្តេយ្យសិក្សាសហគមន៍ | 345,000 | *86,250* | *28,750* | *115,000* | *230,000* |
| | កិច្ចដំណើរការមត្តេយ្យសហគមន៍ | 580,000 | *145,000* | *48,333* | *193,333* | *386,667* |

| ល.រ | ការបរិយាយ | ថវិកាគ្រោង | ការចំណាយ | | | សមតុល្យ |
|---|---|---|---|---|---|---|
| | | | កន្លងមក | ក្នុងខែ | បូកយោង | |
| ៣ | **ការលើកកម្ពស់អនាម័យមូលដ្ឋាន** | **705,000** | ***176,250*** | ***58,750*** | ***235,000*** | ***470,000*** |
| | ការប្រជុំ ការផ្សព្វផ្សាយ និងទិវាអំពីអនាម័យនៅមូលដ្ឋាន | 345,000 | *86,250* | *28,750* | *115,000* | *230,000* |
| | ការផ្តល់សម្ភារៈសម្រាប់ការងារអនាម័យ | 360,000 | *90,000* | *30,000* | *120,000* | *240,000* |
| ៤ | **ការលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ** | **573,000** | ***143,250*** | ***47,750*** | ***191,000*** | ***382,000*** |
| | ការប្រជុំ និងផ្សព្វផ្សាយការងារយេនឌ័រ និងកិច្ចការពារកុមារ | 525,000 | *131,250* | *43,750* | *175,000* | *350,000* |
